រក្សាសិទ្ធិ.©. ពត៌មាន :

©.២00១.Project.WorldReach.....©.២00១ SEAN

រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត®

.Project.WorldReach.(T&M®. ព័ន្ធកិច្ចប្រតិបត្តិការ)

SEAN. អន្តរជាតិ.

អាស័យដ្ឋានសំរាប់ទាក់ទង

Project.WorldReach..PWR®.

E-mail:.pwr@trainandmultiply.com

Website:.http://www.trainandmultiply.com

037KH-H01K01

BETA VERSION released prior to proofreading

ស្បៀវភៅណែនាំអំពីការបង្កើតក្រុមជំនុំ



កូនស្បៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៣៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M.®



"ចូរមើលទៅវាលស្រែមើល៍ ស្រូវទុំល្មមច្រូតហើយ" ។

(យ៉ូហាន ៤:៣៥)

BETA VERSION released prior to proofreading



សង្ខេបអំពីគោលដៅ :

បង្ហាត់បង្រៀនពួកអ្នកដឹកនាំសំរាប់ក្រុមជំនុំថ្មី ដោយប្រើកម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួន បន្ត »™ ។

«ពាក្យនេះគួរអោយជឿ គឺថាប្រសិនបើបងប្អូនណាម្នាក់ចង់បានមុខងារជាអភិបាល គាត់មានបំណងបំពេញមុខងារដ៏ប្រសើរហើយ » ។ (១ ធីម៉ូថេ ៣:១)



BETA VERSION released prior to proofreading

មាតិកា

សេចក្តីផ្តើម

សកម្មភាពនៃការបង្កើតក្រុមជំនុំ	**ទំព័រ**
១- អធិស្ឋាន និង រៀបចំផែនការ	១៧
២- រៀបចំក្រុមបង្កើតក្រុមជំនុំរបស់អ្នក	៣៦
៣- ទាក់ទងអោយស្គាល់បណ្តាជន និង រាប់អានពួកគេ	៤៥
៤- ប្រកាសជ័យជំនះរបស់ព្រះគ្រីស្ត ដោយការ អធិស្ឋាន	៦៦
៥- រកមនុស្សដែលចាប់អារម្មណ៍អំពីដំណឹងល្អ	៧២
៦- បង្រៀនដំណឹងល្អព្រះយេស៊ូ	៩០
៧- វាយតម្លៃលទ្ធផល	១០៩
៨- ធ្វើពិធីជ្រមុជទឹក និង ទទួលជាសមាជិក	១១៧
៩- បង្រៀនអ្នកជឿថ្មីអោយចេះប្រតិបត្តិតាមព្រះគ្រីស្ត	១៣៤
១០- រៀបចំធ្វើការប្រជុំថ្វាយបង្គំ	១៤៣
១១- បណ្តុះបណ្តាលសមាជិកនៃក្រុមជំនុំថ្មីអោយផ្សាយ ដំណឹងល្អ	១៦៦
១២- បង្ហាត់បង្រៀនអ្នកដឹកនាំ	១៧៣

សេចក្តីផ្តើម



បងប្អូនរួមការងារជាទីស្រឡាញ់ សៀវភៅណែនាំនេះ
ពន្យល់អំពីគោលការណ៍របស់ព្រះគម្ពីរ សំរាប់ចាប់ផ្តើម ក្រុមជំនុំ
និង ក្រុមជំនុំតាមផ្ទះ ដែលនឹងរីកចំរើន និង កើនចំនួនបន្ត ។
ព្រះគម្ពីរបង្ហាញរបៀបបួនយ៉ាងសំរាប់ បង្កើតក្រុមជំនុំ គឺ :

១- (ដំបូន្មានរបស់លោកយេត្រូ យោងទៅតាមក័ណ្ឌគម្ពីរ សេរីភាព ១៨):
នេះជាវិធីមួយ ដែលនាំអោយក្រុមជំនុំធំ ឬ ក្រុមជំនុំតាម
ផ្ទះ ឬ ក្រុមតូចបំបែកខ្លួន ដើម្បីបង្កើតក្រុមជំនុំ ឬ ក្រុមថ្មី ទៀត ។
នៅពេលដែលមានចំនួនមនុស្សល្មមគ្រប់គ្រាន់
នៅក្នុងក្រុមជំនុំ ឬ ក្រុមជំនុំតាមផ្ទះ ឬ ក្រុមតូចហើយ
ពួកគេបែងចែកសមាជិករបស់ខ្លួនមួយចំនួន អោយទៅប្រជុំ
ថ្វាយបង្គំនៅកន្លែងមួយថ្មី ។

BETA VERSION released prior to proofreading

«កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល »ក៏រួតទីមួយ បង្រៀ
ពីជំហានដំបូងៗនៃការងារឃ្វាល ដូចជាការផ្សព្វផ្សាយដំណឹងល្អ
ការធ្វើពិធីជ្រមុជទឹក ការបង្រៀនក្រុមជំនុំអោយមានសេចក្តី
ស្រឡាញ់ ការថ្វាយបង្គំ ការដាក់ដង្វាយ និង ការបង្កើតសាវ័ក ។
កូនសៀវភៅទាំងនោះ បង្រៀនអំពីសកម្មភាពជាច្រើន ដែលដូច
សកម្មភាពរបស់ «សៀវភៅណែនាំការបង្កើតក្រុមជំនុំ »នេះដែរ ។
ប៉ុន្តែ កូនសៀវភៅទាំងនោះខុសគ្នាខ្លាំងបំផុតពី «សៀវភៅណែនាំ
ការបង្កើតក្រុមជំនុំ »នេះ ត្រង់អ្នកដឹកនាំថ្មីធ្វើការងារឃ្វាល មិន
មែនសមាជិកក្រុមបង្កើតក្រុមជំនុំទេ ។ នៅក្នុងក៏រួតផ្សេងទៀត
គឺ ក៏រួតទីពីរ និង ក៏រួតទីបី អ្នកដឹកនាំថ្មីធ្វើការងារ ដើម្បីបង្កើត
សកម្មភាពផ្សេងៗជាច្រើន នៅក្នុងក្រុមជំនុំ ដូចជាការរៀបចំ ពួកអ្នកដឹកនាំ
ការជួយអ្នកខ្វះខាត ការពង្រីកការងារផ្សព្វផ្សាយ ដំណឹងល្អ
ការចាត់គ្រីស្តទូតអោយចេញទៅ ។ល។ ។

អ្នកត្រូវជ្រើសរើសពួកអ្នកជឿ ដែលប្រតិបត្តិតាមសេចក្តីបង្គាប់
របស់ព្រះគ្រីស្ត សកម្មក្នុងការផ្សាយដំណឹងល្អ និង ជាមេគ្រួសារ
ដែលគេគោរពរាប់អាននៅក្នុងសហគមន៍ ។ ពួកគេត្រូវខំបំពេញ
លក្ខខ័ណ្ឌ នៅក្នុង ១ ធីម៉ូថេ ៣:១-៧ និង ទីតុស ១:៥-៩
ពីព្រោះនៅពេលក្រោយពួកគេត្រូវបំពេញភារៈកិច្ចឃ្វាល ។

- សរសេរឈ្មោះរបស់អស់អ្នកដែលត្រូវទទួលការបង្ហាត់ បង្រៀន
ដើម្បីធ្វើជាអ្នកបំពេញភារៈកិច្ចឃ្វាល :

- សូមរកអោយបាន "សៀវភៅណែនាំសកម្មភាពនិស្សិតគ្រួ
គង្វាល» មួយក្បាល និង កម្រង "កូនសៀវភៅសំរាប់បង្ហាត់
បង្រៀនគ្រួគង្វាល "មួយឈុត (កូនសៀវភៅពីលេខ ១ ដល់លេខ
៦៣) សំរាប់និស្សិតម្នាក់ៗ ។

- អោយគ្រួចាប់ផ្តើមបង្ហាត់បង្រៀន តាមការណែនាំជាបន្ត បន្ទាប់
ដែលមាននៅក្នុង "សៀវភៅណែនាំសំរាប់គ្រួបង្ហាត់ និស្សិតគ្រួគង្វាល
" និង "សៀវភៅណែនាំសកម្មភាពនិស្សិត គ្រួគង្វាល "របស់កម្មវិធី
«បង្ហាត់បង្រៀន និង បង្កើនចំនួន បន្ត »™ ។

BETA VERSION released prior to proofreading

២- (ក្រុមជំនុំនៅទីក្រុងយ៉ុបប៉ េ បញ្ជូនសមាជិកមួយក្រុមអោយ ចេញទៅ
យោងទៅតាមកិច្ចការជំពូក ១០-១១) :
នៅក្នុងករណីនោះ ក្រុមជំនុំមួយ ឬ ក្រុមជំនុំច្រើនដែលធ្វើ
ការងារជាដៃគូរួមគ្នា និង ប្រហែលជាមួយនឹងទីភ្នាក់ងារ
បេសកកម្មគ្រីស្តទូតដែរ បញ្ជូនសមាជិកមួយក្រុមអោយទៅ
កន្លែងជិតខាងក្រុមជំនុំនោះ ។ ក្រុមនោះ ដែលតាមធម្មតា
ជាក្រុមធំមួយ ធ្វើការងារក្នុងទីកន្លែងមួយ ក្នុងរយៈពេលខ្លី
លួមមួយ ។

៣- (យោងទៅតាមកិច្ចការ ជំពូក ១៣-១៤ ក្រុមជំនុំនៅក្រុង
អង់ទីយ៉ូក បញ្ជូនសមាជិកមួយក្រុមតូចអោយចេញទៅ):
ក្រុមជំនុំនៅក្រុងអង់ទីយ៉ូកបញ្ជូនក្រុមមួយ អោយទៅបង្កើត
ក្រុមជំនុំ ។ ក្រុមនេះតូចជាង និង ធ្វើដំណើរឆ្ងាយជាង និង
ធ្វើការងារក្នុងរយៈពេលវែងជាង ដើម្បីចាប់ផ្តើម ក្រុមជំនុំច្រើន ។

៤- (ក្រុមជំនុំនៅផ្ទះរបស់លោកអាគីឡា និង នាងព្រីស៊ីឡា
យោងទៅតាមកិច្ចការ ១៨, រ៉ូម ១៦:៥, ១ កូរិនថូស ១៦:១៩) :
ប្តីប្រពន្ធនេះធ្វើដំណើរពីទីក្រុងមួយ ទៅទីក្រុងមួយ ដើម្បី
ចាប់ផ្តើមក្រុមជំនុំនៅផ្ទះរបស់ពួកគាត់ នៅទីក្រុងរ៉ូម
កូរិនថូស និង អេភេសូ ។

តើក្រុមជំនុំជាអ្វី ? តើយើងបង្កើតអ្វី ?

- ក្រុមជំនុំជាក្រុមអ្នកជឿលើព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលប្តេជ្ញាប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ដោយសេចក្តីស្រឡាញ់ តាមរយៈឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។

- ក្រុមជំនុំមិនមែនជាកម្មវិធីសំរាប់អធិប្បាយប្រាប់អ្នកដែលគ្រាន់តែស្តាប់ទេ ហើយក្រុមជំនុំក៏មិនមែនជាអាគារ ឬ អង្គការមួយដែលមនុស្សបង្កើតដែរ ។

  តើក្រុមជំនុំត្រូវធ្វើអ្វី ? ក្រុមជំនុំប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ដើម្បីបង្កើតសាវ័ក ដែលប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ (ម៉ាថាយ ២៨:១៨-២០) ។ ការបង្កើតសាវ័កនេះរួមមាន :

- ផ្សាយដំណឹងល្អដល់មិត្តភ័ក្តិ និង សាច់ញាតិរបស់យើង ព្រមទាំងធ្វើពិធីជ្រមុជទឹកអោយអស់អ្នកដែលទទួលជឿ (កិច្ចការ ១:៨, កិច្ចការ ២:៣៧-៤១) ។

- បង្រៀនប្រដៅពួកអ្នកជឿ ដោយព្រះបន្ទូលព្រះជាម្ចាស់ (កិច្ចការ ២:៤២) ។

BETA VERSION released prior to proofreading

វិធីបង្គាត់បង្រៀននេះមានផលប្រយោជន៍ច្រើនណាស់ ជាពិសេសនៅក្នុងកន្លែង ដែលមិនទាន់មានក្រុមជំនុំ :

- និស្សិតគ្រូគង្វាលសិក្សាផង និង ធ្វើការឃ្វាលផង ។

- ប្រជាជននៅជិតខាងទទួលពួកអ្នកដឹកនាំ ដែលពួកគេស្គាល់ស្រាប់ហើយ ។

- ពួកអ្នកជឿថ្មីមានបំណងទទួលខុសត្រូវលើក្រុមជំនុំថ្មី និងកាន់តែសកម្មធ្វើការងារថ្វាយព្រះអម្ចាស់ ។

- ក្រុមជំនុំអាចកើនចំនួនបន្ត ដោយសារតែគេបង្គាត់បង្រៀនពួកអ្នកដឹកនាំថ្មីកាន់តែច្រើន និង ជាបន្តរហូត ។

- អោយអ្នកដែលនឹងធ្វើជានិស្សិតគ្រូគង្វាល សិក្សា "សៀវភៅណែនាំសំរាប់គ្រូបង្គាត់និស្សិតគ្រូគង្វាល" នៅក្នុងកម្មវិធី " បង្គាត់បង្រៀន និង បង្កើនចំនួនបន្ត™ " ដើម្បីអោយគេចេះដឹងពីតួនាទីរបស់គេ ។

- ជ្រើសរើសពួកអ្នកដែលគ្រូបង្គាត់នឹងបង្គាត់បង្រៀនអោយខ្លាយជាអ្នកដឹកនាំកិច្ចការឃ្វាលរបស់ក្រុមជំនុំថ្មី ។

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ពួកអ្នកដឹកនាំថ្មីរបស់ ក្រុមជំនុំ
ដែលត្រូវទទួលការបង្ហាត់បង្រៀន និង ជំរាបក្រុម
អធិស្ឋានអំពីសំណូមពរអធិស្ឋានផ្សេងៗទៀត) ។

*«ខ្ញុំបានទុកអ្នកអោយនៅកោះក្រែត ដើម្បីចាត់ចែងកិច្ចការ ដែល នៅសល់
អោយមានរបៀបរៀបរយ និង តែងតាំងព្រឹទ្ធាចារ្យ នៅតាមក្រុងនិមួយៗ
ដូចខ្ញុំបានផ្តាំរួចហើយ » ។ (ទីតុស ១:៥)*

លោកទីតុសស្នាក់នៅទីក្រុងក្រែត ដើម្បីបង្រៀនពួកអ្នកដឹកនាំ
របស់ក្រុមជំនុំថ្មី ។ ការបង្ហាត់បង្រៀនពួកអ្នកដឹកនាំសំខាន់បំផុត
សំរាប់ការបង្កើតក្រុមជំនុំ ។

យោបល់សំរាប់ការបង្ហាត់បង្រៀនពួកអ្នកដឹកនាំថ្មី :

- ចាត់តាំងអ្នកណាម្នាក់ នៅក្នុងក្រុមបង្កើតក្រុមជំនុំអោយ
  ចាប់ផ្តើមបង្ហាត់បង្រៀនពួកអ្នកដឹកនាំ សំរាប់ក្រុមជំនុំថ្មី
  ដោយប្រើកម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត»™ ។

  វិធីបង្ហាត់បង្រៀនគ្រួគង្វាលនេះ ល្អបំផុតសំរាប់ធ្វើអោយក្រុមជំន
  កើនចំនួនបន ដោយសារអ្នកដឹកនាំថ្មីរបស់ក្រុមជំនុំថ្មី អាចបង្កើត
  ក្រុមជំនុំថ្មីៗទៀតជាបន្ត ។

BETA VERSION released prior to proofreading

- ថ្វាយបង្គំព្រះជាម្ចាស់ តាមរយៈការធ្វើពិធីកាច់នំប៉័ង អធិស្ឋាន
  ច្រៀងសរសើរតម្កើង និង ធ្វើទីបន្ទាល់ (កិច្ចការ ២:៤២) ។

- ការបណ្តុះអោយពួកអ្នកជឿចេះស្រឡាញ់គ្នាទៅវិញទៅមក
  (យ៉ូហាន ១៣:៣៤-៣៥) ។

- ការបំរើអ្នកខ្វះខាត ដោយសេចក្តីស្រឡាញ់ (កាឡាទី ៦:១០) ។

- ការរៀបចំគ្រួគង្វាល និង ពួកអ្នកចាស់ទុំរបស់ក្រុមជំនុំ ។
  (២ ធីម៉ូថេ ២:២)

តើអ្នកណាអាចធ្វើជាអ្នកបង្កើតក្រុមជំនុំ ?

យើងរកមើលមនុស្ស ដែលចូលចិត្តបំរើព្រះគ្រីស្ត ។ ពួកគេមិន
ចាំបាច់មានជំនាញអស្ចារ្យៗទេ ប៉ុន្តែ ពួកគេត្រូវស្ម័គ្រចិត្តផ្សាយ
ដំណឹងល្អ និង បង្កើតសាវ័កដែលធ្វើកិច្ចការដូចមានរៀបរាប់ខាង
លើនេះ ។

សកម្មភាពទាំងដប់ពីរសំរាប់បង្កើតក្រុមជំនុំ



BETA VERSION released prior to proofreading

គោលការណ៍ ទី ១២
បង្ហាត់បង្រៀនអ្នកដឹកនាំ



គោលដៅ :

- ជួយក្រុមបង្កើតក្រុមជំនុំ អោយអាចបង្ហាត់បង្រៀនពួកអ្នក ដឹកនាំ និង បង្កើតរបៀបដឹកនាំក្រុមជំនុំថ្មី សំរាប់ពេល អនាគត ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

តើពួកអ្នកដែលអាចក្លាយជាអ្នកដឹកនាំបានចូលរួមក្នុងសកម្មភាព
អ្វីខ្លះ ?

_____

_____

តើក្រុមជំនុំថ្មីមានសមាជិកប៉ុន្មាននាក់ហើយ សព្វថ្ងៃនេះ ?

_____

សម្លេចអំពីគោលដៅ :

ណែនាំក្រុមជំនុំថ្មីអោយបន្តផ្សាយដំណឹងល្អដល់អ្នកឯទៀត ។

«ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុង ក្រុមរបស់គេជារៀងរាល់ថ្ងៃ » ។ (កិច្ចការ ២:៤៧)

BETA VERSION released prior to proofreading

សូមពិនិត្យមើលសកម្មភាពទាំងដប់ពីរ ហើយចាប់ផ្តើមធ្វើសកម្មភាពទាំង
នេះ តាមលំដាប់លំដោយ ស្របទៅតាមសេចក្តីត្រូវការរបស់អ្នក ។
ផ្នែកទូទៅនៃកិច្ចការឃ្វាលរបស់អ្នកនឹងកំណត់អោយអ្នកធ្វើសកម្មភាព
ចំនួនប៉ុន្មាន និង សកម្មភាពអ្វីខ្លះ ។ អ្នកអាចធ្វើសកម្មភាពពីរបី
ក្នុងពេលជាមួយគ្នា (ព្រមជាមួយគ្នា)បាន ។

នៅពេលដែលក្រុមជំនុំថ្មីចាប់ផ្តើមធ្វើតាមសកម្មភាពមួយហើយ ត្រូវជួយ
ក្រុមជំនុំនោះអោយបន្តធ្វើសកម្មភាពនេះបន្តទៅទៀត ។ ពេលចាប់ផ្តើម
សកម្មភាពមួយទៀត ក៏សូមកុំឈប់សកម្មភាពដែលកំពុងធ្វើដែរ ។

មានវិធីច្រើនណាស់សំរាប់បង្កើតក្រុមជំនុំ ។ វិធីដែលអ្នកប្រើ ត្រូវ
អោយត្រូវនឹងប្រភេទក្រុមជំនុំ ដែលអ្នកចាប់ផ្តើម វប្បធម៌របស់ទីកន្លែង
ធនធានដែលអាចរកបាន និង កត្តាផ្សេងៗទៀត ។ សៀវភៅណែនាំនេះ
ចែកចាយអំពីគោលការណ៍ សកម្មភាពចំនួន ១២
សំរាប់បង្កើតក្រុមជំនុំ ។ វិធីទាំងឡាយសុទ្ធតែផ្សេងៗគ្នា ប៉ុន្តែ
វិធីទាំងអស់ត្រូវអនុវត្តតាមគោល ការណ៍ទាំងឡាយរបស់សម្ពន្ធមេត្រីថ្មី ។



ចំពោះសកម្មភាពនិមួយៗ សូមបញ្ជាក់ពីពេលរៀបចំផែនការ និងពេលចាប់ផ្តើមធ្វើការងាររបស់ផែនការនោះ ។ បើសកម្មភាពណាមួយមិនទាក់ទងនឹងភារកិច្ចបង្កើតក្រុមជំនុំរបស់អ្នកទេ សូមគ្រាន់តែសរសេរកំណត់ចំណាំថា មិនទាក់ទងនឹងភារកិច្ចរបស់អ្នកទេ ។

BETA VERSION released prior to proofreading



បើធ្វើរបៀបនេះ ក្រុមជំនុំថ្មីៗនឹងកើនចំនួនឡើងភ្លាមៗ ។ បើអ្នករង់ចាំយូរពេក ក្រុមជំនុំថ្មីនឹងបាត់បង់ទឹកចិត្តចង់ផ្សាយដំណឹងល្អ ។ ខិតខំបង្កើតក្រុមជំនុំថ្មីជាច្រើន នៅក្នុងកន្លែងតែមួយ ។ នៅពេលដែលបង្កើតក្រុមជំនុំថ្មីនៅកន្លែងផ្សេង ពួកអ្នកដែលបំពេញកិច្ចការបំរើនៅទីនោះ ត្រូវប្រើប្រាស់ «សៀវភៅណែនាំអំពីការបង្កើតក្រុមជំនុំ» នេះមួយទៀត ។ ពួកគេត្រូវប្រាប់អ្នកអោយដឹងពីការរីកចំរើនរបស់ពួកគេ ដូចដែលអ្នកបានជំរាបអ្នកណែនាំ (ទីប្រឹក្សា)របស់អ្នកដែរ ។

- ជួយពួកអ្នកដែលអាចក្លាយជាពួកអ្នកដឹកនាំរបស់ក្រុមជំនុំថ្មី អោយចេះបង្រៀនអ្នកជឿឯទៀតពីរបៀបប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ រៀបចំផែនការសំរាប់ការប្រជុំ ដឹកនាំការប្រជុំ និង ជួយធ្វើពិធីជ្រមុជទឹកអោយអ្នកជឿថ្មី ។ល។ ។

BETA VERSION released prior to proofreading

តើអ្នកអាចប្រើសៀវភៅណែនាំនេះ ដើម្បីបង្កើតក្រុមជំនុំនៅក្នុងស្ថានភាពបែបណា ?

សៀវភៅណែនាំនេះ សំរាប់ជួយអ្នកក្នុងការបង្កើតក្រុមជំនុំថ្មី នៅក្នុងស្ថានភាពច្រើនបែប :

- នៅក្នុងរង្វង់វប្បធម៌របស់អ្នកផ្ទាល់ (ក្នុងចំណោមជាតិ សាសន៍របស់អ្នកផ្ទាល់) ។

- ក្នុងចំណោមប្រជាជន ដែលមានភាសាផ្សេង ជាតិសាសន៍ផ្សេង ឬ វប្បធម៌ផ្សេងពីអ្នក ។ (នេះជាស្ថានភាពរបស់គ្រីស្តទូត) ។

  កំណត់ចំណាំ :
  បើសមាជិកក្រុមបង្កើតក្រុមជំនុំរបស់អ្នកមានសញ្ជាតិ វប្បធម៌ និង ភាសាផ្សេងពីពួកមនុស្ស ដែលអ្នកមានផែនការបង្កើតក្រុមជំនុំ ក្នុងចំណោមពួកគេ អ្នកអាចបង្ហាត់បង្រៀនក្រុមបង្កើតក្រុមជំនុំរបស់អ្នក ដោយក្លូនសៀវភៅលេខ ៥៥ «សៀវភៅសំរាប់គ្រីស្តទូត » ។

- នៅក្នុងកន្លែងដែលក្រុមជំនុំធ្លាក់ចុះអន់ខ្សោយ ហើយត្រូវការចាប់ផ្តើមជាថ្មី ។

- សូមសំរួលសៀវភៅណែនាំនេះ ទៅតាមស្ថានភាពអ្នកផ្ទាល់ ។ សូមបង្ហាញពីអំណោយទានរបស់អ្នក ក្នុងការបង្កើតក្រុមជំនុំ នៅក្នុងរង្វង់វប្បធម៌របស់អ្នកផ្ទាល់សិន សឹមទៅបង្កើតក្រុមជំនុំ នៅក្នុងរង្វង់វប្បធម៌ផ្សេងណាមួយទៀត ។



BETA VERSION released prior to proofreading

- សរសេរឈ្មោះពួកអ្នកដែលអាចក្លាយជាអ្នកដឹកនាំរបស់ ក្រុមជំនុំថ្មី ដែលផ្សាយដំណឹងល្អដល់មិត្តភ័ក្តិ សាច់ញាតិ និង អ្នកជិតខាងរបស់គេ :

  បង្ហាត់បង្រៀនពួកអ្នកដែលអាចក្លាយជាអ្នកដឹកនាំទាំងនោះ អោយចេះទទួលខុសត្រូវលើក្រុមជំនុំថ្មី ។ ដើម្បីអាចដឹងពត៌មានកាន់តែច្រើន សូមមើលគោលការណ៍ណែនាំ ទី ១២ « ចាប់ផ្តើមបង្ហាត់បង្រៀនអ្នកដឹកនាំ» ។

- លើកទឹកចិត្តពួកអ្នកដែលក្លាយជាអ្នកដឹកនាំ អោយបង្កើតគំនិតរបស់ពួកគេផ្ទាល់ សំរាប់ផ្សាយដំណឹងល្អដល់អ្នកដទៃ ដូចជាសំដែងល្ខោនខ្លីៗ និទានរឿង ។ល។ ។

  តើពួកអ្នកដែលអាចក្លាយជាអ្នកដឹកនាំរបស់ក្រុមជំនុំថ្មី បានបង្កើតនិង ប្រើវិធីផ្សាយដំណឹងល្អអ្វីខ្លះ ?

- ជួយពួកអ្នកជឿថ្មីអោយអាចនាំមិត្តភ័ក្តិ និង សាច់ញាតិរបស់ពួកគេដែលនៅកន្លែងផ្សេងៗ ដូចជាភូមិ ខេត្ត ក្រុង ។ល។ មកទទួលជឿព្រះយេស៊ូគ្រីស្ត ។

- សូមអោយពួកអ្នកជឿថ្មីកត់ឈ្មោះមិត្តភ័ក្តិ និង សាច់ញាតិ របស់គេ ហើយអធិស្ឋានទូលសូមអោយអ្នកទាំងនោះ ទទួល ជឿ និង ថ្វាយខ្លួនទៅព្រះអម្ចាស់ ។

  ពន្យល់ថា សូម្បីតែមនុស្សអាក្រក់បំផុត ក៏ឫទ្ធានុភាព និង សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់អាចផ្លាស់ប្តូរគេបានដែរ សាច់ញាតិដែលរស់នៅក្នុងទីកន្លែងផ្សេងៗ អាចធ្វើជាស្ពាន សំរាប់ការបង្កើតក្រុមជំនុំថ្មីៗទៀត ។

- អញ្ជើញពួកអ្នកជឿថ្មី ជាពិសេសអ្នកដែលអាចក្លាយជាអ្នក ដឹកនាំ អោយទៅជាមួយអ្នកបង្កើតក្រុមជំនុំ ពេលពួកគេ ទៅផ្សាយដំណឹងល្អ ដើម្បីឱ្យពួកអ្នកជឿថ្មីអាចរៀនផ្សាយ ដំណឹងល្អ តាមគំរូពួកអ្នកបង្កើតក្រុមជំនុំ ។

  ពួកអ្នកជឿថ្មីរបស់ក្រុមជំនុំថ្មី ត្រូវផ្សាយដំណឹងល្អដល់ក្រុមគ្រួសារ មិត្តភ័ក្តិពួកគេមុនគេ ។ ពួកគេអាចប្រើមេរៀន«ដំណឹងល្អបំផុត» ឬ វិធីផ្សេងទៀតដែលសាមញ្ញ ។ ក្រុមជំនុំថ្មីជាកំឡាំងផ្សព្វផ្សាយ ដំណឹងល្អប្រកបដោយឫទ្ធានុភាព ពីព្រោះព្រះជាម្ចាស់ប្រើប្រាស់ ទឹកចិត្តពុះពារ និង ជីវិតផ្លាស់ប្រែរបស់ពួកអ្នកជឿថ្មី ដើម្បី ទាក់ទាញមនុស្សឯទៀត ។

BETA VERSION released prior to proofreading



តើត្រូវប្រើរយៈពេលប៉ុន្មាន ដើម្បីបង្កើតក្រុមជំនុំមួយ ?

រយៈពេលនៃការបង្កើតក្រុមជំនុំ ទាក់ទងនឹងស្ថានភាពរបស់អ្នក ផ្ទាល់ ។ បើអ្នកធ្វើការនៅក្នុងរង្វង់វប្បធម៌របស់អ្នក ហើយមាន អ្នកជំនួយជាអ្នកដែលអាចនឹងក្លាយជាអ្នកដឹកនាំរបស់ក្រុមជំនុំថ្មី នោះអ្នកអាចបង្កើតក្រុមជំនុំ ដោយធ្វើតាមសៀវភៅណែនាំនេះ ក្នុងរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ ។ បើសិនជាអ្នកធ្វើការក្នុង រង្វង់វប្បធម៌ផ្សេង ហើយនៅក្នុងក្រុមរបស់អ្នក គ្មានអ្នកជំនួយ ជាជនជាតិនៃវប្បធម៌នោះ ដែលអាចក្លាយជាអ្នកដឹកនាំទេ អ្នក ត្រូវប្រើរយៈពេលយូរ ដើម្បីរៀនភាសារបស់គេរហូតដល់ចេះ និយាយអោយត្រូវទៅតាមចិត្តគំនិត និង ស្ថានភាពរបស់ជនជាតិ នោះ ។ មួយវិញទៀត អ្នកត្រូវប្រើរយៈពេលយូរ ដើម្បីធ្វើអោយ មានការទុកចិត្តគ្នាទៅវិញទៅមក ។

ការរីកចំរើនរបស់ក្រុមជំនុំ និង ការបង្កើនចំនួនបន្ត

សៀវភៅណែនាំនេះ ទាក់ទងតែនឹងការចាប់ផ្តើមក្រុមជំនុំថ្មីតែ ប៉ុណ្ណោះ ។ បន្ទាប់មក ក្រុមជំនុំត្រូវរីកចំរើន មានភាពចាស់ទុំ ខាងព្រលឹងវិញ្ញាណ និង បង្កើនចំនួនបន្ត ។

BETA VERSION released prior to proofreading

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានទូលសូមឱ្យក្រុមជំនុំថ្មីខំប្រឹង-ប្រែងផ្សាយដំណឹងល្អដល់អ្នកឯទៀត និង ជំរាបក្រុមអធិស្ឋាន អំពីសំណូមពរអធិស្ឋានផ្សេងៗទៀត) ។

«ព្រះអង្គមានបន្ទូលទៅគេថា÷ "សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំង អ្នកអោយនេសាទមនុស្សវិញ" » ។ (ម៉ាថាយ ៤:១៩)

យោបល់សំរាប់ណែនាំប្រមូលពួកសមាជិកថ្មីរបស់ក្រុមជំនុំថ្មី អោយផ្សាយដំណឹងល្អដល់អ្នកឯទៀត :

- បង្រៀនអំពីមហាបណ្តាំ ដែលក្នុងដំណឹងល្អម៉ាថាយ ២៨:១៨-២០ ដល់ពួកអ្នកជឿថ្មី ។

  ជាពិសេស បង្រៀនពួកអ្នកដែលអាចក្លាយជាអ្នកដឹកនាំអំពីការ ផ្សាយដំណឹងល្អដល់អ្នកឯទៀត និង ការបង្កើតសាវ័ក ។ ពួកគេ ត្រូវយល់ពីគោលដៅ និង សារៈសំខាន់នៃការផ្សាយដំណឹងល្អ ។

គោលការណ៍ ទី ១១
បណ្តុះបណ្តាលសមាជិកនៃក្រុមជំនុំថ្មី អោយផ្សាយដំណឹងល្អ



គោលដៅ :

- បង្រៀន និង ណែនាំអ្នកជឿថ្មីអោយផ្សព្វផ្សាយដំណឹងល្អ ដល់សាច់ញាតិ មិត្តភ័ក្តិ និង មនុស្សឯទៀតនៅក្នុងសហ- គមន៍ និង មនុស្សឯទៀតដែលនៅជុំវិញភូមិ ឬ ក្រុង ។

☐ រៀបចំផែនការរួចហើយ ។

☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

BETA VERSION released prior to proofreading

ការបង្កើតក្រុមជំនុំ

សូមប្រើ « សៀវភៅណែនាំ
អំពីការបង្កើតក្រុមជំនុំ » នេះ ។



ក្រុមជំនុំថ្មីរីកចំរើន ហើយអ្នកដឹកនាំ
បានទទួលការហាត់រៀន

ដើម្បីបង្ហាត់បង្រៀនអ្នកដឹកនាំរបស់ក្រុមជំនុំថ្មី
សូមប្រើ « សៀវភៅសំរាប់បង្ហាត់
បង្រៀននិស្សិតគ្រូគង្វាល » « សៀវភៅ
ណែនាំសកម្មភាពនិស្សិតគ្រូគង្វាល »
និង « កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល » ។



ក្រុមជំនុំមានភាពចាស់ទុំ ហើយបង្កើត
បានក្រុមជំនុំសាខា



ក្រុមជំនុំបានបង្កើនចំនួនបន្ត





BETA VERSION released prior to proofreading

- កម្មវិធីថ្វាយបង្គំជាសាធារណៈដូចនេះ ទាក់ទាញសមាជិករបស់ក្រុមជំនុំផ្សេងទៀត ដែលមានរបៀបគិតគូរ និង ធ្វើសកម្មភាពផ្សេងៗដែរ ។ ការនេះនាំអោយមានមតិផ្សេងគ្នាក្នុងក្រុមជំនុំថ្មី ដែលពួកអ្នកអាចក្លាយជាអ្នកដឹកនាំមូលដ្ឋានមើលឃើញថា ពិបាកដោះស្រាយ ។ ដើម្បីរក្សាសណ្តាប់ធ្នាប់ក្នុងក្រុមជំនុំ ពួកអ្នកបង្កើតក្រុមជំនុំត្រូវបង្ខំចិត្តត្រួតពិនិត្យក្រុមជំនុំខ្លាំងពេក ។

សង្ខេបអំពីគោលដៅ :

ធ្វើការប្រជុំថ្វាយបង្គំ ស្របតាមវប្បធម៌មូលដ្ឋាន ដែលនាំអោយពួកអ្នកជឿរបស់ក្រុមជំនុំនេះអាចបង្ហាញការថ្វាយបង្គំ និង ជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់ ។

«ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និង ដោយចិត្តស្មោះសរផង ។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា ។ ព្រះអម្ចាស់បន្ថែមចំនួនអ្នក ដែលព្រះអង្គបាន សង្គ្រោះមកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ » ។ (កិច្ចការ ២:៤៦-៤៧)

- ការប្រជុំថ្វាយបង្គំជាសាធារណៈ តម្រូវអោយពួកអ្នកក្រៅសហគមន៍ទទួលបន្ទុកដឹកនាំការប្រជុំថ្វាយបង្គំសិន ពីព្រោះពួកអ្នកដឹកនាំមូលដ្ឋាន មិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ ។ ការធ្វើដូចនេះ រាំងស្ទះមិនអោយពួកអ្នកដឹកនាំមូលដ្ឋានទាំងនោះចូលរួម និង រីកចំរើនឡើង ។

- លែងសូវរវល់ផ្សាយដំណឹងល្អទៀត ព្រោះគ្រីស្តជនអ្នកបំរើត្រូវចំណាយពេលទាំងអស់របស់គេ សំរាប់រៀបចំការប្រជុំថ្វាយបង្គំ ហើយគេពឹងលើការប្រជុំថ្វាយបង្គំទាក់ទាញមនុស្សថ្មីមកចូលរួមទៅវិញ ។

- ក្រុមជំនុំថ្មីចាប់ផ្តើមប្រកួតប្រជែងជាមួយក្រុមជំនុំចាស់ជាង និងធ្វើតាមតែរបៀបថ្វាយបង្គំស្មុគ្រស្មាញរបស់ក្រុមជំនុំ ទាំងនោះ ។ (ក្រុមជំនុំគួរតែបង្កើតរបៀបថ្វាយបង្គំរបស់ ខ្លួនផ្ទាល់ ក្នុងបរិយាកាសប្រកបដោយមិត្តភាព ដែលសមរម្យសំរាប់ក្រុមតូចៗជាងទៅវិញទេ) ។

- កម្មវិធីថ្វាយបង្គំមានរយៈពេលយូរពេក ដោយសារក្រុមជំនុំថ្មីចង់រៀបចំកម្មវិធីថ្វាយបង្គំ អោយពេញចិត្តពួកអ្នកជឿចាស់ទុំខាងព្រលឹងវិញ្ញាណ ដែលមកពីក្រុមជំនុំផ្សេងៗទៀត ។ តែពួកអ្នកជឿថ្មីភាគច្រើន មិនទាន់ត្រៀមខ្លួនអាចទទួលកម្មវិធីថ្វាយបង្គំដូចនេះនៅឡើយទេ ។

BETA VERSION released prior to proofreading

គោលការណ៍ណែនាំ ទី ១
អធិស្ឋាន និង រៀបចំផែនការ



គោលដៅ :

- អធិស្ឋាន និង រៀបចំផែនការអំពីទីកន្លែងបង្កើតក្រុមជំនុំ និង អំពីវិធីដែលត្រូវប្រើសំរាប់បង្កើតក្រុមជំនុំ ដោយគិតអំពីការបង្កើតក្រុមជំនុំបន្ត ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

ពេលដែលបង្កើតក្រុមជំនុំ ត្រូវអធិស្ឋានគ្រប់ដំណាក់ការ ហើយ
សូមអោយអ្នកឯទៀតអធិស្ឋានដែរ ។

កិច្ចការសំខាន់ដែលយើងត្រូវធ្វើនៅពេលនេះ គឺរៀបចំផែនការអំពី
ទីកន្លែងបង្កើតក្រុមជំនុំ និង ប្រភេទក្រុមជំនុំដែលយើងនឹងចាប់ ផ្តើម ។
ប្រភេទក្រុមជំនុំដែលអ្នកនឹងបង្កើត ទាក់ទងនឹងធនធាន ដែលមាន
កាលៈទេសៈពិសេសនៃទីកន្លែងបង្កើតក្រុមជំនុំ ចំនួន ប្រជាជននៅទីនោះ
មធ្យោបាយដឹកបញ្ជូនដែលអាចរកបាន ការ យល់ឃើញរបស់អ្នកអំពីក្រុមជំនុំ
និង របៀបដែលព្រះអម្ចាស់ដឹក នាំអ្នក ពេលអ្នកអធិស្ឋាន ។

ព្រះអម្ចាស់យេស៊ូតែងតែអធិស្ឋាន មុននឹងចេញទៅកន្លែងថ្មីៗ ។
(ម៉ាកុស ១:៣៥-៣៩)

ព្រះអម្ចាស់បើកសំដែងបង្ហាញផែនការរបស់ព្រះអង្គប្រាប់លោក ពេត្រុស
ពេលដែលលោកពេត្រុសអធិស្ឋាន ។ (កិច្ចការ ១០:៩-១៦)

ដូចគ្នានេះដែរ យើងអធិស្ឋានទូលសូមអោយព្រះជាម្ចាស់ដឹកនាំ
និង ប្រទានចេស្តារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រោះមានតែព្រះជា-
ម្ចាស់ប៉ុណ្ណោះ ដែលអាចបង្កើតក្រុមជំនុំ និង ធ្វើអោយក្រុមជំនុំ រីកចំរើន
ព្រមទាំងកើនចំនួនបន្តបាន ។

BETA VERSION released prior to proofreading

- តាមធម្មតា បើ «អ្នកមកពីក្រៅសហគមន៍» (អ្នកដែលមាន
  វប្បធម៌មួយផ្សេង) នៅដឹកនាំការប្រជុំនុំថ្វាយបង្គំនៅឡើយ
  គួរកុំអាលអញ្ជើញមនុស្សទូទៅអោយចូលរួមក្នុងការប្រជុំ
  ថ្វាយបង្គំ ទើបប្រសើរជាង ។

- រៀបចំពួកអ្នកដឹកនាំដែលរស់ក្នុងសហគមន៍ អោយបានឆាប់ បំផុត
  តាមដែលអាចធ្វើទៅបាន ។

  ក្រុមជំនុំជាច្រើនបរាជ័យ ព្រោះឆាប់ធ្វើការប្រជុំថ្វាយបង្គំជាសា-
  ធារណៈពេក ។ អ្នកបង្កើតក្រុមជំនុំត្រូវរង់ចាំរហូតទាល់តែបាន
  រៀបចំពួកអ្នកដឹកនាំថ្មី ដែលនៅក្នុងសហគមន៍ អោយអាចដឹកនាំ
  ការថ្វាយបង្គំ ។ (លើកលែងតែករណីដែលអ្នកបង្កើតក្រុមជំនុំ
  នៅធ្វើជាគ្រូគង្វាលប្រចាំរបស់ក្រុមជំនុំថ្មីនោះ) ។ ការបង្ហាត់
  បង្រៀនពួកអ្នកដឹកនាំថ្មី នឹងមានពន្យល់ក្នុងគោលការណ៍ណែនាំ ទី ១២ ។

  សូមពិចារណាអំពីគ្រោះថ្នាក់ដូចតទៅនេះ ដែលបណ្តាលពីការ
  ចាប់ផ្តើមការប្រជុំថ្វាយបង្គំជាសាធារណៈ ដែលគ្មានពួកអ្នកដឹកនាំ
  ដែលនៅក្នុងសហគមន៍ ដែលបានទទួលការបណ្តុះបណ្តាលអោយ
  អាចដឹកនាំកាថ្វាយបង្គំនោះ :

  - មេគ្រួសារ តាមធម្មតា មិនចូលរួមទេ ។ ច្រើនតែស្ត្រី ក្មេងៗ និង
    អ្នកដែលចង់ដឹងប៉ុណ្ណោះ ដែលចូលរួម ។

យោបល់សំរាប់ការអញ្ជើញ មនុស្សជាទូទៅអោយចូលរួមថ្វាយបង្គំ :



BETA VERSION released prior to proofreading

យោបល់អំពីសកម្មភាពអធិស្ឋាន

- រកមនុស្សនៅក្នុងក្រុមជំនុំម្តាយ ដែលព្រមចូលរួមជាក្រុមអធិស្ឋានពិសេស ។

សូមអោយពួកគេអធិស្ឋាន សំរាប់សមាជិកក្រុមដែលបង្កើតក្រុម ជំនុំថ្មី និង សំរាប់ពួកអ្នកជឿថ្មី ។ សូមជំរាបក្រុមអធិស្ឋាននេះ អំពីសំណូមពរអធិស្ឋាននៅដំណាក់ការនិមួយៗនៃការបង្កើត ក្រុមជំនុំ ។

- សូមរអធិស្ឋាន និង ស្វែងរកការដឹកនាំរបស់ព្រះជាម្ចាស់ពេលដែលអ្នកពិចារណាពីការបង្កើតក្រុមជំនុំ ។

អេភេសូ ៦:១៨ លើកទឹកចិត្តយើងអោយអធិស្ឋានច្រើន និងជាទៀងទាត់ : «ចូរអធិស្ឋានគ្រប់ពេលវេលាតាមការណែនាំរបស់ព្រះវិញ្ញាណ ដោយប្រើទាំងពាក្យអធិស្ឋានទាំងពាក្យអង្វរគ្រប់យ៉ាង...» ។

- រៀបចំទៅមើលទីកន្លែង ដែលអ្នកប្រហែលជានឹងបង្កើតក្រុមជំនុំថ្មី ។

ពេលអ្នកដើរមើលទីកន្លែង ត្រូវអធិស្ឋានក្នុងចិត្ត ។ នៅពេលអនាគត ពេលដែលអ្នកបានបង្កើតក្រុមមួយហើយ សូមដឹកនាំ

ពួកគេអោយអធិស្ឋានអំពីអ្វីៗដែលអ្នកសង្កេតឃើញ ដូចជាបញ្ហាមនុស្សសំខាន់ៗដែលនៅក្នុងទីកន្លែងនោះ ។ល។ ។ សូមជ្រើសយកកន្លែងមួយសំរាប់បង្កើតក្រុមជំនុំ ដែលមានមិត្តភ័ក្តិ ឬ សាច់ញាតិរបស់អ្នកជឿ ឬ មានគ្រីស្តជនដែលចង់បានក្រុមជំនុំ ។

យោបល់អំពីសកម្មភាព ដែលណែនាំអោយជ្រើសរើសរបៀបបង្កើតក្រុមជំនុំ :

- សិក្សាខព្រះគម្ពីរទាំងនេះ ដែលបង្ហាញពីគោលការណ៍ណែនាំអំពីការបង្កើតក្រុមជំនុំ :

កិច្ចការ ១៣:១-៣, ម៉ាថាយ ២៨:១៨-២០, ម៉ាកុស ៤:១-៣២, រ៉ូម ១០:១២-១៨, រ៉ូម ១៥:២០-២១ ។ អេភេសូ ៤:១១-១៦ បង្ហាញថានៅគ្រប់ក្រុមជំនុំត្រូវមាន «ពួកសាវក» ដែលមានតួនាទី «ចេញទៅ» ធ្វើអោយការនិមិត្តឃើញឆេះឆួល ឡើង និង ដឹកនាំការងារ ។

- សំរេចចិត្តអំពីរបៀបបង្កើតក្រុមជំនុំទូទៅរបស់អ្នក ។ យើងនឹងពិនិត្យមើលរបៀបខ្លះ ដែលគេតែងតែយកមកប្រើ :

១- ក្រុមអ្នកជឿចាស់ទុំខាងព្រលឹងវិញ្ញាណ ដែលមានសមាជិកចំនួន៤០នាក់ ឬ លើសពីនេះ ចាកចេញពីក្រុមជំនុំម្តាយ

BETA VERSION released prior to proofreading

- អោយពួកអ្នកដែលអាចក្លាយជាអ្នកដឹកនាំ ដឹកនាំកម្មវិធីថ្វាយបង្គំ ។ បន្ថែមភារៈកិច្ចអោយពួកគេទទួលខុសត្រូវអោយបានបន្តិចម្តងៗ ពេលដែលពួកគេកាន់តែមាន បទពិសោធន៍ ។



- ធ្វើសកម្មភាពមួយសំរាប់កុមារ ដែលគួរទុកជាផ្នែកមួយរបស់កម្មវិធីថ្វាយបង្គំដែរ ។

  ឧទាហរណ៍អំពីសកម្មភាពសំរាប់កុមារ គឺនិទានរឿងរបស់ព្រះគម្ពីរ ។ កុមារៗត្រូវដឹងថា ពួកគេជាសមាជិករបស់ក្រុមជំនុំ ថ្មីដែរ ។

- **មានពេលពិសេសសំរាប់ធ្វើអោយមានមេត្រីភាព ។**

  ពួកអ្នកជឿថ្មីត្រូវដឹងថា ពួកគេជាសមាជិករបស់សហគមន៍មួយ ដែលប្តេជ្ញាបំពេញគោលដៅរួមមួយ) ។

យោបល់សំរាប់រំាយតំលៃប្រសិទ្ធិភាព (លទ្ធផល)របស់ការប្រជុំថ្វាយបង្គំ :

- ក្រោយការថ្វាយបង្គំ សំរេចចិត្តពីកិច្ចការ(សកម្មភាព)ដែលត្រូវធ្វើអោយកាន់តែប្រសើរឡើង ។ (តើកិច្ចការណាដែលបំពេញបានល្អ និង កិច្ចការណាដែលបំពេញមិនបានល្អ ?)

- នៅក្នុងរបៀបថ្វាយបង្គំ ផ្លាស់ប្តូរអ្វីៗដែលត្រូវផ្លាស់ប្តូរ ដើម្បីអោយកាន់តែមានប្រសិទ្ធិភាព ។

BETA VERSION released prior to proofreading

ដើម្បីចាប់ផ្តើមជួបជុំគ្នាថ្វាយបង្គំជាក្រុមជំនុំមួយ នៅក្នុងកន្លែងថ្មីមួយ ។ ដូច្នេះ ក្រុមជំនុំថ្មីចាប់ផ្តើមពីក្រុមអ្នកជឿចាស់ទុំខាងព្រលឹងវិញ្ញាណមួយក្រុម ។

របៀបនេះមានប្រសិទ្ធិភាពជាង នៅទីកន្លែងដែលនៅក្នុង ក្រុងពីព្រោះសមាជិករបស់ក្រុមជំនុំម្តាយ អាចធ្វើដំណើរទៅវិញទៅមកពីក្រុមជំនុំថ្មីបាន ។ តាមធម្មតា ព្រះជាម្ចាស់តែងតែប្រទានពរដល់ក្រុមជំនុំម្តាយ ដែលធ្វើតាមរបៀបនេះដោយបញ្ជូនសមាជិកថ្មី ក្នុងចំនួនពីរឬបីដងជាងចំនួនមនុស្ស ដែលក្រុមជំនុំបានបញ្ជូនអោយចេញទៅចាប់ផ្តើមក្រុមជំនុំថ្មី ។ ឧទាហរណ៍ បើក្រុមជំនុំម្តាយបញ្ជូនសមាជិក ៤០នាក់ឱ្យទៅជួបជុំថ្វាយបង្គំនៅកន្លែងផ្សេង ព្រះជាម្ចាស់ប្រហែលជានឹងប្រទានសមាជិកថ្មីចំនួនពី៨០នាក់ទៅ១២០ នាក់អោយក្រុមជំនុំម្តាយ ។ បើសិនជាអ្នកប្រើរបៀបនេះ សកម្មភាពខ្លះដែលនៅក្នុងសៀវភៅណែនាំនេះ មិនអាចយកមកអនុវត្តជាមួយរបៀបនេះទេ ព្រោះក្រុមស្នូលដំបូងរបស់ក្រុមជំនុំថ្មី មកពីក្រុមជំនុំម្តាយ ។ ពួកគេជាគ្រីស្តជន់ចាស់ទុំខាងព្រលឹងវិញ្ញាណរួចហើយ ។

២- ក្រុមជំនុំម្តាយមួយ ឬ ក្រុមជំនុំមួយចំនួន ដែលរួមគ្នាជាក្រុម បញ្ជូនក្រុមបង្កើតក្រុមជំនុំមួយ អោយទៅបង្កើតក្រុម-ជំនុំនៅកន្លែងថ្មីមួយ ។ ពួកគេអាចរកពួកអ្នកជឿនៅក្នុង

កន្លែងនោះ ដែលមានបំណងចង់បានក្រុមជំនុំ ឬ ពួកគេត្រូវ
ចាប់ផ្តើម ដោយនាំមនុស្សអោយជឿលើព្រះយេស៊ូ ។ នៅ
ពេលដែលបង្កើតក្រុមជំនុំបានហើយ ក្រុមអាចនៅជាមួយ
ក្រុមជំនុំថ្មី ឬ ត្រឡប់មកក្រុមជំនុំម្តាយវិញ ។

៣- នៅកន្លែងដែលគ្មានក្រុមជំនុំម្តាយ ក្រុមបង្កើតក្រុមជំនុំមួយ
ចូលទៅក្នុងកន្លែងនោះ ដើម្បីបង្កើតក្រុមជំនុំថ្មីមួយ ។
ជួនកាល ពួកគ្រីស្តជនអ្នកបំរើទាំងនេះ មកពីវប្បធម៌ ផ្សេងៗ ។

៤- មនុស្សមួយចំនួនរួមគ្នាជាក្រុមស្នូល ដើម្បីបង្កើតក្រុមជំនុំ
តាមផ្ទះ ដូចលោកអាគីឡា និង នាងព្រីស៊ីឡាយោងទៅតាម
កិច្ចការ ១៨ ។ ពេលក្រុមជំនុំតាមផ្ទះនោះមានដំណើរការ
ល្អ មនុស្សខ្លះចេញពីក្រុមតូចតាមផ្ទះនោះ ទៅទីកន្លែង ផ្សេងទៀត
ដើម្បីចាប់ផ្តើមក្រុមតូចតាមផ្ទះថែមទៀត ។

ពួកអ្នកបង្កើតក្រុមជំនុំ ដែលមកពីតំបន់ផ្សេងពីកន្លែងដែលគេចង់
បង្កើតក្រុមជំនុំ ត្រូវទុកពេលគ្រប់គ្រាន់ និង ខំប្រឹងប្រែងសមល្មម
ដើម្បីអាចមានទំនាក់ទំនងល្អនឹងមនុស្សនៅកន្លែងនោះ ព្រមទាំង
រៀនអោយស្គាល់ពីវប្បធម៌មូលដ្ឋាន និង រៀបចំរបៀបបង្កើតក្រុម ជំនុំ
ស្របទៅតាមទីកន្លែងនោះ និង ប្រជាជនដែលត្រូវប្រមូល
ផ្តុំជាក្រុមជំនុំ ។ បើក្រុមបង្កើតក្រុមជំនុំរបស់អ្នកមានសមាជិក
មកពីតំបន់ផ្សេងទាំងអស់ ពួកគេត្រូវចាត់ទុកក្រុមរបស់ពួកគេ

BETA VERSION released prior to proofreading

បង្រៀនតាមរបៀបមួយ ដែលសាមញ្ញ និង ដែលអនាគត
អ្នកដឹកនាំស្រួលធ្វើតាម ។ ចាប់ផ្តើមដោយបង្រៀនអំពីសេចក្តី
បង្គាប់របស់ព្រះគ្រីស្ត (មើលគោលការណ៍ណែនាំ ទី ៩)

- អញ្ជើញក្រុមជំនុំអោយឆ្លើយតបនឹងការបង្រៀនព្រះគម្ពីរ ។

  ពួកគេអាចឆ្លើយតបនឹងដំណឹងល្អ ដោយអធិស្ឋាន ច្រៀង ងើប
  ឈរឡើង ប្រកាសជាសាធារណៈ ឬ ធ្វើរបៀបផ្សេងៗទៀត ។

- ទុកពេលមុន ឬ ក្រោយការថ្វាយបង្គំសំរាប់អោយមនុស្ស
  ទាក់ទងស្គាល់គ្នាទៅវិញទៅមក ជជែកគ្នា និង រៀបចំ
  ផែនការសំរាប់សកម្មភាពទាំងឡាយ ។

សកម្មភាពបន្ថែមសំរាប់បញ្ចូលក្នុងការប្រជំនុំថ្វាយបង្គំ ក្នុងក្រុម ជំនុំថ្មី :

- ដាក់ដង្វាយតាមរបៀប ដែលសមរម្យសំរាប់វប្បធម៌ មូលដ្ឋាន ។

- អ្នកចូលរួមច្រៀងចំរៀងពិសេស ឬ លេងភ្លេងពិសេស ។

អធិស្ឋានសំរាប់ការថ្វាយបង្គំ និង រៀបចំផែនការសំរាប់ការ
ថ្វាយបង្គំអោយបានល្អ ។ អោយពួកអ្នកដែលអាចក្លាយជាអ្នក
ដឹកនាំរបស់ក្រុមជំនុំថ្មី ចូលរួមដែរ ។ ជួយអោយពួកអ្នកជឿ
ថ្មីឃើញថា ពួកគេជាក្រុមជំនុំ មិនមែនគ្រាន់តែជាអ្នកមើលទេ ។

- សារភាបអំពើបាប តាមរយៈការអានខព្រះគម្ពីរ ដែល
  និយាយអំពីការសារភាពអំពើបាប ថែមទាំងអធិស្ឋានជា សាធារណៈ
  ឬ អធិស្ឋានក្នុងចិត្ត ។

- ប្រកាសពីការលើកលែងទោសរបស់ព្រះជាម្ចាស់ដោយប្រើ ខព្រះគម្ពីរ
  ដែលនិយាយពីការលើកលែងទោសរបស់ ព្រះអង្គ ។

- ធ្វើពិធីកាច់នំបុ័ង ។
  (ក្រុមជំនុំជាច្រើនយល់ឃើញថា ពិធីកាច់នំបុ័ងជួយកសាង
  សមាជិកក្រុមជំនុំ បើគេធ្វើពិធីនេះជាផ្នែកសំខាន់មួយរបស់
  កម្មវិធីថ្វាយបង្គំនិមួយៗ) ។

- អធិស្ឋានសំរាប់អ្នកជំងឺ អ្នកខ្វះខាត ជាតិសាសន៍ ។ល។ ។
  (អ្នកអាចដាក់ដៃលើអ្នកជំងឺ) ។

- បង្រៀនមេរៀនខ្លីមួយពីព្រះគម្ពីរ ។

BETA VERSION released prior to proofreading

ជា ក្រុមបណ្តោះអាសន្ន ដូចជា «សំណង់ជំនួយ (រន្ទា)» ជុំវិញ
អាគារដែលគេកំពុងសាងសង់ ។ ព្រោះគេសាងសង់សំណង់ ជំនួយ
សំរាប់មួយរយៈពេលប៉ុណ្ណោះ ។ ហើយពេលដែលអាគារ ដែលគេសាងសង់
បានសាងសង់រួចហើយ គេរុះសំណង់ជំនួយ ជុំវិញចេញហើយ ។
ដូចគ្នានេះដែរ ក្រុមបង្កើតក្រុមជំនុំនឹង
បង្ហាត់បង្រៀនពួកអ្នកដឹកនាំពីក្នុងចំណោមពួកអ្នកជឿថ្មី នៅ កន្លែង
នោះយ៉ាងឆាប់បំផុត រួចទុកអោយអ្នកដឹកនាំទាំងនោះ ធ្វើ កិច្ចការបន្ត ។
បើអ្នកជាអ្នកក្រៅបណ្តោះអាសន្ន អ្នកត្រូវរៀបចំ ពួកអ្នកជឿមូលដ្ឋាន
អោយអាចអនុវត្តការងារជាបន្ត ។

យោបល់អំពីសកម្មភាព ដើម្បីជ្រើសរើស ទីកន្លែងសំរាប់បង្កើតក្រុមជំនុំ :

- រកទីកន្លែងសំរាប់ចាប់ផ្តើមក្រុមជំនុំ នៅកន្លែងដែលមិត្តភ័ក្តិ ឬ
  សាច់ញាតិរបស់សមាជិកក្រុមជំនុំអ្នករស់នៅ ។

  តើមានទីកន្លែងដែលត្រូវការក្រុមជំនុំ ជាទីកន្លែងដែលមានមិត្តភ័ក្តិ ឬ
  សាច់ញាតិរបស់សមាជិកក្រុមជំនុំអ្នករស់នៅ ឬទេ ?

- សូមរើសយកកន្លែងដែលមិនទាន់មានក្រុមជំនុំនៅឡើយ និង មិនទាន់មានអ្នកណាទៅផ្សាយដំណឹងល្អ ប្រកបដោយប្រសិទ្ធិភាពនៅឡើយ ។ លោកប៉ូលផ្សាយដំណឹងល្អជ្រាប់ពួកអ្នកដែលមិនទាន់បានឮដំណឹងល្អនៅឡើយ (រ៉ូម ១៥:២០-២១) ។

  តើក្រុមមនុស្ស ឬ ជនជាតិភាគតិចណា ដែលមិនដែលឮដំណឹងល្អ ឬ មិនទាន់មានក្រុមជំនុំដែលមានប្រសិទ្ធិភាព ?

  _____

  តើនៅទីនោះ មានមនុស្សប៉ុន្មាននាក់រស់នៅ ?

  _____

  តើពួកគេចំនួនប៉ុន្មានភាគរយ ដែលបានស្គាល់ព្រះអម្ចាស់ ហើយ ?

  _____

  តើមនុស្សនៅទីនោះ បើកចិត្តដូចម្តេចទទួលដំណឹងល្អ ?

  _____

BETA VERSION released prior to proofreading

យោបល់សំរាប់ការប្រជុំថ្វាយបង្គំ នៅក្នុងក្រុមជំនុំថ្មី :

(សូមធ្វើតាមលំដាប់ ដែលត្រូវនឹងកាលៈទេសៈ) ។

- មានការចាប់ផ្តើម និង ការបញ្ចប់ច្បាស់លាស់ ។

- ថ្វាយបង្គំព្រះជាម្ចាស់ ដោយចំរៀង និង ការអធិស្ឋាន ។

  ធ្វើយ៉ាងណាអោយពួកអ្នកជឿចេះច្រៀងចំរៀងទាំងឡាយ ។ ដឹកនាំការថ្វាយបង្គំតាមរបៀបមួយ ដែលអ្នកជឿទាំងអស់អាចចូលរួមបាន ។ ជួយអោយម្នាក់ៗអាចចូលរួម ដោយធ្វើទីបន្ទាល់ អានព្រះគម្ពីរ អធិស្ឋាន ឬ ច្រៀងចំរៀង ។ល។ ។ ការធ្វើយ៉ាងនេះជួយពួកគេអោយអាចប្រើអំណោយទានខាងព្រលឹងវិញ្ញាណរបស់ពួកគេ និង ដឹងថាពួកគេជា *«ជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និង ជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់ » (អេភេសូ ២:១៩)* ។

«បងប្អូនអើយ ដូច្នេះ តើត្រូវធ្វើដូចម្តេច ? ។ ពេលបងប្អូនរួម ប្រជុំគ្នា ប្រសិនបើម្នាក់ច្រៀងបទលើកតម្កើងព្រះជាម្ចាស់ ម្នាក់ បង្រៀនម្នាក់ពន្យល់សេចក្តីដែលព្រះជាម្ចាស់សំដែងប្រាប់ ម្នាក់និយាយភាសាចំឡែកអស្ចារ្យ ម្នាក់ទៀតបកប្រែ ត្រូវធ្វើការទាំង អស់នេះដើម្បីកសាងក្រុមជំនុំ, ព្រះសហគមន៍ » ។ (១ កូរិនថូស ១៤:២៦)

- កាលវិភាគរបស់មធ្យោបាយដឹកជញ្ជូនសាធារណៈ ។
- ថ្ងៃបើកផ្សារណាត់ ដែលមនុស្សទៅផ្សារនោះ នៅទីក្រុង ឬ នៅភូមិ ។
- កត្តាផ្សេងៗទៀត :

តើក្រុមជំនុំថ្មីនឹងមានការប្រជុំប្រចាំអាទិត្យសំខាន់ជាងគេ នៅពេលណា ? (ថ្ងៃ និង ម៉ោង)

បើក្រុមជំនុំថ្មីមានការប្រជុំផ្សេងៗទៀត តើការប្រជុំនោះ គេធ្វើនៅពេលណាខ្លះ ?

BETA VERSION released prior to proofreading

- ត្រូវពិចារណាពីមធ្យោបាយធ្វើដំណើរ ។

  តើសហគមន៍ ដែលអ្នកមានផែនការទៅបង្កើតក្រុមជំនុំ ស្ថិតនៅឆ្ងាយគួរសមដែរឬទេ ?

  តើអ្នក និង អ្នកជំនួយឯទៀត ធ្វើដំណើរទៅកន្លែងនោះ ដោយរបៀបណា ?

- ដំបូង បង្កើតក្រុមជំនុំនៅកន្លែងដែលមនុស្សចាប់អារម្មណ៍ និងដំណឹងល្អ ។

  តើទីកន្លែងដែលមនុស្សបង្ហាញថា គេចាប់អារម្មណ៍លើដំណឹងល្អ ស្ថិតនៅឯណា ?

- ពិចារណា និង វាយតំលៃអំពីក្រុមជំនុំដែលមានស្រាប់ នៅក្នុងកន្លែងនោះ ។

តើក្រុមជំនុំទាំងឡាយ ដែលនៅក្នុងទីកន្លែងនោះពិតជាបានផ្សាយដំណឹងល្អដល់មនុស្សឯទៀត និង បង្រៀនពួកគេ ឬក៏ក្រុមជំនុំទាំងនោះគ្រាន់តែជាក្រុមដដែលៗ ដែលមិនរីកចំរើនប៉ុណ្ណោះ ?

តើក្រុមជំនុំទាំងនោះ ប្រើវិធីផ្សាយដំណឹងល្អណាខ្លះ នៅក្នុងទីកន្លែងរបស់គេ ?

តើវិធីផ្សាយដំណឹងល្អនេះមានប្រសិទ្ធិភាពដែរឬទេ ?

BETA VERSION released prior to proofreading

- ជាកន្លែងដែលនៅក្បែផ្ទះអ្នកចូលរួម ។
- ជាកន្លែងដែលទំនេរ ពេលត្រូវការ ។
- ជាកន្លែងដែល ក្រុមជំនុំមានលុយគ្រប់គ្រាន់សំរាប់ថ្លៃជួល ឬ ថែទាំ និង ប្រើប្រាស់ ។
- ជាកន្លែងដែលមនុស្សអាចថ្វាយបង្គំ ដោយសេរី ។
- មានទំហំសមល្មម ។

តើក្រុមជំនុំថ្មីនឹងជួបជុំគ្នានៅឯណា ?

សេចក្តីដែលត្រូវពិចារណា សំរាប់ពេលដែលអ្នកជួបជុំគ្នា :

- ពេលធ្វើការ និង ពេលបាយរបស់អ្នកចូលរួម ។
- ពេលវេលាតាមលំដាប់សំរាប់ការប្រជុំថ្វាយបង្គំ ។

តម្រូវការសំរាប់ទីកន្លែង ដែលក្រុមជំនុំជួបជុំគ្នា :



BETA VERSION released prior to proofreading



បើអ្នកសំរេចចិត្តបង្កើតក្រុមជំនុំថ្មីមួយ នៅក្នុងកន្លែងដែលមានក្រុមជំនុំផ្សេងៗធ្វើកិច្ចការបំរើហើយ សូមបង្ហាញសេចក្តីគោរព និងសេចក្តីស្រឡាញ់ចំពោះពួកគេ កុំលួចសមាជិកពួកគេ ហើយមិនមែនប្រកួតប្រជែងជាមួយពួកគេទេ ។



BETA VERSION released prior to proofreading

មូលហេតុធម្មតា ដែលនាំអោយជួបប្រជុំគ្នា ក្នុងអាគារក្រុមជំនុំ :

- មិនស្រួលមានបន្ទុកធ្ងន់ពេកលើនរណាម្នាក់ ដូចជាមានចំពោះ ម្ចាស់ផ្ទះដែលទទួលខុសត្រូវក្នុងការទទួលភ្ញៀវ ពេល ក្រុមជំនុំជួបជុំតាមផ្ទះ ។
- សមាជិកជាច្រើន អាចប្រមូលផ្តុំគ្នា និង ចូលរួមធ្វើសកម្មភាពផ្សេងៗច្រើនជាង ។
- មានការរំខានតិចជាង ។
- មនុស្សខ្លះចង់ថ្វាយបង្គំ ក្នុងអាគារដែលសំរាប់តែការប្រជុំថ្វាយបង្គំប៉ុណ្ណោះ ។

- ក្រុមជំនុំតាមផ្ទះថ្មីៗ ច្រើនតែនាំអោយអាចចៀសវាងពី «ពួកឆ្កែចចក» បាន ។

- ក្រុមជំនុំតាមផ្ទះថ្មីៗ អាចផ្សព្វផ្សាយដំណឹងល្អដល់មនុស្ស ដែលចៀសវាងពីក្រុមជំនុំ ដែលជួបជុំគ្នានៅក្នុងអាគារជាព្រះវិហារ ។

ការជួបជុំគ្នាតាមផ្ទះ ជាការប្រតិបត្តិមួយរបស់សម្ពន្ធមេត្រីថ្មី (កិច្ចការ ២០:២០, ១ កូរិនថូស ១៦:១៩, កូឡូស ៤:១៥ ភីលេម៉ូន ១:២) ។

អ្នកអាចចាប់ផ្តើមក្រុមជំនុំតាមផ្ទះតូចៗច្រើន ក្នុងពេលតែមួយ ដែលនៅតាមក្រុមជំនុំទាំងនោះ ពួកអ្នកជឿអាចទទួលការថែរក្សាពីអ្នកដឹកនាំ ។

ក្រុមជំនុំតាមផ្ទះទាំងនោះត្រូវខិតខំជួបប្រជុំរួមទាំងអស់គ្នា តាមពេលកំណត់ទៀងទាត់ (ដូចជាមួយខែម្តង) ។

កន្លែងផ្សេងទៀត ដែលអាចធ្វើការប្រជុំ រួមមានសាលារៀន ហាងទំនិញ អាគារសហគមន៍ រោងចក្រ ការិយាល័យ ភោជនីយដ្ឋាន ឬ កណ្តាលវាល នៅពេលដែលមានធាតុ អាកាសល្អ ។

BETA VERSION released prior to proofreading

តើអ្នកជឿលើព្រះយេស៊ូ ដែលរស់នៅក្នុងកន្លែងនោះ អាចជួយអ្នកក្នុងការបង្កើតក្រុមជំនុំដែរឬទេ ?

- បើអ្នកមានផែនការធ្វើការងារនៅក្នុងសហគមន៍មួយផ្សេង ឬ នៅក្នុងសហគមន៍មួយដែលនៅឆ្ងាយ អ្នកត្រូវប្រមូលពត៌មានអំពីសហគមន៍នោះ ។

  សូមនិយាយជាមួយប្រជាជននៅទីនោះ ។ បើអាចធ្វើបាន សូមស្វែងរកពត៌មានពីការិយាល័យជំរឿនប្រជាជនរបស់រដ្ឋាភិបាល ឬ កន្លែងផ្សេងទៀត ដែលផ្តល់ពត៌មានអំពីប្រជាជន ។

សំណួរខ្លះសំរាប់ប្រមូលពត៌មាន :

(មនុស្សដែលទើបនឹងរើមករស់នៅក្នុងសហគមន៍មួយ ច្រើនតែបើកចិត្តទទួលដំណឹងល្អជាង ព្រោះមិត្តភ័ក្តិ និង សាច់ញាតិដែលមិនទាន់ជឿ គ្មានឥទ្ធិពលលើពួកគេទេ) :

តើមានមនុស្សថ្មីច្រើនមករស់នៅក្នុងកន្លែងនោះ (ឧទាហរណ៍ ពួកជនភៀសខ្លួន ។ ល។)ទេ ?

ពួកគេមកពីណា ?

តើមានឧស្សាហកម្មថ្មីចាប់ផ្តើមទេ ?

តើមានគេសង់ផ្ទះថ្មីៗឬទេ ?

(ការដែលល្អ គឺត្រូវគិតពិចារណាពីការងារ និង បញ្ហាក្នុងសង្គម ដែរ) :

តើប្រជាជនភាគច្រើនប្រកបមុខរបរអ្វី ឬ ធ្វើការងារនៅឯណា ?

BETA VERSION released prior to proofreading

បើមានមនុស្សចូលរួមច្រើន អាចជួបជុំគ្នាតាមផ្ទះផ្សេងៗ ព្រមទាំងយូរៗម្តងអាចជួបប្រជុំរួមគ្នាជាក្រុមធំមួយដែរ ។

មូលហេតុធម្មតា ដែលនាំអោយជួបជុំគ្នាតាមផ្ទះ :

- ពួកអ្នកដឹកនាំថ្មី ស្រួលដឹកនាំក្រុមតូចៗជាង ។
- ដង្វាយដែលទទួលបាន អាចយកទៅប្រើសំរាប់តែសេចក្តីត្រូវការផ្សេងៗ ក្រៅពីការជួល ឬ ទិញ ឬ សាងសង់ ។
- ក្រុមជំនុំតាមផ្ទះថ្មីៗ ស្រួលនឹងបង្កើនចំនួនបន្ត និង រីកសាយពេញតំបន់ធំមួយ ។
- ក្រុមជំនុំតាមផ្ទះថ្មីៗ ធ្វើអោយមេត្រីភាពរវាងពួកអ្នកជឿ រីកចំរើនឡើង និង ធ្វើឱ្យពួកអ្នកជឿកាន់តែប្រើអំណោយទានខាងព្រលឹងវិញ្ញាណរបស់ពួកគេក្នុងមុខងារបំរើ ។
- ក្រុមជំនុំតាមផ្ទះថ្មីៗ ធ្វើអោយអ្នកដឹកនាំកាន់តែអាចធ្វើកិច្ចការឃ្វាលខាងថែរក្សាសមាជិកម្នាក់ៗ ដោយផ្ទាល់ ។

ខ្លីៗ ។ល។) សូមចាំជានិច្ចថា ត្រូវប្រើវិធីដែលអ្នកជឹកនាំថ្មី
អាចធ្វើតាមបានដោយស្រួល ។

៨_ បើពួកអ្នកបង្កើតក្រុមជំនុំ មិនមានឥទ្ធិពលទៅលើក្រុមជំនុំ
មូលដ្ឋានទេ តើអ្នកចូលរួមក្រុមជំនុំមូលដ្ឋាន តាមធម្មតា
អធិស្ឋានដោយរបៀបណា (ដោយស្ងៀមស្ងាត់ និយាយឮៗ
លុតជង្គង់ ឈរ ដោយលើកដៃឡើងលើ ។ល។) ?

យោបល់អំពីទីកន្លែង និង ពេលប្រជុំថ្វាយបង្គំ :

- ណែនាំក្រុមជំនុំថ្មីអោយសំរេចចិត្តជ្រើសរើសកន្លែង និង
ពេលសំរាប់អ្នកជួបជុំគ្នា ។

- អធិស្ឋានជាមួយពួកអ្នកជឿថ្មី ដើម្បីទូលសូមអោយ
ព្រះជាម្ចាស់ជឹកនាំ ។

BETA VERSION released prior to proofreading

តើប្រជាជនច្រើនតែមានបញ្ហាអ្វី ?

តើប្រជាជនដែលអ្នកមានផែនការផ្សាយដំណឹងល្អ មានភាព
ជីវភាពទូទៅដូចម្តេច ?

តើមនុស្សធ្វើអ្វីពេលល្ងាច ឬ ពេលមិនធ្វើការងារ ? ដើម្បីអោយ
ដឹងពីការទាំងនោះ អ្នកត្រូវធ្វើការសង្កេតអំពីសហគមន៍នោះ ដោយនិ
យាយជាមួយមនុស្សមួយចំនួន បើអាចធ្វើបានដោយ សុវត្ថិភាព
សុំអោយអ្នកណាម្នាក់ ដែលមានបទពិសោធន៍ អំពីការស្រាវជ្រាវដូចនេះ
ជួយរៀបចំសំនួរទាំងឡាយ

សំរាប់គ្រីស្តទូត ដែលធ្វើកិច្ចការបំរើ នៅក្នុងវប្បធម៌ផ្សេង :

បើសិនជានៅក្នុងកន្លែង ដែលអ្នកផ្សាយដំណឹងល្អ មានក្រុមច្រើន
ដែលមានភាសា និង វប្បធម៌ផ្សេងៗគ្នា សូមជ្រើសយកតែក្រុម
មនុស្សមួយ ដើម្បីចាប់ផ្តើមធ្វើការងារបានហើយ ។ ក្រុមនិមួយៗ
មានរបៀបគិតរបស់គេផ្ទាល់ ហើយដំបូង ពួកគេបើកចិត្តទទួល

ដំណឹងល្អខ្លាំងជាង បើពួកគេជួបប្រជុំជាមួយមនុស្សដែលមាន
វប្បធម៌ដូចគេ ។

តើក្រុមជនជាតិភាគតិចណាខ្លះ ដែលរស់នៅក្នុងកន្លែងនោះ ?

តើពួកគេនិយាយភាសាអ្វី ?

តើអ្នកនឹងចាប់ផ្តើមធ្វើការងារជាមួយក្រុមណា ឬ ភាសាណា ?

ដើម្បីអាចមានទំនាក់ទំនងល្អជាមួយមនុស្សទាំងនោះ ក្រុមបង្កើត
ក្រុមជំនុំរបស់អ្នកត្រូវមានសមាជិកជាគ្រីស្តជនអ្នកបំរើ ដែលចេះ ភាសា
និង វប្បធម៌របស់មនុស្សទាំងនោះ បើអាចមានបាន ។

រៀបចំផែនការសំរាប់ធ្វើអោយក្រុមជំនុំកើនចំនួនបន្ត នៅក្នុង
កន្លែងដែលបានជ្រើសយក និង នៅក្នុងតំបន់ជុំវិញកន្លែងនោះ ។
សូមព្រមព្រៀងគ្នាអំពីគោលដៅសំរាប់រយៈពេលយូររបស់អ្នក ។

BETA VERSION released prior to proofreading

៤- តើបែបបទភ្លេងរបស់ប្រជាជនមូលដ្ឋាន អាចយកទៅប្រើ
សំរាប់លេងជាមួយបទចំរៀងសរសើរតម្កើង ឬ បង្កើត
ចំរៀងថ្វាយបង្គំថ្មីដែរឬទេ ?

៥- តើពួកអ្នកជឿថ្មីពេញចិត្តចំរៀងសរសើរតម្កើងប្រពៃណី ឬ
ចំរៀងថ្វាយបង្គំថ្មីៗជាង ឬ ប្រភេទចំរៀងផ្សេងទៀតជាង ?

៦- តើអ្នកអាចធ្វើអោយសមាជិកទាំងអស់ អាចចូលរួមក្នុងផ្នែក
ផ្សេងៗនៃការប្រជុំថ្វាយបង្គំ ដោយរបៀបណា ?

៧- តើពិធីបង្រៀនណាមួយ ដែលប្រសើរបំផុតសំរាប់ក្រុមតូច
ថ្មីៗមួយ ? (ដូចជា ការសិក្សាព្រះគម្ពីរយ៉ាងខ្លី ការនិទាន
រឿងព្រះគម្ពីរ ការសំដែងរឿងរបស់ព្រះគម្ពីរជារឿងល្ខោន

ក្រុមជំនុំថ្មីជាច្រើន មិនរីកចំរើនទៅមុខដោយសារពួកគេថ្វាយបង្គំ តាមរបៀបដែលសមាជិកថ្មីមើលឃើញថាចម្លែក ។ ដូច្នេះ ត្រូវ បញ្ចូលរបៀបថ្វាយបង្គំ ដែលធ្វើអោយពួកអ្នកជឿថ្មីអាចបង្ហាញ ជំនឿ និង ទឹកចិត្តរបស់ពួកគេខ្លាំងជាងគេ ។ សំនួរទាំងនេះនឹង ជួយអ្នកអោយអាចធ្វើដូចនេះបាន :

១- ពួកអ្នកជឿថ្មីបានចូលរួមក្នុងក្រុមជំនុំប្រភេទណាពីមុន ? (បើគេបានចូល) ។

_____

២- តើពួកអ្នកជឿថ្មីលេងឧបករណ៍ភ្លេងណាខ្លះ ?

_____

៣- តីអាចយកឧបករណ៍ភ្លេងទាំងនោះ មកលេងក្នុងការប្រជុំ ថ្វាយបង្គំដែរឬទេ ?

_____

BETA VERSION released prior to proofreading

យោបល់សំរាប់កំណត់ការនិមិត្តឃើញរបស់អ្នក អំពីការបង្កើតក្រុមជំនុំបន្ត នៅពេលអនាគត :

- គួរផែនទីសាមញ្ញមួយរបស់កន្លែងដែលអ្នកជ្រើសយក ដើម្បីបង្ហាញអំពីការកើនចំនួនបន្តរបស់ក្រុមជំនុំ នៅពេលអនាគត ។

បង្ហាញក្រុមជំនុំម្តាយ រួចគួរព្រួញចេញពីក្រុមជំនុំម្តាយ ទៅរកសហគមន៍ទាំងឡាយ ដែលអ្នកមានផែនការទៅបង្កើតក្រុមជំនុំសាខា ។ សូមសរសេរឈ្មោះអ្នកជំនួយ ដែលមកពីក្រុមជំនុំម្តាយ នៅក្បែរព្រួញទាំងនោះ នៅក្បែឈ្មោះសហគមន៍ថ្មី សូមសរសេរឈ្មោះមនុស្សដែលរស់នៅទីនោះ ដែលអាចជួយបាន ។

- មើលឡើងវិញអំពីឌីយ៉ាក្រាម ដែលបង្ហាញពីដំណើរការបង្កើនចំនួនការបង្ហាត់បង្រៀនពួកអ្នកដឹកនាំ ។

BETA VERSION released prior to proofreading

បង្កើតក្រុមជំនុំបានហើយ និង
បង្ហាត់បង្រៀនពួកអ្នកដឹកនាំហើយ

បង្កើតក្រុមជំនុំបានហើយ និង
បង្ហាត់បង្រៀនពួកអ្នកដឹកនាំហើយ

។ល។ ។



អ្នកដឹកនាំដែលរៀបចំរួចហើយ
ចេញទៅបង្កើតក្រុមជំនុំមួយទៀត

អ្នកដឹកនាំដែលរៀបចំរួចហើយ
ចេញទៅបង្កើតក្រុមជំនុំមួយទៀត

ពួកអ្នកដឹកនាំដែលអ្នកបង្ហាត់បង្រៀន នឹងបង្កើតក្រុមជំនុំ ផ្សេងទៀតខ្លួនគេ
ហើយបង្ហាត់បង្រៀនពួកអ្នកដឹកនាំថ្មីៗទៀត សំរាប់ក្រុមជំនុំទាំងនោះ ។



កុំធ្វើការប្រជុំថ្វាយបង្គំជាគំរូ ឬ
បង្រៀនរបៀបប្រជុំថ្វាយបង្គំរបស់ ក្រុមជំនុំម្តាយ ជាពិសេស
បើក្រុមជំនុំម្តាយជាក្រុមជំនុំធំ ។ ក្រុមជំនុំថ្មីដែលតូច
ត្រូវការរបៀបថ្វាយបង្គំសាមញ្ញ ។

- បើអ្នកធ្វើកិច្ចការបំរើក្នុងវប្បធម៌ផ្សេង ត្រូវធ្វើយ៉ាងណាអោយ
  មនុស្សអាចថ្វាយបង្គំ តាមរបៀបដែលស្របតាមវប្បធម៌
  មូលដ្ឋានរបស់ពួកគេ ។

  របៀបថ្វាយបង្គំរបស់ក្រុមជំនុំវប្បធម៌ផ្សេង អាចខុសពីរបៀប
  ដែលក្រុមបង្កើតក្រុមជំនុំធ្លាប់ប្រើ ។ លោកពេត្រុសត្រូវរៀន
  ផ្លាស់ប្តូរទំលាប់របស់គាត់ ដើម្បីអាចតម្រូវខ្លួនទៅតាមស្ថានភាព
  ថ្មី (កិច្ចការ ១០) ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវធ្វើយ៉ាងណា
  កុំអោយរបៀបថ្វាយបង្គំរបស់ពួកគេផ្ទុយនឹង (មិនតាម)ព្រះបន្ទូល
  ព្រះជាម្ចាស់ ។

  ក្រុមជំនុំដែលរីកចំរើន និង មានដំណើរការល្អ ច្រើនតែនិពន្ធបទ
  ចំរៀងរបស់គេផ្ទាល់ និង បង្កើតរបៀបថ្វាយបង្គំតាមគំនិតផ្តួច
  ផ្តើមរបស់គេផ្ទាល់ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំពួកគេ ។



BETA VERSION released prior to proofreading

- នៅលើផែនទី គួរព្រួញចេញពីក្រុមជំនុំ នៅកន្លែងដែលក្រុមជំនុំទាំងនេះអាចទៅបង្កើតក្រុមជំនុំចៅ និង គួរព្រួញបន្តពីក្រុមជំនុំចៅ ទៅកន្លែងសំរាប់បង្កើតក្រុមជំនុំចៅ ទួតទៀត ។

  ព្រះជាម្ចាស់អាចដឹកនាំអ្នកអោយផ្លាស់ប្តូរផែនការរបស់អ្នក នៅលើផែនទី ឬ បន្ថែមអ្វីៗលំអិតច្រើនទៀត នៅពេលខាងមុខ ។

សង្ខេបអំពីគោលដៅ :

សូមអធិស្ឋាន និង រៀបចំផែនការអំពីទីកន្លែងបង្កើតក្រុមជំនុំមួយ ព្រមទាំងអំពីរបៀបដែលអ្នកត្រូវប្រើ ដើម្បីបង្កើតក្រុមជំនុំនោះ ដោយគិតពិចារណាអំពីការបង្កើតចំនួនក្រុមជំនុំបន្ត ។

«នៅទីបំផុត បងប្អូនអើយ សូមអធិស្ឋានអោយយើងផង ដើម្បីឱ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានផ្សព្វផ្សាយយ៉ាងឆាប់រហ័ស និងបានរុងរឿង ដូចនៅក្នុងចំណោមបងប្អូនដែរ » ។ (២ ថេស្សាឡូនិក ៣:១)

គោលការណ៍ណែនាំ ទី ២
រៀបចំពួកអ្នកបង្កើតក្រុមជំនុំរបស់អ្នក



គោលដៅ :

- រៀបចំក្រុមបង្កើតក្រុមជំនុំរបស់អ្នក ដោយគិតអំពីអំណោយទានខាងព្រលឹងវិញ្ញាណរបស់សមាជិកក្រុមនោះ ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____.

BETA VERSION released prior to proofreading

ពួកអ្នកជឿថ្មីត្រូវយល់ថា ពួកគេទើបជាក្រុមជំនុំថ្មី មិនមែនសមាជិកនៃក្រុមបង្កើតក្រុមជំនុំទេ ។ ក្រុមជំនុំថ្មីត្រូវមានលក្ខណៈផ្ទាល់របស់ខ្លួន ។ បើមិនដូច្នោះទេ ក្រុមជំនុំមូលដ្ឋានថ្មីនឹងមិនអាចចាក់ឫសក្នុងសហគមន៍ និង វប្បធម៌មូលដ្ឋានបានទេ ។

- បង្កើតក្រុមជំនុំថ្មី ដោយរៀបចំពួកអ្នកដឹកនាំមកពីសហគមន៍ដែលអ្នកកំពុងបង្កើតក្រុមជំនុំថ្មី ។

  ការដែលប្រសើរបំផុត គឺបង្កើតក្រុមជំនុំថ្មីមួយ ដោយរៀបចំពួកអ្នកដឹកនាំ ដែលមកពីសហគមន៍នោះ ជាពិសេស ក្នុងកាលៈទេសៈដែលអ្នកជឿថ្មីមានវប្បធម៌ផ្សេងពីវប្បធម៌របស់ពួកអ្នកបង្កើតក្រុមជំនុំ ។ អធិស្ឋានសំរាប់ពួកអ្នកដឹកនាំ ដែលមកពីសហគមន៍ដែលក្រុមបង្កើតក្រុមជំនុំជ្រើសយក ។

- កុំបង្រៀន ឬ ដឹកនាំការប្រជុំតាមរបៀបដែលពួកអ្នកជឿថ្មីមើលឃើញថា ពិបាកធ្វើតាម ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានអោយក្រុមជំនុំថ្មីអាចធ្វើការ
ប្រជុំថ្វាយបង្គំទៀងទាត់ និង ជំរាបក្រុមអធិស្ឋានអំពីសំណូមពរ
អធិស្ឋានផ្សេងៗទៀត) ។

«មិនត្រូវលះបង់ការប្រជុំគ្នានោះឡើយ...» (ហេប្រឺ ១០:២៥)

ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងការថ្វាយបង្គំរបស់យើង បើយើង ថ្វាយបង្គ
ំ ដោយថ្វាយសិរីរុងរឿងទៅព្រះអង្គ ដោយបង្ហាញពី សេចក្តីស្រឡាញ់ និង
ពីទឹកចិត្តអរព្រះគុណ ព្រមទាំងសារភាពថា យើងត្រូវការព្រះអង្គ និង
សារភាពអំពើបាបរបស់យើងផងដែរ ។
ការថ្វាយបង្គំក្នុងឋានៈជារូបកាយក្រុមជំនុំ ជួយអ្នកជឿថ្មីអោយ
រីកចំរើនឡើងខាងព្រលឹងវិញ្ញាណ (កាន់តែមានជំនឿ) ។

យោបល់ទូទៅសំរាប់ការប្រជុំថ្វាយបង្គំ :

- កុំគ្រាន់តែអោយពួកអ្នកជឿថ្មីចូលរួមក្នុងការប្រជុំរបស់ពួកអ្នក
  បង្កើតក្រុមជំនុំ ។

BETA VERSION released prior to proofreading

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ក្រុមបង្កើតក្រុមជំនុំ
ហើយជូនដំណឹងក្រុមអធិស្ឋាននោះអំពីសំណូមពរអធិស្ឋានផ្សេងៗទៀត) ។

ព្រះគ្រីស្ត និង ពួកសាវ័ករបស់ព្រះអង្គ មិនដែលចេញទៅធ្វើការ-
ងារម្នាក់ឯងទេ ។ ពួកសាវ័កព្រះអង្គបង្កើតក្រុមបង្កើតក្រុមជំនុំ
ដែលចេញទៅកន្លែងនានាមួយរយៈពេលៗ ។ ឧទាហរណ៍ លោក
ពេត្រុសចេញទៅផ្សព្វផ្សាយដំណឹងល្អ នៅក្រុងសេសារេជាមួយ
អ្នកជំនួយឯទៀត (កិច្ចការ ១០:២៣) ។ លោកប៉ូល លោក បារណាបាស
និង លោកយ៉ូហាន ហៅម៉ាកុស ចេញពីក្រុង អន់ទីយ៉ូកជាមួយគ្នា ។
ក្រុមបង្កើតក្រុមជំនុំទីមួយ តាមធម្មតា
ធ្វើការផ្សព្វផ្សាយដំណឹងល្អទូលំទូលាយ និង ខ្លាំងក្លានៅក្នុង កន្លែងថ្មី
ដើម្បីបង្កើតក្រុមអ្នកជឿដែលជាក្រុមស្នូល ។ ក្រុម បង្កើតក្រុមជំនុំទីពីរ
តាមធម្មតា ជាពួកអ្នកដែលបង្ហាត់បង្រៀន ពួកអ្នកដឹកនាំថ្មីរបស់ក្រុមជំនុំថ្មី ។

យោបល់ពីសកម្មភាព ដែលសំរាប់
រៀបចំក្រុមបង្កើតក្រុមជំនុំរបស់អ្នក :

- ទូលសូមអោយព្រះអម្ចាស់នៃចម្រូត ចាត់គ្រីស្តជនអ្នកបំរើឱ្យ
  ចេញទៅ ។

សូមអោយក្រុមជំនុំម្តាយរបស់អ្នកអធិស្ឋានទូលសូមឱ្យព្រះជាម្ចាស់ជ្រើសរើស និង រៀបចំគ្រីស្តជនអ្នកបំរើ សំរាប់ធ្វើជាសមាជិកក្រុមបង្កើតក្រុមជំនុំ ។ ព្រះអម្ចាស់យេស៊ូគ្រីស្តបានអធិស្ឋានពេញមួយយប់ មុននឹងជ្រើសរើសសាវ័កខ្លះ អោយដើរតាមព្រះអង្គ (លូកា ៦:១២-១៣) ។

- ប្រមូល និង រៀបចំសមាជិកក្រុម ដែលមានអំណោយទានដែលមានប្រយោជន៍សំរាប់ការបង្កើតក្រុមជំនុំ ។

  អំណោយទានទាំងនោះ រួមមាន : អំណោយទានខាងការបង្កើតសាវ័ក ខាងផ្សព្វផ្សាយដំណឹងល្អ ខាងប្រោសជំងឺ ខាងមានចិត្តមេត្តាករុណា ។ល។ ។ ក្រុមណាដែលមានអំណោយទានផ្សេងៗសហការជាមួយគ្នា នឹងធ្វើការងារបានសំរេចច្រើន ។

- ចៀសវាងកុំអញ្ជើញគ្រីស្តជនអ្នកបំរើដែលគ្រាន់តែចង់អធិប្បាយនៅមុខក្រុមជំនុំថ្មីប៉ុណ្ណោះ ។

  ជំនាញខាងការធ្វើកិច្ចការឃ្វាល និង ការបង្ហាញសេចក្តីស្រឡាញ់ចំពោះមនុស្ស ជាមុខនាទីសំខាន់ជាងការអធិប្បាយនៅមុខគេ ។ សូមពន្យល់សមាជិកក្រុម អំពីភារកិច្ចរបស់ពួកគេ ក្នុងឋានៈពួកគេជាផ្នែកមួយរបស់ក្រុមបង្កើតក្រុមជំនុំ ។ ពេលដែលពួកគេដឹងថាពួកគេនឹងមិនអធិប្បាយនៅក្នុងក្រុមជំនុំថ្មីទេ ពួកគេប្រហែលជា

BETA VERSION released prior to proofreading

«ប្រសិនបើយើងកាន់តាមវិន័យរបស់ព្រះអង្គ នោះទើបយើងដឹងថាយើងបានស្គាល់ព្រះអង្គមែន » ។ (១ យ៉ូហាន ២:៣)

គោលការណ៍ ទី ១០
រៀបចំធ្វើការប្រជុំថ្វាយបង្គំ



គោលដៅ

- ចាបផ្តើមធ្វើការប្រជុំថ្វាយបង្គំទៀងទាត់ តាមរបៀបសាមញ្ញដែលសមាជិក និង អ្នកដឹកនាំរបស់ក្រុមជំនុំថ្មី អាចធ្វើតាមបានដោយងាយស្រួល ។

☐ ឧបត្ថម្ភគ្រីស្តជនអ្នកបំរើ ដែលធ្វើកិច្ចការបំរើនៅក្នុងកន្លែងផ្សេង ឬ ប្រទេសផ្សេង ដែលមិនទាន់មានគេទៅផ្សាយដំណឹងល្អ ។

☐ សេចក្តីផ្សេងៗ : _____

- តែងតាំងហេរញ្ញិកបណ្តោះអាសន្នម្នាក់ និង បង្រៀនគាត់ឱ្យចេះធ្វើសៀវភៅបញ្ជី ចេញបង្កាន់ដៃចំណាយ ។ល។ ។

ឈ្មោះរបស់ហេរញ្ញិក :

_____

សម្លេចអំពីគោលដៅ :

បង្រៀនពួកអ្នកជឿថ្មីអោយប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះ គ្រីស្ត ដូចជា : កែប្រែចិត្តគំនិត ទទួលពិធីជ្រមុជទឹក មាន សេចក្តីស្រឡាញ់ ចូលរួមធ្វើពិធីកាច់នំប៉័ង អធិស្ឋាន អោយ និង បង្កើតសាវ័ក ។

«...ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍...ត្រូវបង្រៀនគេ អោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នក រាល់គ្នា » ។ (ម៉ាថាយ ២៨:១៩-២០)

BETA VERSION released prior to proofreading

និងសំរេចចិត្តលែងធ្វើជាសមាជិកក្រុម តាមចិត្តគំនិតរបស់ពួកគេផ្ទាល់ គឺមិនបាច់បញ្ឈប់ពួកគេទេ ។

- ប្រមូល និង រៀបចំសមាជិកក្រុមដែលប្តេជ្ញាបង្កើតសាវ័ក គឺ សាវ័កដែលអាចប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូ ត្រូវ :

  - កែប្រែចិត្តគំនិត ជឿ និង ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ (យើងត្រូវពន្យល់ដំណឹងល្អព្រះយេស៊ូអោយច្បាស់លាស់ប្រាប់ពួកគេ មុនអ្នកស្តាប់អាចទទួលជឿពិតមែន) ។

  - ទទួលពិធីជ្រមុជទឹក និង មានជីវិតថ្មីវិសុទ្ធដែលយើងត្រូវ មានក្រោយដែលបានទទួលពិធីជ្រមុជទឹក ។

  - កាច់នំប៉័ង និង ជួនជុំគ្នា ដោយសេចក្តីស្រឡាញ់ជាមួយបងប្អូនអ្នកជឿឯទៀត ។

  - មានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និង ចំពោះមនុស្ស ដោយធ្វើពលីកម្ម (ដូចជា ជួយបំរើអ្នកខ្វះខាត) និង អត់ទោសអោយខ្មាំងសត្រូវ ។

- អធិស្ឋានទៀងទាត់

- អោយដោយចិត្តសប្បុរស ។

- បង្កើតសាវ័ក (ផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត ឃ្វាលហ្វូងចៀម បង្ហាត់បង្រៀនពួកអ្នកដឹកនាំ និង ចាត់គ្រីស្តទូតអោយចេញទៅ) ។

- បើអាចធ្វើបាន ត្រូវរកមនុស្សដែលមានវប្បធម៌ និង ប្រវត្តិដូចប្រជាជនដែលអ្នកចង់ផ្សាយដំណឹងល្អប្រាប់ អោយធ្វើជាសមាជិកក្រុមបង្កើតក្រុមជំនុំ ។

  សមាជិកក្រុមបង្កើតក្រុមជំនុំដែលមានវប្បធម៌ និង ប្រវត្តិដូចប្រជាជនដែលអ្នកចង់ផ្សាយដំណឹងល្អប្រាប់ អាចទាក់ទងជាមួយប្រជាជននោះ ប្រកបដោយប្រសិទ្ធិភាពជាង ។

- សរសេរឈ្មោះពួកអ្នក ដែលនឹងធ្វើការងារជាមួយអ្នក អំពីក្រុមបង្កើតក្រុមជំនុំ :

BETA VERSION released prior to proofreading

- បង្រៀនពួកអ្នកជឿថ្មីអោយចេះជួយបំពេញសេចក្តីត្រូវការរបស់អ្នកទៀត ដែលមានទុក្ខលំបាក ដោយចែកចាយអ្វីៗដែលព្រះជាម្ចាស់ប្រទានអោយខ្លួន ។

- ក្នុងឋានៈជាក្រុមជំនុំ អធិស្ឋាន និង សំរេចអំពីរបៀបប្រើប្រាស់ប្រាក់កាស ដែលបានពីដង្វាយដប់ភាគរយ និង ដង្វាយស្ម័គ្រចិត្ត ។

  ពួកអ្នកជឿថ្មីនឹងស្ម័គ្រចិត្តដាក់ដង្វាយច្រើនជាង បើគេដឹងថាប្រាក់ដង្វាយត្រូវយកទៅធ្វើអ្វី ។ រៀបចំថវិកាមួយ ដោយប៉ាន ស្មានអំពីចំនួនប្រាក់ចំណូល និង ដោយព្រមព្រៀងគ្នាអំពីចំនួន ទឹកប្រាក់ដែលត្រូវចំណាយ ។ កត់ត្រាអំពីប្រភេទចំណាយ ដូចជាចំណាយសំរាប់ប្រាក់ខែគ្រូគង្វាល សំរាប់ទិញព្រះគម្ពីរ ទិញកន្ទេល ទិញទឹកបរិសុទ្ធ ។ល។ ។ ក្រុមជំនុំត្រូវផ្តល់បាក់កាស ដើម្បីឧបត្ថម្ភយ៉ាងតិចតំរោងមួយ ឬ សេចក្តីត្រូវការ ដែលមិនមែនជារបស់ក្រុមជំនុំរបស់ខ្លួន ។

  តើក្រុមជំនុំថ្មីបានសំរេចឧបត្ថម្ភគំរោងណាខ្លះ ឬ មនុស្សណាខ្លះ ?

  ☐ ជួយមនុស្សឈឺ ។
  ☐ ទិញសំភារៈសំរាប់ផ្សាយដំណឹងល្អ ។
  ☐ ឧបត្ថម្ភគ្រូគង្វាល ។

- ចែកចាយ និង អោយ ដោយលះបង់ (ម៉ាថាយ ៦:១៩-២១) ។

- បង្កើតសាវ័ក ដែលប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ (ម៉ាថាយ ២៨:១៨-២០, ម៉ាកុស ១៦:១៥) ។

- កត់ឈ្មោះពួកអ្នកជឿថ្មី និង ចាត់តាំងអ្នកថែរក្សាខាងព្រលឹងវិញ្ញាណម្នាក់អោយជួយពួកគេម្នាក់ៗ អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះយេស៊ូ ដែលមានរៀបរាប់នៅទំព័រមុនរួចមកហើយ ។

- បង្រៀនពួកអ្នកជឿថ្មីអំពីរបៀបអធិស្ឋាន ។

  គ្រីស្តជនថ្មីម្នាក់ៗ ត្រូវអធិស្ឋានខ្លួនឯងរាល់ថ្ងៃ ។ ម៉្យាងទៀត គ្រួសារពួកគេក៏ត្រូវជួបជុំគ្នាជាមួយសមាជិកក្រុមគ្រួសារជារៀង រាល់ថ្ងៃដែរ ដើម្បីអធិស្ឋាន និង រៀនព្រះបន្ទូលព្រះជាម្ចាស់ ។ អ្នកចាំបាច់ត្រូវធ្វើកិច្ចការទាំងនេះ បង្ហាញពួកគេនៅតាមផ្ទះរបស់ ពួកគេ ។

  សមាជិករបស់ក្រុមជំនុំទាំងឡាយ ដែលរីកចំរើន តែងតែជួបជុំគ្នារាល់ថ្ងៃ ដើម្បីអធិស្ឋានទូលសូមអោយមិត្តភ័ក្តិ និង គ្រួសារគេ ដែលបាត់បង់ បានសង្គ្រោះក្នុងអង្គព្រះយេស៊ូគ្រីស្ត ។

BETA VERSION released prior to proofreading

យោបល់អំពីសកម្មភាពសំរាប់ការប្រជុំទីមួយរបស់ក្រុមបង្កើតក្រុមជំនុំ :

- ពន្យល់ក្រុមបង្កើតក្រុមជំនុំថា ពួកសាវ័កដំបូងចេញទៅផ្សាយដំណឹងល្អពីរៗនាក់ ឬ ជាក្រុមតូច ។

  ពេលផ្សាយដំណឹងល្អ និង ផ្តល់ជំបូន្មាន បុរសត្រូវធ្វើកិច្ចការបំរើចំពោះបុរស និង ស្ត្រីចំពោះស្ត្រី ។

- នៅពេលអ្នកជួបជាមួយសហការីរបស់អ្នក សូមអធិស្ឋានរួចមើលឡើងវិញអំពីគោលការណ៍ណែនាំទាំងដប់ពីរ នៅក្នុងសៀវភៅណែនាំនេះ ។

  ធ្វើយ៉ាងណា អោយសមាជិកក្រុមបង្កើតក្រុមជំនុំទាំងអស់យល់ព្រមទទួលផែនការ និង របៀបធ្វើការរបស់អ្នក ។ ម៉្យាងទៀត ពន្យល់អំពីផែនការរយៈពេលវែងទាំងអស់ អំពីការបង្កើនចំនួនក្រុមជំនុំបន្ត ។

- ជំរាបសមាជិកក្រុមថា ពួកគេនឹងជួបគ្នាជាទៀងទាត់ ជា ក្រុម ។

  ក្រុមបង្កើតក្រុមជំនុំត្រូវជួបប្រជុំទៀងទាត់ ដើម្បីអធិស្ឋានសំរាប់គ្នាទៅវិញទៅមក និង សំរាប់មនុស្សដែលអ្នកកំពុងផ្សាយដំណឹងល្អ

ប្រាប់ ថែមទាំងកត់ផែនការរបស់សមាជិកក្រុមផង ។ សមាជិកក្រុមម្នាក់ៗរាយការណ៍ពីនរណាដែលគាត់កំពុងផ្សាយដំណឹងល្អ ឬ បង្រៀនអោយក្លាយជាសាវក ព្រមទាំងរាយការណ៍ពីការរីកចំរើន និង បញ្ហារបស់គាត់ដែរ ។

- សូមអោយសមាជិកដែលរៀបការហើយ និយាយជាមួយគ្នាស្រករគាត់អំពីការដែលគាត់សំរេចចិត្តធ្វើសមាជិកក្រុម បង្កើតក្រុមជំនុំ ។

  ប្រពន្ធអាចចូលរួមធ្វើកិច្ចការបំរើផ្ទាល់ជាមួយប្តី ឬ គាំទ្រការងាររបស់ប្តី ដោយអធិស្ឋាន ។ លើកទឹកចិត្តសហការីអោយចំណាយពេលវេលាគ្រប់គ្រាន់ជាមួយគ្រួសារពួកគេ ។ បើមានទំនាស់ក្នុងគ្រួសារ នោះអាចមានគ្រោះថ្នាក់ដល់គ្រួសារផ្ទាល់ និង ក្រុមជំនុំថ្មីដែរ ។

- គិតគូរ និង សំរេចអំពីអ្នកណាដែលត្រូវដឹកនាំក្រុមជំនុំថ្មី ។

  តើអ្នកនឹងបង្ហាត់បង្រៀនពួកអ្នកដឹកនាំតាមមូលដ្ឋាន ឬ ចាត់អោយសមាជិកម្នាក់របស់ក្រុមបង្កើតក្រុមជំនុំរបស់អ្នក ធ្វើជាអ្នកដឹកនាំក្រុមជំនុំថ្មី ?

BETA VERSION released prior to proofreading

- បង្រៀនពួកអ្នកជឿថ្មី អោយប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ប្រកបដោយសេចក្តីស្រឡាញ់ ។ តទៅនេះជាសេចក្តីបង្គាប់របស់ព្រះគ្រីស្ត :

  - កែប្រចិត្តគំនិត និង ជឿ (ម៉ាកុស ១:១៥, យ៉ូហាន ៣:១៦) ។

  - ទទួលពិធីជ្រមុជទឹក និង រស់នៅដោយមានជីវិតថ្មីក្នុងព្រះជាម្ចាស់ស្របតាមអត្ថន័យនៃពិធីជ្រមុជទឹក (ម៉ាកុស ១៦:១៦, កិច្ចការ ២:៣៨) ។

  - មានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ មនុស្សឯទៀត និង បងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ត (ម៉ាថាយ ៥-៧, ម៉ាថាយ ២២:៣៧-៣៩, យ៉ូហាន ១៣:៣៤) ។

  - ជួបជុំគ្នាធ្វើពិធីកាច់នំប៉័ង និង ជួបជុំគ្នា ដើម្បីថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា (លូកា ២២:១៧ -២០) ។

  - អធិស្ឋាន និង រិះគិតពិចារណាពីព្រះបន្ទូល ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ (ម៉ាថាយ ៤:៤, ៦:៥-១៣, យ៉ូហាន ១៤:១៤) ។

BETA VERSION released prior to proofreading

ប្តីប្រពន្ធពីរនាក់ ដែលធ្លាប់ទៅព្រះវិហារផ្សេង បានចាប់ផ្តើមមកក្រុមជំនុំយើង ។ ពួកគេមានគំនិតផ្សេង និងគោរពក្រិត្យវិន័យខ្លាំងណាស់ ។ តើអោយខ្ញុំធ្វើ ដូចម្តេច ?



ត្រូវដាក់លក្ខខ័ណ្ឌអោយពួកគេ ។ ជំបូង ពួកគេត្រូវយល់ព្រមជួយបង្កើតសាវក ដែលប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត និង ជួយបង្កើនចំនួនក្រុមជំនុំបន្ត ។ ពួកគេត្រូវជួយជំរុញពួកអ្នកជឿថ្មីអោយកាន់តែមានជំនឿ និង សេចក្តីស្រឡាញ់ មិនមែនគោរពក្រិត្យវិន័យហួសហេតុទេ ។

- តែងតាំងសមាជិកក្រុមបង្កើតក្រុមជំនុំ ដោយធ្វើពិធីតែង តាំង ។

ក្រុមជំនុំនៅអន់ទីយ៉ូក តែងតាំងលោកប៉ូល និង លោកបារណាបាស ដោយដាក់ដៃលើលោកទាំងពីរ ក្រោយដែលបានអធិស្ឋាន និង តមអាហារួច (កិច្ចការ ១៣:១-៣) ។ ជួយក្រុមជំនុំម្តាយអោយយល់គំរោងការងារ និង ផែនការរបស់គំរោងនេះ ។

ខ្ញុំចង់រស់នៅសហគមន៍ថ្មី ដើម្បីអាចមានពេលផ្សាយដំណឹងល្អច្រើនជាង ។ ប៉ុន្តែ យើងនៅមិនទាន់មានផ្ទះនៅទីរនោះនៅឡើយ ។



អធិស្ឋាន និង ទុកចិត្តលើព្រះជាម្ចាស់ទៅ ! ព្រះអង្គនឹងផ្គត់ផ្គង់គ្រប់សេចក្តីត្រូវការរបស់អ្នក (ម៉ាថាយ ១០:៩-១០) ។

យោបល់ខ្លះថែមទៀត ៖

បើអាចធ្វើបាន សូមរកអោយបានព្រះគម្ពីរទាំងមូល ឬ ព្រះគម្ពីរ
សម្ពន្ធមេត្រីថ្មីជាភាសាខ្មែរសម្រាយ ជាភាសាទូទៅដែលគេ និយាយតាមផ្ទះ
ដើម្បីមនុស្សអាចយល់បានច្បាស់លាស់ ។

រៀបចំឱ្យសមាជិកម្នាក់ៗរបស់ក្រុមបង្កើតក្រុមជំនុំអាចធ្វើកិច្ចការ បំរើរួមគ្នា
តាមរបៀបមួយដែលពួកគេអាចប្រើអំណោយទានរបស់ ពួកគេ ។
ត្រូវដោះស្រាយយ៉ាងម៉ឺងម៉ាត់ជាមួយសមាជិកណាដែល
មានបញ្ហាមិនចុះសម្រុងជាមួយសមាជិកឯទៀត ។

សង្ខេបអំពីគោលដៅ

រៀបចំ និង ចាប់ផ្តើមដឹកនាំអប់រំក្រុមបង្កើតក្រុមជំនុំរបស់អ្នក ។

*«គឺព្រះអង្គហើយ ដែលបានប្រទានអោយអ្នកខ្លះមានមុខងារជា គ្រីស្តទូត
អោយអ្នកខ្លះថ្លែងព្រះបន្ទូល អ្នកខ្លះផ្សាយដំណឹងល្អ អ្នកខ្លះជាអ្នកគង្វាល
និង អ្នកខ្លះទៀតជាអ្នកបង្រៀន ។ ដើម្បី រៀបចំប្រជាជនជំវិសុទ្ធ
អោយបំពេញមុខងារបំរើ និង កសាង ព្រះកាយរបស់ព្រះគ្រីស្តឡើង...» ។*
(អេភេសូ ៤:១១-១២)

BETA VERSION released prior to proofreading



ទាំងអស់ដែលកើតនៅពេលក្រោយទៀត ។ ពួកអ្នកជឿថ្មីមិនភ្លេច ពីមេរៀនខាងព្រលឹងវិញ្ញាណ ដែលពួកគេបានរៀនចេះ នៅក្នុង រយៈពេលប៉ុន្មានខែដំបូង ក្រោយពេលគេថ្វាយខ្លួនទេ ។

យោលបល់សំរាប់ការបង្រៀនពួកអ្នកជឿថ្មី អោយចេះស្តាប់ បង្គាប់ព្រះគ្រីស្ត ក្នុងឋានៈជាសាវ័កស្មោះត្រង់ :

- ជួយក្រុមបង្កើតក្រុមជំនុំរបស់អ្នកអោយយល់ថា គេអាចរាប់ ក្រុមជំនុំមួយជាក្រុមជំនុំពិតប្រាកដបាន លុះត្រាតែសមាជិក ក្រុមជំនុំប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្តប៉ុណ្ណោះ ។

BETA VERSION released prior to proofreading

គោលការណ៍ណែនាំ ទី ៣
ទាក់ទងអោយស្គាល់ និង រាប់អានពួកគេ



គោលដៅ :

- ទាក់ទងអោយស្គាល់ និង រាប់អានពួកគេ ។ (បើអ្នកមិន ធ្វើដូច្នេះទេ ការងារផ្សាយដំណឹងល្អមិនរីកចំរើនទេ) ។

- សំរេចចិត្តថា នឹងផ្សាយដំណឹងល្អប្រាប់អ្នកណាមុនគេ ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ការខំប្រឹងប្រែងរបស់
អ្នក ដើម្បីទាក់ទងអោយស្គាល់មនុស្ស ដែលអ្នកនឹងបង្កើតក្រុម
ជំនុំក្នុងចំណោមពួកគេ និង ជំរាបក្រុមអធិស្ឋានអំពីសំណូមពរ
អធិស្ឋានផ្សេងៗទៀត) ។

នៅទីក្រុងអាថែន លោកប៉ូលដើរពិនិត្យមើលទីក្រុងយ៉ាងហ្មត់ ចត់ ។
បន្ទាប់មក ទើបលោកនិយាយទៅកាន់បណ្តាជននៅ ទីនោះ
តាមរបៀបមួយដែលគេអាចយល់បាន ។
(សូមអាន កិច្ចការ ១៧:១៦-៣៤) ។ ដូចគ្នានេះដែរ យើងនឹងផ្សាយ
ដំណឹងល្អកាន់តែមានប្រសិទ្ធិភាព បើសិនជាយើងស្គាល់មនុស្ស
កាន់តែច្បាស់ ។

សេចក្តីសំខាន់ : បើអ្នកជាអ្នកដឹកនាំក្រុមបង្កើតក្រុមជំនុំ អ្នកត្រូវ
ធ្វើយ៉ាងណាអោយមានអ្នកណាម្នាក់ធ្វើកិច្ចការបំរើជាគំរូ សំរាប់
បង្ហាញដល់ពួកសហការី ដែលមិនទាន់មានបទពិសោធន៍ ។

យោបល់អំពីសកម្មភាពជំបួង

- មុនសមាជិកក្រុមបង្កើតក្រុមជំនុំចាប់ផ្តើមចុះទៅមើល សហគមន៍
ដែលពួកគេត្រូវទៅបង្កើតក្រុមជំនុំ សូម

BETA VERSION released prior to proofreading

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ពួកអ្នកជឿថ្មីរបស់ក្រុម ជំនុំថ្មី
ទូលសូមឱ្យពួកគេស្តាប់បង្គាប់ព្រះគ្រីស្ត ក្នុងឋានៈជាសាវក ស្មោះត្រង់ និង
ជំរាបក្រុមអធិស្ឋានអំពីសំណូមពរអធិស្ឋានផ្សេងៗ ទៀត) ។

*«ត្រូវបង្រៀនពួកគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែល
ខ្ញុំបានបង្គាប់អ្នករាល់គ្នា » ។ (ម៉ាថាយ ២៨:២០)*

នៅក្នុងមហាបណ្តាំ ព្រះគ្រីស្តបង្គាប់យើងអោយបង្កើតសាវក
ដែលប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលព្រះយេស៊ូបានបង្គាប់ ។
ពួកអ្នកជឿថ្មីត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងឡាយរបស់ព្រះអង្គ
គឺមិនមែនគ្រាន់តែរៀនអំពីសេចក្តីបង្គាប់ទាំងនោះទេ ។

អ្នកជឿលើព្រះយេស៊ូដោយស្មោះត្រង់ មានបំណងចង់ប្រតិបត្តិ
តាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។ ជំនឿដែលគ្មានការស្តាប់ បង្គាប់
ជាជំនឿដែលស្លាប់ (យ៉ាកុប ២:១៤-១៧) ។ យើងមិន
មែនបានសង្គ្រោះ ដោយសារការធ្វើអំពើល្អទេ ប៉ុន្តែ យើងបាន
សង្គ្រោះ ដើម្បីធ្វើអំពើល្អ (អេភេសូ ២:៨-១០) ។

សូមបញ្ជាក់ឱ្យច្បាស់ថា ការស្តាប់បង្គាប់ព្រះគ្រីស្តសំខាន់បំផុត
ចំពោះអ្នកជឿថ្មីផង និង អ្នកបង្កើតក្រុមជំនុំផង ។ ពួកអ្នកជឿ
ថ្មីនឹងធ្វើតាមសមាជិកនៃក្រុមបង្កើតក្រុមជំនុំ ។ ម៉្យាងទៀត ក្រុម
ជំនុំដែលកើតមុនគេ នៅក្នុងកន្លែងមួយ ជាគំរូសំរាប់ក្រុមជំនុំ

គោលការណ៍ ទី ៩
បង្រៀនអ្នកជឿថ្មីអោយចេះប្រតិបត្តិតាមព្រះគ្រីស្ត



គោលដៅ

- បង្រៀនពួកអ្នកជឿថ្មីអោយប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

BETA VERSION released prior to proofreading

ពិចារណាអំពីស្ថានភាពដូចតទៅនេះ ដែលទាក់ទងនឹងបេសកកម្មគ្រីស្តទូត នៅក្នុងវប្បធម៌ផ្សេង :

មនុស្សច្រើនតែចូលចិត្តចូលរួមជាមួយមនុស្សឯទៀត ដែលមានជាតិសាសន៍ និង ឋានៈក្នុងសង្គមដូចខ្លួន ។ លើកលែងតែក្នុងសហគមន៍មួយ ដែលមានជាតិសាសន៍ច្រើនរស់នៅរួមជាមួយគ្នាជាសង្គមតែមួយជាស្រេចហើយ ។ នៅពេលដែលមនុស្សបានថ្វាយខ្លួនហើយ ទើបយើងត្រូវបង្រៀនពួកគេអោយដឹងថា ពួកគេ ត្រូវស្រឡាញ់ និង ជួយក្រុមមនុស្សដែលមានវប្បធម៌ផ្សេងៗទៀត ។

ឧទាហរណ៍ : បើសិនជាអ្នកផ្សាយដំណឹងល្អដល់ពួកជនជាតិភាគតិចនៅខេត្តរតនគីរី អ្នកអាចជួបនឹងក្រុមវប្បធម៌មួយចំនួន ដែលនិយាយភាសាផ្សេងគ្នា ។ ដោយសារតែក្រុមវប្បធម៌ទាំងនោះជាសហគមន៍ផ្សេងគ្នា ដំបូងអ្នកត្រូវផ្សាយដំណឹងល្អដល់ក្រុមវប្បធម៌មួយសិន ។ ក្នុងករណីនេះ ដំណឹងល្អព្រះយេស៊ូនឹងត្រូវផ្សព្វផ្សាយតាមធម្មតា ពីក្រុមគ្រួសារមួយទៅក្រុមគ្រួសារមួយទៀត ដែលទុកចិត្តគ្នាទៅវិញទៅមករួចហើយ ។ សូមផ្សាយដំណឹងល្អតាមរយៈទំនាក់ទំនងធម្មតាដូចនេះ ដើម្បីប៉ះពាល់ក្រុមវប្បធម៌ទាំងមូល ។ នៅពេលអនាគត ក្រុមវប្បធម៌ដែលជឿលើព្រះយេស៊ូហើយនោះអាចនឹង ចែកចាយដំណឹងល្អព្រះយេស៊ូប្រាប់ក្រុមប្បធម៌មួយផ្សេងទៀត ។



- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ជួយសមាជិកក្រុម
  បង្កើតក្រុមជំនុំអោយអាចយល់ពីសេចក្តីត្រូវការរបស់មនុស្ស និង
  របៀបរបបរបស់ពួកគេ ។

BETA VERSION released prior to proofreading

បើសិនជាពួកអ្នកដែលមិនទទួលជឿ បណ្តាលអោយមានបញ្ហា ធ្ងន់ធ្ងរ
សូមនិយាយជាមួយពួកគេ ដើម្បីកែតម្រង់ពួកគេ ។ បើ
សិនជាពួកគេបែរទៅធ្វើអំពើបាបដដែល ហើយបដិសេធមិនព្រម
កែប្រែចិត្តគំនិតនោះ អ្នកត្រូវអោយពួកគេចេញពីក្រុមជំនុំ តែសូម
ធ្វើដោយសេចក្តីស្រឡាញ់ និង ដោយអំណាច ។

សង្ខេបអំពីគោលដៅ :

ធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ធ្វើពិធីកាច់នំបុ័ងជាមួយគ្នា
ជារូបកាយក្រុមជំនុំថ្មី និង អញ្ជើញសមាជិកអោយជួបជុំគ្នាទៀង ទាត់
ដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក ឱ្យដើរតាមព្រះគ្រីស្ត ។

*«...ធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និង
ព្រះវិញ្ញាណដ៏វិសុទ្ធ » ។ (ម៉ាថាយ ២៨:១៩)*

*«សាវ័កទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត
រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំបុ័ង និង ព្យាយាម អធិស្ឋាន » ។
(កិច្ចការ ២:៤២)*

BETA VERSION released prior to proofreading

អ្នកអាចពន្យល់កិច្ចការ ១៣:១៦-៣៤ ដល់សហការីរបស់អ្នក ដើម្បីបង្ហាញពួកគេពីរបៀប ដែលលោកប៉ូលទាក់ទាញអារម្មណ៍មនុស្សមិនទាន់ជឿ អំពីសាសនារបស់ពួកគេ ដើម្បីបញ្ចូលដំណឹងល្អអំពីព្រះយេស៊ូ ។

- ទៅសួរសុខទុក្ខមនុស្ស ដើម្បីទាក់ទងអោយស្គាល់ និងមានសេចក្តីស្រឡាញ់ចំពោះពួកគេ ហើយទាក់ទងរកឱ្យ បានពតិមានដែលនឹងជួយអ្នកអោយអាចមានទំនាក់ទំនងល្អជាមួយអ្នកទាំងនោះ ។

យោបល់សំរាប់ធ្វើអោយអ្នកអាចស្គាល់ក្រុមមនុស្សពិសេសមួយ

- សូមដើរមើលទីកន្លែងទាំងមូល ព្រមទាំងសង្កេតមើលបណ្តាជន ។

  ឧទាហរណ៍ បើសិនជាអ្នកឃើញមានមនុស្សប្រុសច្រើននៅតៀមលក់ស្រា សូមគិតពិចារណាថា÷ «តើខ្ញុំត្រូវយល់យ៉ាងណាអំពីរឿងនេះ ? យល់ថានៅទីនេះមានបញ្ហាញៀនស្រាឬ ? » ។ នៅពេលនោះ សូមកុំវិនិច្ឆ័យ ឬ ដាក់ទោស តែសូមអធិស្ឋាន និង សិក្សាពីស្ថានភាពនោះ ដើម្បីរកផ្លូវជួយបណ្តាជនវិញ ។



៣-(ពួកអ្នកដែលមិនទទួលជឿ តែមកចូលរួមថ្វាយបង្គំ) ។ ពិចារណាអំពីកិច្ចការ ដែលត្រូវធ្វើចំពោះពួកអ្នកដែលចូលរួមប្រជុំជាមួយក្រុមអ្នកជឿ តែមិនទាន់ទទួលព្រះយេស៊ូនៅឡើយ ។

- ចុះទៅលេងសាច់ញាតិ និង មិត្តភក្តិរបស់សមាជិកក្រុមបង្កើត ក្រុមជំនុំ ឬ របស់សមាជិកក្រុមជំនុំម្តាយ ។

- សូមទាក់ទងជជែកលេងជាមួយអ្នកជិតខាង ដោយសុភាព រាបសា ដើម្បីធ្វើអោយមានមេត្រីភាព ។

  សូមធ្វើកិច្ចការនេះ ដូចជាអ្នកដែលគ្រាន់តែចង់មានទំនាក់ទំនងល្អជាមួយពួកគេ មិនមែនដូចជាអ្នកស៊ើបអង្កេតទេ ។ សូមនិយាយជាមួយបណ្តាជននៅតាមផ្ទះ តាមកន្លែងប្រកប ការងារ តាមទីផ្សារ តាមហាងគុយទាវ តាមសួនសាធារណៈ ។ល។ ។ សូមទាក់ទងស្គាល់មនុស្សអោយបានច្រើនបំផុត ។ សូមសួរសំនួរស្របទៅតាមស្ថានភាព ហើយស្តាប់គេដោយយកចិត្តទុកដាក់ ។ លើកទឹកចិត្តពួកគេអោយនិយាយពីសេចក្តីត្រូវការ និង បញ្ហារបស់ពួកគេ ។

- ក្រោយមក សូមសរសេរពតិមានគ្រប់យ៉ាង ដែលមានតម្លៃដែលអ្នកទទួលបាន សំរាប់យកទៅពិភាក្សាជាមួយសហការីរបស់អ្នក ។

- ចូលរួមធ្វើសកម្មភាព និង កម្មវិធីផ្សេងៗរបស់សហគមន៍គឺសកម្មភាពដែលស្របនឹងភាពជាអ្នកជឿលើព្រះយេស៊ូ ។

BETA VERSION released prior to proofreading

១-(ពួកអ្នកដែលមិនទទួលជឿ និង មិនមកចូលរួមថ្វាយបង្គំ) ។ សូមនៅតែទាក់ទងជាមួយពួកគេ និង រាប់អានពួកគេ តែកុំបង្ខាតពេលជាមួយពួកគេច្រើន ពេកបើពួកគេនៅតែមិនចាប់អារម្មណ៍លើដំណឹងល្អ ។ អធិស្ឋានសំរាប់ពួកគេ និង ទៅសួរសុខទុក្ខពួកគេយូរៗ ម្តង ។ ប្រហែលជាពួកគេអាចនឹងកែប្រែចិត្តគំនិត នៅពេលក្រោយ ។

២-(ពួកអ្នកដែលពោលថា ខ្លួនទទួលជឿហើយ តែនៅមិនទាន់ប្រតិបត្តិតាមព្រះយេស៊ូ) ។ អធិស្ឋានទូលសូមប្រាជ្ញាពីព្រះជាម្ចាស់ ដើម្បីឱ្យអាចយល់ពីពួកគេបាន ។ ប្រហែលជាពួកគេមានអំពើបាប ដែលពួកគេមិនទាន់បានលន់តួសារភាព ដូចជា ចូលរួមក្នុងមន្តអាគម ធ្វើជាមនុស្សដែលចេះតែស្រវឹងស្រា វាយប្រពន្ធ ប្រព្រឹត្ត អំពើសហាយស្មន់ ។ល។ ។ សូមពន្យល់ថា ព្រះគ្រីស្ត នឹងលើកលែងទោសអំពើបាបទាំងអស់ ដែលពួកគេ លន់តួសារភាពទូលព្រះអង្គ ព្រមទាំងយល់ព្រមឈប់ ប្រព្រឹត្តអំពើបាបទាំងនោះ ។ សូមជួយពួកគេ ដោយ សេចក្តីស្រឡាញ់ អោយអាចដោះស្រាយបញ្ហារបស់ ពួកគេបាន ។

ជួនកាល ក្រុមបង្កើតក្រុមជំនុំគ្រាន់តែប្រមូលបណ្តាជនមកជួបជុំ គ្នា ដើម្បីច្រៀង អធិស្ឋាន និង ស្តាប់ព្រះបន្ទូលប៉ុណ្ណោះ ។ ធ្វើដូចនេះ មិនគ្រប់គ្រាន់ទេ ។ សមាជិកក្រុមត្រូវបង្រៀនក្រុមជំនុំថ្មីអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ដែរ គឺថា ធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ធ្វើពិធីកាច់នំប៉័ង និង ថ្វាយដង្វាយ ។ល។ ។ មួយវិញទៀត ត្រូវបង្ហាត់បង្រៀនមនុស្សដែលរស់នៅកន្លែងនោះ អោយក្លាយទៅជាអ្នកដឹកនាំ ដែលចេះឃ្វាលក្រុមជំនុំថ្មី ។ មានតែធ្វើដូចនេះទេ ទើបអ្នកអាចបង្កើតបានក្រុមជំនុំមួយ ដែលសកម្ម និង ចេះប្រតិបត្តិតាមព្រះគ្រីស្ត ។

- ចាត់តាំងអ្នកជឿថ្មីម្នាក់ជាលេខាបណ្តោះអាសន្ន ។

  ប្រគល់បញ្ជីឈ្មោះសមាជិកអោយគាត់ ។ បញ្ជីនោះប្រហែលជាគ្រាន់តែជាសៀវភៅកំណត់ធម្មតាមួយប៉ុណ្ណោះ ។ សូមអោយលេខានោះកត់ឈ្មោះពួកអ្នកដែលបានទទួលពិធី ជ្រមុជទឹក និង ថ្ងៃ ខែ ដែលពួកគេបានទទួលផងដែរ ។

- ពិចារណាអំពីកិច្ចការ ដែលត្រូវធ្វើជាមួយពួកអ្នកដែលមិនចង់ជាក់ខ្លួនចុះចូលក្នុងក្រុមជំនុំថ្មី ។ ពួកអ្នកទាំងនោះ អាចមានបីប្រភេទយ៉ាងគឺច :

BETA VERSION released prior to proofreading

- អ្នកអាចធ្វើកម្រងសំណួរ ដើម្បីយកទៅសួរតាមផ្ទះ ។

  បើចាំបាច់ ត្រូវសូមការអនុញ្ញាតិពីអ្នកដឹកនាំសហគមន៍ ។ កម្រងសំនួរអាចជួយឱ្យមនុស្សបង្ហាញពីទឹកចិត្តរបស់គេ ។ ប៉ុន្តែ ការទៅសួរសំណួរតាមផ្ទះ អាចបណ្តាលអោយមានប្រតិកម្មមិនល្អដែរ ។ នៅក្នុងសង្គមខ្លះ មនុស្សអាចគិតថាអ្នកជជែកសួរពួកគេ ដើម្បីយកពត៌មានទៅប្រើប្រាស់ប្រឆាំងនឹងពួកគេ ជាពិសេសបើអ្នកកត់ចំលើយរបស់ពួកគេនៅមុខពួកគេ ។ ត្រូវសួរអ្នកណាម្នាក់ ដែលមានបទពិសោធន៍ក្នុងការស្រាវជ្រាវនេះ អំពីរបៀបធ្វើកិច្ចការនេះ ។

សេចក្តីដែលត្រូវចេះដឹងអំពីមនុស្ស

ត្រូវប្រយ័ត្នពីរបៀបដែលអ្នកអនុវត្ត ដើម្បីទទួលពត៌មាន ។ ក្នុង សង្គមខ្លះ អ្នកមិនត្រូវសួរមនុស្សដែលអ្នកមិនស្គាល់ ដោយត្រង់ៗ អំពីកិច្ចការផ្ទាល់ខ្លួនរបស់គេទេ ។

សួរសំណួរអំពីសាសនា

ពតិមានអំពីចំណេះដឹងខាងព្រលឹងវិញ្ញាណ និង ខាងសាសនារបស់ ពួកគេ នឹងជួយអ្នកឱ្យចេះប្រាប់ពួកគេអំពីព្រះអម្ចាស់យេស៊ូគ្រីស្ត តាមរបៀបមួយ ដែលពួកគេអាចយល់បានស្រួលជាង ។

តើពួកគេកាន់សាសនាអ្វី ?

តើពួកគេប្រកាន់ពិធីសាសនាអ្វីខ្លះ ទុកជាផ្នែកមួយរបស់វប្បធម៌ របស់ខ្លួន (ឧ. ការដុតទៀន ធូបឧទ្ទិសដល់មនុស្សស្លាប់ជាដើម) ?

ហេតុអ្វីបានជាពួកគេចង់ធ្វើពិធីសាសនាផ្សេងៗទាំងនោះ (ឧទាហរណ៍ : ពីព្រោះជាទំនៀមទំលាប់ ដែលមានតាំងពីយូរ ណាស់មកហើយ) ?

BETA VERSION released prior to proofreading

ពួកអ្នកជឿថ្មីត្រូវដឹងខ្លួនថា ពួកគេជាសមាជិកក្រុមជំនុំថ្មី ។ ដូចនេះ បើសិនជាចាំបាច់ សូមកុំអោយសមាជិកក្រុម បង្កើតក្រុមជំនុំខ្លះទៅចូលរួមថ្វាយបង្គំ រហូតទាល់តែ ក្រុមជំនុំថ្មីកើនចំនួនសិន ។

ក្រុមគ្រីស្តទូតដែលធ្វើកិច្ចការបំរើ នៅក្នុងវប្បធម៌ផ្សេង មិនត្រូវ បណ្តោយអោយក្រុមរបស់ខ្លួនក្លាយជាក្រុមជំនុំខ្លួនឯងទេ តែត្រូវ ធ្វើកិច្ចការបំរើជាឆ្អប ដែលជួយសមាជិករបស់សហគមន៍មូលដ្ឋាន បង្កើតក្រុមជំនុំមួយថ្មីវិញ គឺត្រូវជួយអោយក្រុមជំនុំថ្មី សុទ្ធសាធ កើតឡើងវិញ ។

- សូមអោយពួកអ្នកជឿថ្មីសន្យាថា ដោយមានព្រះជាម្ចាស់ ជួយ ពួកគេនឹងប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងឡាយរបស់ ព្រះគ្រីស្ត ។

អញ្ជើញពួកគេឱ្យប្តេជ្ញាប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ដូចជា : បន្តមានជំនឿលើព្រះអង្គ បន្តកែប្រែចិត្តគំនិត បានពេញដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ មានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និង ចំពោះអ្នកដទៃ ជួបជុំគ្នាដើម្បីធ្វើពិធីកាច់នំបុ័ង អធិស្ឋានរាល់ថ្ងៃ អោយ ផ្សព្វផ្សាយដំណឹងល្អ និងឃ្វាលអ្នកឯទៀត ។



- ធ្វើយ៉ាងណាអោយពួកអ្នកជឿថ្មីដឹងថា ពួកគេជាក្រុមជំនុំ គឺមិនមែនគ្រាន់តែជាគោលដៅសំរេចរបស់ការងាររបស់ក្រុមបង្កើតក្រុមជំនុំប៉ុណ្ណោះទេ ។

នៅពេលជួបជុំគ្នាថ្វាយបង្គំជាលើកទីមួយ ពួកអ្នកជឿថ្មីមានចំនួនតិចជាងសមាជិកក្រុមបង្កើតក្រុមជំនុំ ហើយពួកគេមិនយល់ថាពួកគេជាក្រុមជំនុំថ្មីទេ ។ ពួកគេ ស្មានថាពួកគេគ្រាន់តែជាអ្នកចូលរួមជាមួយក្រុម បង្កើតក្រុមជំនុំប៉ុណ្ណោះ ។

BETA VERSION released prior to proofreading

តើពួកគេជឿដូចម្តេច អំពីព្រះជាម្ចាស់ដែលជាព្រះអាទិករ ?

តើពួកគេថ្វាយបង្គំព្រះជាម្ចាស់ ដោយរបៀបណា ?

តើព្រះជាម្ចាស់មានន័យដូចម្តេចចំពោះជំនឿរបស់ពួកគេ
(តើព្រះជាម្ចាស់មានឥទ្ធិពលលើជំនឿរបស់ពួកគេដូចម្តេច) ?

តើពួកគេជឿយ៉ាងដូចម្តេចអំពីស្ថានបរមសុខ ?

តើពួកគេជឿយ៉ាងដូចម្តេចអំពីឋាននរក ?

តើពួកគេជឿយ៉ាងដូចម្តេចអំពីជីវិតអស់កល្ប ?

តើពួកគេជឿយ៉ាងដូចម្តេចអំពីមារសាតាំង (ឬ អំណាចអារក្ស) និង
វិញ្ញាណអាក្រក់ ?

តើពួកគេខ្លាចវិញ្ញាណអាក្រក់ដែរឬទេ ?

តើពួកគេជឿយ៉ាងដូចម្តេចអំពីរបៀបបង្កើតពិភពលោក ?

BETA VERSION released prior to proofreading

យោបល់សំរាប់ធ្វើអោយក្រុមអ្នកជឿ ដែលបានទទួល ពិធីជ្រមុជទឹក រាប់ខ្លួនជាក្រុមជំនុំមួយ :

- អោយពួកអ្នកដែលបានទទួលពិធីជ្រមុជទឹក ធ្វើពិធីកាច់នំប៉័ង រួមជាមួយគ្នា ហើយនៅពេលនោះប្រកាសថា ក្រុមរបស់ ពួកគេឥឡូវនេះបានក្លាយជាក្រុមជំនុំមួយហើយ ។

ពួកគេមិនមែនគ្រាន់តែជាក្រុមសិក្សាព្រះគម្ពីរប៉ុណ្ណោះទេ គឺពួកគេ ជាបងប្អូនក្នុងក្រុមជំនុំ, ព្រះសហគមន៍ដែលជឿ និង ប្រតិបត្តិតាម ព្រះអម្ចាស់យេស៊ូ ។ ពួកគេជាព្រះកាយរបស់ព្រះអង្គ ដែលមាន ព្រះវិញ្ញាណព្រះអង្គគង់ជាមួយ ។ សូមធ្វើឱ្យពួកគេមើលឃើញថា ពួកគេនឹងក្លាយជាក្រុមជំនុំមួយ ដែលថ្វាយបង្គំព្រះជាម្ចាស់ មាន សេចក្តីស្រឡាញ់ ផ្សាយដំណឹងល្អ និង ធ្វើការងារដោយស្រុះស្រួល គ្នាល្អ និង ដោយអំណរ ។ បើពួកអ្នកជឿថ្មីបានយល់សេចក្តី ទាំងនេះ ពួកគេពិតជាធ្វើការងារជាមួយគ្នា និង ធ្វើពលិកម្មដើម្បី ការងាររបស់ព្រះអម្ចាស់ ។

- សរសេរឈ្មោះរបស់ពួកអ្នកជឿ ដែលបានទទួលពិធីជ្រមុជ ទឹក និង ថ្ងៃ ខែ ដែលពួកគេបានទទួលពិធីជ្រមុជទឹក :

BETA VERSION released prior to proofreading

តើពួកគេជឿថា នឹងមានអ្វីកើតឡើងចំពោះពួកគេ ក្រោយពេល ដែលពួកគេស្លាប់ទៅ ?

តើពួកគេជឿយ៉ាងដូចម្តេចអំពីព្រលឹងរបស់ដួនតារបស់ពួកគេ ?

តើពួកគេជឿថា ព្រលឹងមនុស្សស្លាប់មករកពួកគេដែរឬទេ ?

តើពួកគេយល់ដឹងអ្វីខ្លះអំពីព្រះគម្ពីរ ?

បើបានរៀនចេះ តើពួកគេបានរៀនចេះអ្វីខ្លះ តាមរយៈព្រះគម្ពីរ ?

តើពួកគេអានព្រះគម្ពីរទៀងទាត់ដែរឬទេ ?

តើពួកគេជឿថា មនុស្សទាំងអស់មានបាបដែរឬទេ ?

តើពួកគេជឿយ៉ាងណា ? តើពួកគេជឿថា បាបរបស់យើង គឺជា
អំពើដែលយើងធ្វើប្រឆាំងនឹងព្រះជាម្ចាស់ និង ប្រឆាំងនឹងមនុស្ស ឬទេ ?

បើសិនជាពួកគេទៅព្រះវិហារ/ក្រុមជំនុំមួយ តើពួកគេសង្ឃឹមថា
នឹងបានអ្វីនៅទីនោះ (មេត្រីភាព ការបង្រៀនព្រះគម្ពីរ សេចក្តី
សង្គ្រោះតាមរយៈព្រះគ្រីស្ត ជំនួយខាងសម្ភារៈ ។ល។) ?

BETA VERSION released prior to proofreading

ឃ- ពិធីកាច់នំបុ័ង :

ធ្វើពិធីកាច់នំបុ័ងក្នុងសភាពគោរពយ៉ាងជ្រាលជ្រៅ សូមកុំ
ធ្វើពិធីនេះរហ័សពេក ព្រោះបង្ហាញថា គ្មានការគោរពកោត ខ្លាច ។
សូមនឹកចាំថាយើងធ្វើនេះ ដើម្បីរំលឹកពីការសុគត របស់ព្រះអម្ចាស់ ។
នៅពេលដែលអ្នកកាច់នំបុ័ង សូម និយាយយឺតៗដោយអំណាច
តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ នេះ «នេះជារូបកាយរបស់ខ្ញុំ »
(លូកា ២២:១៩) ។ សូម
ទុកអោយបណ្តាជនសង្រួមចិត្តរិះគិតពិចារណាក្នុងចិត្ត ។
នៅពេលទទួលទឹកទំពាំងបាយជូរ ត្រូវធ្វើតាមរបៀបដូចនេះ ដែរ
(លូកា ២២:២០) ។ នៅពេលនោះ សូមកុំនិយាយ
ពន្យល់អំពីពិធីកាច់នំបុ័ងយូរពេក គឺសូមទុកអោយព្រះ
វិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូល តាមរយៈពិធីកាច់នំបុ័ង
ផ្ទាល់វិញចុះ ។

- ធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី និង ទទួលពួកគេជា
  សមាជិករបស់ក្រុមជំនុំព្រះគ្រីស្ត ។

ក- សិរិយាបថសំរាប់ក្រុមតូច :

ឈរ ឬ អង្គុយជុំវិញតុដែលមាននំប៉័ង និង ទឹកទំពាំង
បាយជូរ (បើអត់មានតុ ត្រូវដាក់នំប៉័ង និង ទឹកទំពាំង បាយជូរ
នៅលើកន្ទេលក៏បានដែរ) ។

ខ- ការសរសើរតម្កើង :

ច្រៀងចំរៀងសរសើរតម្កើង ដែលអ្នកចូលរួមចេះគ្រប់គ្នា ។
ឬក៏ពួកគេអាចអានទំនុកតម្កើងខ្លះក៏បានដែរ ។ បើសិនជា
ពួកគេអាចអានបាន ត្រូវប្រាប់ពួកគេអោយអានយឺតៗទាំង អស់គ្នា ។
(បើមានអ្នកមិនចេះអក្សរមកចូលរួម សូមកុំ
អោយអានម្តងម្នាក់អោយសោះ ។ គួរតែអោយគេទន្ទេញ
ទំនុកតម្កើងថ្វាយបង្គំមួយ ឬ ពីរ ហើយសូត្រឡើងវិញ លួជាង) ។

គ- ការអធិស្ឋាន :

សូមអោយពួកគេអធិស្ឋានក្នុងចិត្ត លន់តួសារភាពបាបរបស់
ពួកគេទូលទៅព្រះជាម្ចាស់ ។ បន្ទាប់មក បញ្ជាក់ប្រាប់ពួក គេថា
ព្រះជាម្ចាស់អត់ទោសអោយពួកគេហើយ ។

BETA VERSION released prior to proofreading

ចំពោះក្រុមជំនុំដែលពួកគេស្គាល់ តើពួកគេមិនពេញចិត្តអ្វីខ្លះ ?

នៅពេលមានគ្រោះអាសន្ន ដូចជាទឹកជំនន់ ។ល។ តើពួកគេ ទូលអង្វ ឬ
បន់ស្រន់ទៅអ្នកណា (ព្រះណា វិញ្ញាណណា ។ល។) ?

តើពួកគេសូត្រមិ បន់ស្រន អធិស្ឋានក្នុងកាលៈទេសៈណាខ្លះ ?

តើពួកគេស្វែងរកជំនួយពីអ្នកខាងពិភពព្រលឹងវិញ្ញាណទាំនោះ
ដោយរបៀបណា ?

រៀនអោយដឹងពីអ្វីៗដែលពួកគេអោយតម្លៃខាងសាសនារបស់ពួក
គេ ដើម្បីអាចពន្យល់ នៅពេលក្រោយ ពីរបៀបដែលព្រះយេស៊ូ
ជួយបំពេញសេចក្តីត្រូវការតាមរបៀបប្រសើរជាង ។

សំណួរអំពីសេចក្តីត្រូវការ

បើសិនជាអ្នកដឹងពីសេចក្តីត្រូវការខ្លាំងបំផុតរបស់បណ្តាជននោះ
អ្នកអាចប្រាប់ពួកគេថា ព្រះយេស៊ូគ្រីស្តជាព្រះអង្គដែលនឹងផ្គត់ផ្គង់
សេចក្តីត្រូវការរបស់ពួកគេ ។ សេចក្តីត្រូវការខ្លះ ជាសញ្ញាជាក់
ស្តែងនៃបញ្ហាខាងព្រលឹងវិញ្ញាណ ដូចជាការភ័យខ្លាចសេចក្តីស្លាប់
ជម្ងឺ និង សង្គ្រាម ព្រមទាំងការមានអារម្មណ៍ថានៅឯកោ ថាគ្មាន
នរណាស្រឡាញ់ខ្លួន និង ថាជីវិតរស់នៅសព្វថ្ងៃនេះគ្មានន័យ ។
(សេចក្តីត្រូវការ និង បញ្ហាផ្សេងៗទៀត គឺគ្មានការងារធ្វើ ការ ប្រមឹកស្រា
ការញៀនគ្រឿងញៀន បញ្ហារវាងប្តីប្រពន្ធ ឬ បញ្ហា គ្រួសារ អនក្ខរកម្ម
ការគ្មានថ្នាំពេទ្យព្យាបាល និង គ្មានចំណី អាហារដែលមានជីវជាតិ
។ល។) ។

BETA VERSION released prior to proofreading

គ) អធិស្ឋានដាក់ដៃលើពួកអ្នកជឿថ្មី សូមអោយពួកគេបាន ពោរពេញ
ដោយព្រះវិញ្ញាណដ៏វិសុទ្ធ (កិច្ចការ ៨:១៧) ។

ឃ) ក្រោយពីធ្វើពិធីជ្រមុជទឹករួចហើយ អ្នកប្រហែលជាចង់ធ្វើ
ពិធីកាច់នំបុ័ងជាមួយគ្នាភ្លាមៗ ។ ពិធីជ្រមុជទឹកបញ្ជាក់ថា
ពួកអ្នកជឿថ្មីជាកូនរបស់ព្រះគ្រីស្ត និង ជាប្រជារាស្ត្រព្រះអង្គ
ឯពិធីកាច់នំបុ័ងបញ្ជាក់ថា ពួកគេបានរួមជាមួយព្រះគ្រីស្ត ។
ជាធម្មតា មានតែពួកអ្នកដែលបានទទួលពិធីជ្រមុជទឹករួច
ហើយប៉ុណ្ណោះ ដែលចូលរួមធ្វើពិធីកាច់នំបុ័ង ។

យោបល់ខ្លះសំរាប់ពិធីកាច់នំបុ័ង :

(បើសិនជាក្រុមជំនុំរបស់អ្នកមិនទាន់មានរបៀបធ្វើ ដែលមានពី
មុនមកហើយទេ) ។



- បង្រៀនពួកអ្នកជឿថ្មីថា ពិធីជ្រមុជទឹកជារបៀបប្រកាស ជំនឿរបស់ពួកគេលើព្រះគ្រីស្ត តាមព្រះគម្ពីរ ។

- រៀបចំផែនការសំរាប់ធ្វើពិធីជ្រមុជទឹក និង ទទួលអោយ ចូលជាសមាជិករបស់ក្រុមជំនុំព្រះគ្រីស្ត ។

យោបល់ខ្លះសំរាប់ការធ្វើពិធីជ្រមុជទឹក :

(បើសិនជាអ្នកគ្មានរបៀបដែលមានពីមុនមកទេ) ។

ក) សុំអោយពួកអ្នកជឿថ្មីប្រកាសបង្ហាញថា ពួកគេបានកែប្រែ ចិត្តគំនិត និង មានជំនឿលើព្រះគ្រីស្តជាព្រះសង្គ្រោះ និង ព្រះអម្ចាស់ ។ សុំអោយពួកអ្នកដែលទទួលពិធីជ្រមុជទឹក ពីមុនហើយ ទទួលរាប់រកពួកអ្នកជឿថ្មី និង ស្រឡាញ់ពួក គេដូចបងប្អូន ព្រមទាំងអធិស្ឋានសំរាប់ពួកគេ និង ជួយ ពួកគេអោយអាចស្តាប់បង្គាប់ព្រះអម្ចាស់យេស៊ូ ។

ខ) ធ្វើពិធីជ្រមុជទឹកអោយពួកគេ (ធ្វើតាមរបៀបរបស់ក្រុមជំនុំ អ្នកផ្តាល់) ។

BETA VERSION released prior to proofreading

តើបណ្តាជនមានសេចក្តីត្រូវការអ្វី និង មានបញ្ហាអ្វីខ្លាំងជាងគេ ?

_____

_____

តើបណ្តាជនប្រកបមុខរបរអ្វីច្រើនជាងគេ ?

_____

តើបណ្តាជនមានកិរិតជីវភាពដូចម្តេច ? .

- ☐ ក្រ ។
- ☐ គ្មានការងារធ្វើ ។
- ☐ កម្មករបានប្រាក់ឈ្នួលតិច ។
- ☐ កសិករ ។
- ☐ ថ្នាក់មធ្យម ។
- ☐ ថ្នាក់ខ្ពស់ ។
- ☐ ផ្សេងៗទៀត ។ _____

នៅពេលអនាគត អ្នកជឿថ្មីនឹងផ្សាយដំណឹងល្អប្រាប់អ្នកដទៃ ទៀត ។ សេចក្តីសំខាន់ គឺក្រុមបង្កើតក្រុមជំនុំត្រូវផ្តល់គំរូល្អ។ អំពីការផ្សាយដំណឹងល្អ ដែលពួកគេអាចធ្វើតាមបានដោយស្រួល និង មានជោគជ័យ ។



BETA VERSION released prior to proofreading

- បើអាចធ្វើបាន សូមធ្វើពិធីជ្រមុជទឹកអោយគ្រួសារទាំងមូលជាមួយគ្នា (កិច្ចការ ១៦:១៥, ៣១-៣៣) ។



- ពន្យល់អំពីពិធីជ្រមុជទឹកប្រាប់សហការីរបស់អ្នក នៅក្នុងក្រុមបង្កើតក្រុមជំនុំ ដោយសិក្សាព្រះគម្ពីររួមជាមួយគ្នា ។

ខព្រះគម្ពីរទាំងនេះ បង្រៀនយើងអំពីពិធីជ្រមុជទឹក : ម៉ាថាយ ២៨:១៩-២០, កិច្ចការ ២:៣៧-៤២, កិច្ចការ ៨:៣៥-៣៨, កិច្ចការ ១០:៤៧-៤៨, រ៉ូម ៦:១-១៤ ។ យើងឃើញនៅក្នុងសៀវភៅកិច្ចការថា ពួកសាវ័កមិនដែលពន្យារពេលធ្វើពិធីជ្រមុជ-ទឹកទេ ។ ពេលដែលមនុស្សបានកែប្រែចិត្តគំនិត និង ប្រកាសថាពួកគេមានជំនឿលើព្រះគ្រីស្ត (កិច្ចការ ១៦:៣១-៣៣) គេក៏ទទួលពិធីជ្រមុជទឹកភ្លាមដែរ ។ ពួកសាវ័កច្រើនតែធ្វើពិធីជ្រមុជ-ទឹកអោយមនុស្សនៅថ្ងៃដែលគេថ្វាយខ្លួន ។

នៅក្នុងព្រះគម្ពីរ ពិធីជ្រមុជទឹកមិនមែនជាពិធីសំរាប់ប្រគល់សញ្ញាប័ត្រ បន្ទាប់ពីបានរៀនវគ្គសិក្សាអំពីគោលជំនឿរយៈពេលវែងនោះទេ តែពិធីជ្រមុជទឹកជាឱកាសសំរាប់អ្នកជឿថ្មីចាប់ផ្តើមជីវិតថ្មីក្នុងព្រះគ្រីស្ត និង ឈានជំហានទីមួយនៃការស្តាប់បង្គាប់ទៅវិញទេ ។ អ្នកអាចបង្រៀនអ្នកជឿថ្មីបន្ថែមទៀត ក្រោយពេលដែលពួកគេទទួលពិធីជ្រមុជទឹកហើយ ។ យើងនឹងពន្យារពេលដើម្បីណែនាំបង្រៀនអំពីពិធីជ្រមុជទឹកយូរបន្តិច តែបើសិនជាអ្នកជឿថ្មីមិនយល់ពីពិធីជ្រមុជទឹក ។

BETA VERSION released prior to proofreading

សំណួរអំពីអ្នកដឹកនាំសហគមន៍

សូមទាក់ទងជាមួយអ្នកដឹកនាំនៅក្នុងសហគមន៍នោះ ដែលប្រជា ជនគោរព និង ដែលធ្វើសេចក្តីសំរេចសំខាន់ៗក្នុងសហគមន៍ ។
បើសិនជាអ្នកបង្កើតក្រុមជំនុំនៅទីក្រុង ត្រូវខិតខំទាក់ទងជាមួយពួកអ្នកដែលមានឥទ្ធិពលខ្លាំងលើបណ្តាជន ដូចជាចៅហ្វាយក្រុង និង នាយកសាលា ។ សូមធ្វើការងាររបស់អ្នក តាមរយៈពួកគេ បើសិនជាអាចធ្វើបាន ។ ចូរផ្សាយដំណឹងល្អដល់ពួកគេ ព្រោះបើពួកអ្នកទាំងនេះថ្វាយខ្លួន អ្នកឯទៀតមុខជាធ្វើតាម ម្យ៉ាងទៀត ពួកគេអាចក្លាយទៅជាអ្នកដឹកនាំក្នុងក្រុមជំនុំថ្មី ។ សូមទៅសុំ ជំនួយ និង យោបល់ពីអ្នកដឹកនាំសហគមន៍ ហើយធ្វើអោយពួក គេទុកចិត្ត និង គាំទ្រកិច្ចការបំរើរបស់អ្នក ។

តើអ្នកណាជាអ្នកដឹកនាំសហគមន៍នោះ (សូមកត់អាស័យដ្ឋាន និង តួនាទីរបស់ពួកគេ) ?

ឈ្មោះ អាស័យដ្ឋាន តួនាទី

_____

_____

តើពួកអ្នកជឹកនាំសហគមន៍បានជួយអ្នក តាមរបៀបណាខ្លះ ?

_____

_____

_____



សូមអធិស្ឋានសំរាប់អ្នកកាន់អំណាចទាំងអស់នោះ
និង ប្រាស្រ័យទាក់ទងជាមួយពួកគេផង ។
(១ ធីម៉ូថេ ២:១-៣)

BETA VERSION released prior to proofreading

*ព្រះគ្រីស្ត យើងក៏ជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គ
ដែរ »* ។ *(រ៉ូម ៦:៣-៨)*

យោបល់សំរាប់ការធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី :

កំណត់ចំណាំសំខាន់ៗ :

យោបល់សំរាប់គ្រីស្តទូត ដែលធ្វើកិច្ចការបំរើ នៅក្នុងវប្បធម៌ផ្សេង:
នៅកន្លែងដែលអ្នកទទួលជឿព្រះយេស៊ូ ត្រូវគេបៀតបៀនខ្លាំង
រហូតដល់សំឡាប់គេ សូមទុកអោយអ្នកជឿថ្មីសំរេចចិត្តខ្លួនឯងថា
គួរប្រកាសជំនឿរបស់ពួកគេជាសាធារណៈ ឬ មិនគួរ ។ សូមកុំ
បង្ខំពួកគេអោយធ្វើតាមរបៀបណាមួយអោយសោះ ។ គ្រីស្តទូត
ខ្លះធ្វើពិធីជ្រមុជទឹកអោយមនុស្សដោយសម្ងាត់ ។

យោបល់សំរាប់ក្រុមជំនុំ :
ក្រុមជំនុំផ្សេងៗ មានជំនឿផ្សេងគ្នាអំពីពិធីជ្រមុជទឹក និង មាន
របៀបធ្វើពិធីជ្រមុជទឹកផ្សេងៗគ្នាដែរ ។ នៅក្នុងសៀវភៅណែនាំ នេះ
យើងចែកចាយអំពីគោលការណ៍សំខាន់ៗ សំរាប់ពិធីជ្រមុជទឹក
ដែលដកស្រង់ពីក្នុងព្រះគម្ពីរ ។ អ្នកត្រូវយកគោលការណ៍សំខាន់ ទាំងនេះ
ទៅអនុវត្តស្របទៅតាមរបៀបរបបរបស់ក្រុមជំនុំអ្នក ។

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ពួកអ្នកដែលត្រូវទទួល
ពិធីជ្រមុជទឹក និង ជំរាបក្រុមអធិស្ឋានអំពីសំណូមពរអធិស្ឋាន
ផ្សេងៗទៀត) ។

តើព្រះជាម្ចាស់មានផែនការដូចម្តេច សំរាប់ធ្វើពិធីជ្រមុជទឹកអោយ
ពួកអ្នកជឿ ដែលជាមនុស្សពេញវ័យ ? ។ សាវ័កប៉ូលបង្ហាញពី
ផែនការនោះ ដោយមានប្រសាសន៍ថា :

*«តើបងប្អូនមិនជ្រាបទេឬ យើងទាំងអស់គ្នា ដែលបានទទួលពិធី
ជ្រមុជទឹក ដើម្បីរួមជាមួយព្រះគ្រីស្តយេស៊ូនោះ គឺយើងបានជ្រមុជ
រួមជាមួយព្រះអង្គ ដែលសោយទិវង្គត ។ ហេតុនេះ ដោយពិធី ជ្រមុជទឹក
ដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅ
ក្នុងផ្នូររួមជាមួយព្រះអង្គដែរ ។ ដូច្នេះ ព្រះគ្រីស្តមានព្រះជន្មរស់ ឡើងវិញ
ដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើង
ក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ ។ ប្រសិនបើយើងបានរួម
ស្លាប់ជាមួយព្រះអង្គដែលសោយទិវង្គត យើងក៏នឹងបានរួមជាមួយ ព្រះអង្គ
ដែលមានព្រះជន្មរស់ឡើងវិញដែរ ។ យើងដឹងថា ចរិត
ចាស់របស់យើងបានជាប់ឆ្កាងជាមួយព្រះអង្គរួចហើយ ដើម្បីអោយ ខ្លួនយើង
ដែលជាប់បាបនេះ ត្រូវវិនាសសាបសូន្យ កុំអោយយើង ទៅ
ធ្វើជាខ្ញុំបំរើរបស់បាបតទៅទៀត ។ ដ្បិតអ្នកដែលស្លាប់ មិនទាក់
ទាមនឹងបាបទៀតទេ ។ ដូច្នេះ បើសិន ជាយើងរួមស្លាប់ជាមួយ*

BETA VERSION released prior to proofreading

សំណួរអំពីអង្គការ

នៅក្នុងទីក្រុង និង ភូមិធំៗមានអង្គការ ឬ សមាគមច្រើនណាស់
ដូចជា ក្លិបកីឡាជាដើម ។ អង្គការទាំងអស់នោះ កើតឡើង
ដោយសារសមាជិកមានចំណូលចិត្តដូចគ្នា ។ ជួនកាល ការ
ចូលជាសមាជិកអង្គការណាមួយ អាចជួយអ្នកក្នុងការផ្សាយ
ដំណឹងល្អប្រាប់សមាជិកឯទៀតរបស់អង្គការនោះ ។ ដោយសារ
អង្គការនិមួយៗប្រៀបដូចជាក្រុមគ្រួសារមួយ អ្នកអាចឆ្លៀតប្រើ
ប្រាស់ទំនាក់ទំនងជិតស្និទ្ធរវាងសមាជិកអង្គការទាំងនោះ ដើម្បី
ផ្សាយដំណឹងល្អ ព្រោះមនុស្សនឹងឆាប់ជឿទុកចិត្តអ្នក ។ ការ
ផ្សាយដំណឹងល្អនឹងកាន់តែមានប្រសិទ្ធិភាព បើសិនជាមាន
ទំនាក់ទំនងជាមិត្តភក្តិ និង មានការទុកចិត្តគ្នា ហើយ ។

តើនៅទីកន្លែងនោះ មានអង្គការ ឬ សមាគមអ្វីខ្លះ ?

- សូមគូសពីក្រោមអង្គការទាំងឡាយណា ដែលអ្នកអាចចូលរួមជាសមាជិកបាន ដើម្បីផ្សាយដំណឹងល្អ និង អង្គការណាដែលពួកគ្រីស្តជនអាចធ្វើការងារក្នុងនោះបាន ដោយមិនប៉ះពាល់ដល់ជំនឿរបស់ខ្លួន ។

  ពិនិត្យមើលពតិមានដែលអ្នកប្រមូលបាន ហើយសូមសរសេរពីអ្វីៗដែលអ្នកត្រូវអធិស្ឋាន :

តើអ្នកមានផែនការដូចម្តេចខ្លះ សំរាប់ទាក់ទងជាមួយគេ តាមរបៀបដែលស្របនឹងវប្បធម៌ និង សេចក្តីត្រូវការរបស់គេ ?

BETA VERSION released prior to proofreading

គោលការណ៍ ទី ៨
ធ្វើពិធីជ្រមុជទឹក និង ទទួលជាសមាជិក



គោលដៅ

- ធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ហើយទទួលពួកគេជាសមាជិករបស់ក្រុមជំនុំព្រះគ្រីស្ត ។
- ធ្វើពិធីកាច់នំបុ័ងក្នុងឋានៈជាក្រុមជំនុំថ្មី ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

សង្ខេបគោលដៅ :

វាយតម្លៃការងាររបស់ក្រុមបង្កើតក្រុមជំនុំ ដើម្បីអោយអ្នកអាច
ធ្វើអោយមធ្យោបាយរបស់អ្នកកាន់តែប្រសើរឡើង ស្របតាមការ
វាយតម្លៃនោះ ។

*«យើងមិនត្រូវខឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិនបើ
យើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់ យើងនឹងច្រូតបាន
ផលជាមិនខាន ។ » (កាឡាទី ៦:៩)*



BETA VERSION released prior to proofreading

សង្ខេបអំពីគោលដៅ

ទាក់ទងអោយស្គាល់មនុស្ស ហើយកសាងទំនាក់ទំនង
ជាមួយមនុស្សសំខាន់ៗនៅក្នុងសហគម៌ ។

*«ក្រោយមកលោកប៉ូលបានចាកចេញពីក្រុងអាថែន ធ្វើដំណើរ
ឆ្ពោះទៅក្រុងកូរិនថូស នៅក្រុងនោះ លោកបានជួបជនជាតិ
យូដាម្នាក់ឈ្មោះអគីឡាស ជាអ្នកស្រុកប៉ុនតុស ។ លោក អគីឡាស និង
នាងព្រីស៊ីឡាជាភរិយា ទើបនឹងមកពីស្រុកអ៊ីតាលី ព្រោះព្រះចៅអធិរាជក្លូដ
បានចេញបញ្ជាអោយជនជាតិយូដា ទាំងអស់ចេញពីក្រុងរ៉ូម
លោកប៉ូលទៅទាក់ទងនឹងអ្នកទាំងពីរ ហើយស្នាក់នៅ និង ធ្វើការជាមួយគេ
ព្រោះលោកមានមុខរបរ ដូចគ្នា គឺត្បាញក្រណាត់សំរាប់បោះជំរំ » ។
(កិច្ចការ ១៨:១-៣)*

គោលការណ៍ណែនាំ ទី ៤
ប្រកាសជ័យជំនះរបស់ព្រះគ្រីស្ត ដោយការអធិស្ឋាន



គោលដៅ :

- ក្នុងឋានៈជាក្រុមបង្កើតក្រុមជំនុំ ចាប់ផ្តើមសង្គ្រាមខាងព្រលឹងវិញ្ញាណ តាមរយៈការអធិស្ឋានយ៉ាងមុតមាំ ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

BETA VERSION released prior to proofreading



ល្អដូចនេះ ដោយទៅសួរសុខទុក្ខ ជួយធុរៈ ចូលរួមក្នុងការរស់នៅ
របស់ក្រុមគ្រួសារ បង្ហាញការអត់ទោស និង បង្ហាញការសុំទោស
ចំពោះសមាជិកក្រុមគ្រួសារ ។

- ពិចារណាអំពីសំនួរនេះ: តើមានការផ្សាយដំណឹងល្អ កាន់តែច្រើន ឬ
  លែងសូវមាន ?

  ត្រូវផ្សាយដំណឹងល្អតម្រង់ទៅសាច់ញាតិ និង មិត្តភ័ក្តិរបស់ពួក
  អ្នកជឿថ្មី ។ ក្រុមជំនុំថ្មីខ្លះ
  ឆាប់ទុកចិត្តលើការប្រជុំថ្វាយបង្គំ ជាសាធារណៈខ្លាំងពេក
  ក៏ឈប់ផ្សាយដំណឹងល្អ ។ សូមកុំឈប់
  ផ្សាយដំណឹងល្អដោយសារអ្នកបានចាប់ផ្តើមធ្វើការប្រជុំថ្វាយបង្គំ
  ឡើយ គឺសូមបន្តផ្សាយដំណឹងល្អថ្វាយព្រះគ្រីស្ត ដោយស្វាហាប់
  តទៅទៀត ។

- ពិចារណាអំពីសំនួរនេះ : តើក្រុមបង្កើតក្រុមជំនុំមាន
  បញ្ហាណាខ្លះដែលត្រូវដោះស្រាយដែរឬទេ ?

BETA VERSION released prior to proofreading

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ការចូលធ្វើសង្គ្រាមខាង
ព្រលឹងវិញ្ញាណរបស់ក្រុមអ្នក និង ជំរាបក្រុមអធិស្ឋានពីសំណូម
ពរអធិស្ឋានផ្សេងៗទៀត) ។



«ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹងវត្ថុ សក្តិសិទ្ធិ ទល់នឹងអ្វីៗដែលមានអំណាច ទល់នឹងមេត្រួតត្រាក្នុង លោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់នឹងឥទ្ធិពលអរូបិយដ៏អាក្រក់ ទាំងឡាយ ដែលនៅស្ថានលើដែរ ។ ហេតុនេះ ចូរបងប្អូនប្រើ គ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ទៅ ដើម្បីអោយបង ប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហរឈរប៉ឹងដដែល ដោយបានប្រើគ្រប់មធ្យោបាយ» ។ (អេភេសូ ៦:១២-១៣)

ប្រភពនៃជ័យជំនះរបស់យើង មកដល់ដោយសារ «ព្រះលោហិត របស់កូនចៀម» (វិវរណៈ ១២:១១) ។ ដោយសារព្រះលោហិត នេះ យើងត្រូវបានព្រះជាម្ចាស់រំដោះយើងឱ្យរួចពីអំណាចរបស់មារ សាតាំង (កូឡូស ២:១៥, ហេប្រឺ ២:១៤-១៥)។ ពេលព្រះយេស៊ូ មានព្រះជន្មរស់ឡើងវិញ ព្រះអម្ចាស់ត្រូវបានព្រះជាម្ចាស់លើក តម្កើងជា «ព្រះបុត្រារបស់ព្រះជាម្ចាស់ ប្រកបដោយឫទ្ធានុភាព» (រ៉ូម ១:៤) ។ យើងនឹងពង្រីកព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុង សហគមន៍ ដោយការអធិស្ឋាន ដូចជា «សូមអោយព្រះរាជ្យទ្រង់ បានមកដល់...») និង ការផ្សាយដំណឹងល្អ ។

BETA VERSION released prior to proofreading

- ពិចារណាអំពីសំនួរនេះ : តើអ្នកជឿថ្មីខ្វះសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមកឬទេ ?

  បើអ្នកជឿថ្មីខ្វះក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក អ្នកត្រូវរៀបចំសកម្មភាពសង្គមអោយបានច្រើនជាងមុន ។ ត្រូវរៀបចំពេលសំរាប់ការបរិភោគអាហារជាមួយគ្នា ដំណើរទៅសំរាកលំហែកាយជាមួយគ្នា សកម្មភាពកីឡា ឬ សកម្មភាពសង្គមផ្សេងៗទៀត សំរាប់ពួកអ្នកជឿថ្មី បើស្រួលធ្វើ ។ ត្រូវធ្វើអោយពួកគេមើលឃើញថាមិនយូរទេ ពួកគេនឹងក្លាយជាក្រុមជំនុំស្វាហាប់ ពេញដោយអំណរ និង ពេញដោយសេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ត និង ចំពោះមនុស្សឯទៀត ។

- ពិចារណាអំពីសំនួរនេះ : តើអ្នកជឿថ្មីនៅតែរក្សាទំនាក់ ទំនង ពេញដោយការគោរពជាមួយក្រុមគ្រួសារ និង មិត្តភ័ក្តិ ពួកគេដែលមិនទាន់ជឿដែរឬទេ ?

  បន្តលើកទឹកចិត្តពួកអ្នកជឿថ្មីអោយរក្សាទំនាក់ទំនងពេញដោយក្តីស្រឡាញ់ជាមួយក្រុមគ្រួសារ និង មិត្តភ័ក្តិពួកគេ ដែលមិនទាន់ជឿ ។ ធ្វើអោយមានទំនាក់ទំនងល្អដូចនេះ នឹងនាំឱ្យសាច់ញាតិរបស់អ្នកជឿថ្មី សប្បាយរីករាយដែលឃើញអ្នកជឿថ្មីបានថ្វាយខ្លួនទៅព្រះយេស៊ូ ។ ពួកអ្នកជឿថ្មី ត្រូវបណ្តុះអោយមានទំនាក់ទំនង

យោបល់សំរាប់ការចាប់ផ្តើមធ្វើសង្គ្រាម ខាងព្រលឹងវិញ្ញាណ តាមរយៈការអធិស្ឋាន :

- អធិស្ឋានជាមួយសមាជិកក្រុមបង្កើតក្រុមជំនុំរបស់អ្នក (និង តមអាហារ បើសិនជាអ្នកមានទម្លាប់តមអាហារដែរ) ។

  អធិស្ឋានដើម្បីបំបាក់ឫទ្ធានុភាពរបស់មារសាតាំង និង ដើម្បីចូលទៅវាយប្រយុទ្ធកន្លែងដែលវាបានកាន់កាប់ និង អធិស្ឋានទូលសូមអោយព្រះជាម្ចាស់បង្ហាញឫទ្ធានុភាពរបស់ព្រះអង្គ ដោយធ្វើអោយមនុស្សច្រើននាក់បានសង្គ្រោះ ។

  នៅក្នុងព្រះគម្ពីរ មុននឹងបានទទួលជ័យជំនះធំៗ អ្នកបំរើព្រះជា-ម្ចាស់ តែងតែអធិស្ឋាន និង តមអាហារច្រើនណាស់ ។ ក្នុងការបង្កើតក្រុមជំនុំ ពេលមកដល់ចំណុចនេះ ការដែលសំខាន់ គឺត្រូវអធិស្ឋានអោយបានខ្លាំងក្លា មុននឹងធ្វើការផ្សាយដំណឹងល្អ ។ នៅក្នុងតំបន់ និង ទីក្រុងនិមួយៗ តែងតែមានកងកម្លាំងអារក្សដែលគ្រប់គ្រង និង មានឥទ្ធិពលលើមនុស្ស ដើម្បីកុំអោយពួកគេអាចទទួលព្រះគ្រីស្តជាព្រះអម្ចាស់ (២ កូរិនថូស ៤:៤) ។ បើយើងអធិស្ឋាន ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងឆ្លើយតប ដោយរំដោះពួកអ្នកដែលត្រូវអារក្សគ្រប់គ្រង
  (អេភេសូ ៦:១០-១២ និង ១៨) ។

BETA VERSION released prior to proofreading

បើមនុស្សបង្ហាញថា ចាប់អារម្មណ៍លើដំណឹងល្អ ប៉ុន្តែ មិនចង់ចូលរួមជាមួយគ្នា អ្នកប្រហែលជាត្រូវផ្សាយដំណឹងល្អតម្រង់ទៅក្រុមមនុស្សតែមួយ ឬ មនុស្សតែមួយប្រភេទ ឬ កន្លែងណាមួយ ។ ក្រុមមនុស្សផ្សេងៗមិនសូវចូលរួមគ្នាល្អ ក្នុងក្រុមជំនុំថ្មីមួយទេ ។ ឧទាហរណ៍ ក្រុមជនអន្តោប្រវេស្ត (អ្នកដែលចេញពីស្រុកកំណើតទៅរស់នៅប្រទេសមួយផ្សេងទៀត) ទោះបីជាចេះភាសាមូលដ្ឋានក៏ដោយ ក៏នៅតែពេញចិត្តនឹងថ្វាយបង្គំជាភាសាកំណើតរបស់គេជាងដែរ ។ ហេតុនេះហើយបានជា អ្នកត្រូវសំរេចចិត្តថា ផ្សាយដំណឹងល្អតម្រង់ទៅតែក្រុមជនអន្តោប្រវេស្ត ឬ ទៅតែពួកអ្នកដែលភាសាមូលដ្ឋាន ជាភាសាកំណើតរបស់ពួកគេ ។ អ្នកជឿថ្មីជាច្រើន ចេញពីក្រុមជំនុំមួយ ដោយសារតែពួកគេមិនអាចទម្លាប់ខ្លួនទៅតាមវប្បធម៌ ដែលមានភាគច្រើននៅក្នុងក្រុមជំនុំនោះ ។ បើជួបប្រទះបញ្ហាដូចនេះ ត្រូវរៀបចំឡើងវិញ ដើម្បីបង្កើតក្រុមជំនុំ ឬ ក្រុមតូចតាមផ្ទះ ដែលពួកអ្នកជឿថ្មីអាចចូល រួមដោយចុះសម្រុងជាមួយក្រុមគ្រួសារក្រុមជំនុំបាន ។

បើអ្នកជួបកាលៈទេសៈដូចនេះ តើអ្នកនឹងផ្សព្វផ្សាយដំណឹងល្អតម្រង់ទៅក្រុមមនុស្សណាមួយ ?

- រៀបចំការអធិស្ឋានចាំយាមមួយយប់ ឬ កំណត់ពីរបី ថ្ងៃសំរាប់អធិស្ឋាន និង តមអាហារ ។

- សូមជូនពតិមានទៅក្រុមជំនុំម្តាយរបស់អ្នកជាប់ជានិច្ច ដើម្បីអោយពួកគេជួយអធិស្ឋានទូលអង្វរសំរាប់ក្រុមអ្នក ។

- ក្នុងឋានៈជាអ្នកបង្កើតក្រុមជំនុំ សូមធ្វើជាគំរូ ដោយមាន ការិយាថ្លៃថ្នូរ ដែលជាផ្នែកសំខាន់បំផុតមួយរបស់គ្រឿង សស្ត្រាវុធខាងព្រលឹងវិញ្ញាណរបស់យើង (១ ធីម៉ូថេ ៣:៨-១៦ និង អេពេសូ ៥:១៣-១៧) ។

ទោះជាអ្នកអធិស្ឋានតាមរបៀបណាក៏ដោយ ក៏អ្នកត្រូវធ្វើយ៉ាងណា អោយសហការីរបស់អ្នក អធិស្ឋានទូលអង្វរយ៉ាងមុតមាំទៅព្រះ ជាម្ចាស់ និង សំរាប់មនុស្សដែរ ។

តើអ្នកកំពុងធ្វើអ្វី ដើម្បីធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណប្រភេទ នេះ ?

BETA VERSION released prior to proofreading

បើអ្នកឃើញថា មនុស្សដូចជាចាប់អារម្មណ៍លើដំណឹងល្អ ប៉ុន្តែ ពួកគេពិបាកនឹងយល់ដំណឹងល្អព្រះយេស៊ូ អ្នកត្រូវលើកទឹកចិត្ត ពួកគេ ដោយ :

- ពេលដែលអ្នកចែកចាយ ឬ បង្រៀន ធ្វើយ៉ាងណា ដើម្បី បញ្ជាក់អំពីព្រះយេស៊ូគ្រីស្ត ។ មារសាតាំងតែងតែបង្វែរ យើងអោយនិយាយពីសេចក្តីអ្វីៗផ្សេងទៀត ដែលមិននាំ អោយមនុស្សបានសង្គ្រោះទេ ។
- ជួយពួកគេអោយបញ្ជាក់និយាយអំពីជំនឿរបស់គេ ដោយ អោយពួកគេឆ្លើយសំនួរ ដូចជា : « តើព្រះគ្រីស្តបានធ្វើអ្វី ដើម្បីសង្គ្រោះយើង ? » ។ល។ ព្រមទាំងអោយពួកគេ និទានរឿង ព្រះគម្ពីរអំពីដំណឹងល្អប្រាប់ក្រុមគ្រួសាររបស់ ពួកគេ ។
- អធិស្ឋានជាមួយពួកគេ (អ្នកអាចសូមអោយពួកគេអធិស្ឋាន ដែរ ដោយថាតាមអ្នកមួយឃ្លាម្តងៗ) ។
- ជួយពួកគេអោយទន្ទេញខព្រះគម្ពីរ ។

- ពិចារណាអំពីសំនួរនេះ : តើមនុស្សដែលបង្ហាញថា ចាប់អារម្មណ៍លើដំណឹងល្អ ចង់ចូលរួមជាមួយអ្នកឯទៀត ដែលចាប់អារម្មណ៍លើដំណឹងល្អដែរឬទេ ?

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ការវាយតម្លៃការងារ
របស់ក្រុមបង្កើតក្រុមជំនុំ និង ជំរាបពួកគេអំពីសំណូមពរអធិស្ឋាន
ផ្សេងៗទៀត) ។

យោបល់សំរាប់ការពិនិត្យមើលលទ្ធផល :

- ពិចារណាអំពីសំនួរនេះ : តើមនុស្សចាប់អារម្មណ៍អំពី ដំណឹងល្អ និង
ទទួឡជឿដំណឹងល្អនោះដែរឬទេ ?

  ធ្វើការងារដើម្បីអោយមនុស្សទទួលជឿដំណឹងល្អ ។ បើមនុស្ស
  មិនចាប់អារម្មណ៍អំពីដំណឹងល្អទេ បន្តទូលសូមអោយព្រះជាម្ចាស់
  ដឹកនាំការដែលក្រុមបង្កើតក្រុមជំនុំធ្វើ ហើយប្រើមធ្យោបាយផ្សេង
  ទៀត ដែលមានប្រសិទ្ធិភាព ។

  *«ខ្ញុំធ្វើអោយបានដូចមនុស្សទាំងអស់ក្នុងគ្រប់កាលៈទេសៈ ដើម្បី
  សង្គ្រោះអ្នកខ្លះតាមគ្រប់មធ្យោបាយទាំងអស់ » ។*
  (១ កូរិនថូស ៩:២២)

- ពិចារណាអំពីសំនួរនេះ : តើមានមនុស្សដែលបង្ហាញថា
ចាប់អារម្មណ៍អំពីដំណឹងល្អ ប៉ុន្តែ មិនយល់ ឬ មិនទទួល
សេចក្តីពិតជាមូលដ្ឋានទាំងឡាយរបស់ដំណឹងល្អឬទេ ?

BETA VERSION released prior to proofreading

សង្ខេបអំពីគោលដៅ

រៀបចំការអធិស្ឋានសំរាប់ធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ ។

*«ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹងវត្ថុ សក្តិសិទ្ធិ
ទល់នឹងអ្វីៗដែលមានអំណាច ទល់នឹងមេត្រួតត្រាក្នុង
លោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់នឹងឥទ្ធិពលអួរបិយដ៏
អាក្រក់ទាំងឡាយ ដែលនៅស្ថានលើដែរ ។។។ ចូរអធិស្ឋានគ្រប់
ពេលវេលា តាមការណែនាំរបស់ព្រះវិញ្ញាណ ដោយប្រើទាំង ពាក្យអធិស្ឋាន
ទាំងពាក្យអង្វរគ្រប់យ៉ាង ។។។ » (អេភេសូ ៦:១២, ១៨)*

គោលការណ៍ណែនាំ ទី ៥
រកមនុស្សដែលចាប់អារម្មណ៍អំពីដំណឹងល្អ



គោលដៅ :

- ទាក់ទងជាមួយមនុស្ស ដែលចាប់អារម្មណ៍អំពីដំណឹងល្អ ជាពិសេស មេគ្រួសារ ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

BETA VERSION released prior to proofreading

គោលការណ៍ ទី ៧
វាយតម្លៃលទ្ធផល



គោលដៅ

- វាយតម្លៃការងាររបស់ក្រុមបង្កើតក្រុមជំនុំ

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

ដែលហួសសមត្ថភាពពួកគេ ។ ត្រូវធ្វើអ្វីៗគ្រប់យ៉ាងតាមរបៀប
ដែលពួកគេអាចធ្វើតាមបានភ្លាមៗ ដើម្បីផ្សាយដំណឹងល្អបន្តទៅ
អ្នកឯទៀត ។ ការនិទានរឿងដកស្រង់ពីព្រះគម្ពីរ ដែលជា
ឧទាហរណ៍បំភ្លឺអំពីការប្រោសលោះក្នុងព្រះគ្រីស្ត តាមធម្មតាជា
របៀបស្រួលបំផុត សំរាប់ធ្វើអោយដំណឹងល្អហូរពីមិត្តភ័ក្តិមួយ
ទៅមិត្តភក្តិមួយទៀត និង ពីគ្រួសារមួយ ទៅគ្រួសារមួយទៀត ជាបន្ត ។

សង្ខេបអំពីគោលដៅ :

ពន្យល់ដំណឹងល្អដល់ក្រុមគ្រួសារ ដែលមានបំណងចង់ស្តាប់ (ជាពិសេស
កំណត់រកមនុស្សដែលអ្នកនឹងបង្រៀន សំភារៈដែល អ្នកនឹងប្រើ និង
វិធីដែលអ្នកនឹងអនុវត្ត) ។

*«ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើង
បានស្តាប់នោះ កើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ត » ។ (រ៉ូម ១០:១៧)*

BETA VERSION released prior to proofreading

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ការខំប្រឹងប្រែងរបស់ អ្នក
ដើម្បីរកមនុស្សដែលបើកចិត្តទទួលដំណឹងល្អ ជាពិសេស មេគ្រួសារ
ហើយជំរាបក្រុមអធិស្ឋានអំពីសំណូមពរអធិស្ឋាន ផ្សេងៗទៀត) ។

*«ក្នុងចំណោមសិស្សទាំងពីរ ដែលបានឮពាក្យរបស់លោកយ៉ូហាន
ហើយតាមព្រះយេស៊ូទៅនោះ មានម្នាក់ឈ្មោះអន់ដ្រេជាប្អូនរបស់
លោកស៊ីម៉ូនពេត្រុស ស៊ីម៉ូនសិលា ។ គាត់ទៅជួបលោកស៊ីម៉ូន
ជាបងមុនគេប្រាប់ថា÷ «យើងបានរកព្រះមេស្ស៊ីឃើញហើយ !»
(ពាក្យ "មេស្ស៊ី" នេះប្រែថា "ព្រះគ្រីស្ត") ។ គាត់ក៏នាំលោក
ស៊ីម៉ូនទៅគាល់ព្រះយេស៊ូ » ។ (យ៉ូហាន ១:៤០-៤២)*

(បើអ្នកមានទំនាក់ទំនងល្អជាមួយមនុស្ស ដែលចាប់អារម្មណ៍នឹង ដំណឹងល្អហើយ
សូមបន្តធ្វើតាមគោលការណ៍ណែនាំបន្ទាប់ទៀត) ។

យោបល់អំពីរបៀបទាក់ទងមនុស្ស ដែលចាប់អារម្មណ៍នឹងដំណឹងល្អ :

- ទាក់ទងជាមួយមនុស្សច្រើន ដើម្បីស្វែងរកពួកអ្នកដែល
  ចាប់អារម្មណ៍អំពីដំណឹងល្អ ។

អ្នកនេសាទត្រីបង់សំណាញ់អោយរីកធំ ដើម្បីចាប់ត្រីអោយបានច្រើនយ៉ាងណា អ្នក និង សហការីរបស់អ្នកក៏ត្រូវទាក់ទងមនុស្សជាច្រើនយ៉ាងនោះដែរ ដើម្បីរកមនុស្សដែលចាប់អារម្មណ៍អំពីដំណឹងល្អ ។ ក្រោយមក ទើបយើងទាញសំណាញ់មកវិញ (ម៉ាថាយ ៤:១៩, កិច្ចការ ១៣:៣២-៣៤) ។

តើមនុស្សច្រើនតែជួបជុំគ្នា ដើម្បីជជែកគ្នា ឬ ដើម្បីសំរាកកំសាន្តនៅកន្លែងណា ?

តើអ្នកអាចជជែកជាមួយពួកគេនៅទីនោះឬទេ ?

- ទៅសួរសុខទុក្ខក្រុមគ្រួសារ ដោយទៅជាមួយមនុស្សដែលពួកគេធ្លាប់ស្គាល់ ។ នោះពួកគេនឹងទុកចិត្តជាង ហើយទទួលអ្នកដោយបើកចិត្តខ្លាំងជាង ។

  បើអាចធ្វើបាន ត្រូវសូមអោយមនុស្សដែលគេគោរពរាប់អាន និងដែលនៅជិតខាងទៅជាមួយអ្នក ។ បើទោះជាគាត់មិនមែនជាគ្រីស្តជនក៏ដោយ ក៏គាត់នឹងជួយអោយគេទទួលអ្នកដែរ ។ នៅ

BETA VERSION released prior to proofreading

- នៅក្នុងការប្រជុំធំ ត្រូវធ្វើទីបន្ទាល់ ច្រៀងចំរៀងសាមញ្ញៗ និងរៀបចំកត់ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកដែលចង់ស្តាប់ដំណឹងល្អព្រះយេស៊ូបន្តទៀត ។

  នៅក្នុងការប្រជុំដែលមានមនុស្សច្រើន សូមកុំរាប់ថាមនុស្សដែលគ្រាន់តែលើកដៃ ចុះហត្ថលេខាលើប័ណ្ណ ឬ ដើរទៅមុខ ជាមនុស្សដែលពិតជាទទួលជឿលើព្រះយេស៊ូនោះឡើយ ។ ព្រោះការសំរេចចិត្តដូចនេះ ច្រើនតែមិនទាន់ស៊ីជំរៅទេ ។ សូមយកចិត្តទុកដាក់នាំមនុស្សអោយយល់ពីដំណឹងល្អ គឺកែប្រែចិត្តគំនិត ជឿ ហើយទទួលពិធីជ្រមុជទឹក ។

សេចក្តីសង្ខេប : សូមចៀសវាងកុំនិយាយពីទស្សនៈវិជ្ជា ឬ គោលជំនឿជ្រៅៗ ។ មនុស្សតិចណាស់ ដែលថ្វាយខ្លួនទៅព្រះគ្រីស្តតាមរយៈការស្វែងរកហេតុផលតាមគំនិតប្រាជ្ញា ។ ត្រូវទុកអោយពួកគេមើលឃើញថា អ្នកស្រឡាញ់ព្រះគ្រីស្ត និង ថាព្រះអង្គស្រឡាញ់ពួកគេ ។ និយាយប្រាប់គេពីសេចក្តីដែលព្រះយេស៊ូ មានបន្ទូលហើយនិយាយប្រាប់គេពីហេតុការណ៍ប្រវត្តិសាស្ត្រនៃ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ (លូកា ២៤:៤៦-៤៨) ។ រៀបរាប់ពីទីបន្ទាល់របស់អ្នកផ្ទាល់ អំពីកិច្ចការដែលព្រះគ្រីស្តបានធ្វើដើម្បីអ្នក ។ សូមកុំប្រើវិធី ឬ គ្រឿងប្រដាប់

មែនជាគ្រីស្តជន បដិសេធគេទេ ។ តាមធម្មតា មនុស្សអាច សំរេចចិត្តបានពិត ដោយជជែកពិភាក្សា និង គិតគូរជាមួយ សមាជិកគ្រួសារ និង មិត្តភក្តិជិតស្និទ្ធរបស់គេ ។

- ចាប់ពីពេលដែលពួកគេបានថ្វាយខ្លួនទៅព្រះគ្រីស្ត អញ្ជើញ ពួកគេអោយបោះបង់ចោលការធ្វើអំពើបាប និង ការ ប្រតិបត្តិតាមមន្តអាគមគ្រប់យ៉ាង ព្រមទាំងព្រះផ្សេងទៀត ទាំងអស់ គឺ :

  - ទទួលស្គាល់អំពើផ្សេងៗនេះក្នុងជីវិត ហើយបដិសេធ អ្វីៗ ទាំងអស់នោះ ។
  - បំផ្លាញវត្ថុដែលទាក់ទងនឹងអបិយ៍ជំនឿ (មន្តអាគម) ទាំងអស់ ហើយទទួលយកសេរីភាពពេញលេញក្នុង ព្រះគ្រីស្ត ដើម្បីអោយរួ ចពីឫទ្ធានុភាពរបស់បិសាច ដែលទាក់ទងនឹងវត្ថុទាំងនោះ ។

  - ជួយពួកអ្នកដែលកែប្រែចិត្តគំនិត អោយអាចទូលសូម ព្រះជាម្ចាស់អោយអត់ទោសអោយគេ និង ជំរះសំអាត គេដោយសារព្រះលោហិតរបស់ព្រះគ្រីស្ត និង អោយ បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ។

- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ប្រោសអ្នកជំងឺ ។

BETA VERSION released prior to proofreading

ពេលដែលអ្នកទាក់ទងជាមួយមនុស្ស សូមបង្ហាញសេចក្តីសឡាញ់ របស់ព្រះគ្រីស្តដល់អ្នកមានសេចក្តីត្រូវការ និង អធិស្ឋានសំរាប់ អ្នកជំងឺដែរ ។

- ស្វែងរកមេគ្រួសារ ដែលចង់ស្តាប់ដំណឹងល្អ ។

  មេគ្រួសារជាគន្លឹះសំរាប់នាំគ្រួសារទាំងមូលៗ និង សហគមន៍ទាំង មូលៗមកថ្វាយព្រះយេស៊ូគ្រីស្ត ។ បើយើងចៀសវាងមេគ្រួសារ យើងនឹងធ្វើអោយពួកអ្នកដែលត្រូវការស្តាប់ដំណឹងល្អ បែកបាក់ ជាមួយគ្រួសារ និង មានឧបសគ្គ ។ មេគ្រួសារខ្លះ ក៏អាចក្លាយ ជាអ្នកដឹកនាំក្រុមជំនុំដែរ ។

  តើអ្នកអាចទៅរកមេគ្រួសារនៅផ្ទះគាត់ នៅពេលណាខ្លះ ?

- ព្រោះគ្រាប់ពូជលើដីគ្រប់ប្រភេទ ប៉ុន្តែ ផ្តង់ការងារទៅលើដី ដែលមើលឃើញថា អោយផលច្រើនជាងគេ ពេលច្រូតកាត់ (ម៉ាថាយ ១៣:៤-៨, ១៨-២៣) ។

សូមកុំបង្ខាតពេលច្រើនជាមួយពួកអ្នកដែលឆ្លើយតបជាការប្រឆាំង ជំទាស់ ឬ មិនចាប់អារម្មណ៍ (ម៉ាថាយ ៧:៦) ។ លោកប៉ូល ទៅផ្សាយដំណឹងល្អដល់ពួកសាសន៍ដទៃ ពីព្រោះពួកគេបើកចិត្ត ទទួលដំណឹងល្អជាងពួកយូដា (កិច្ចការ ១៨:៦) ។

- ដើម្បីបង្កើតបានក្រុមជំនុំរឹងមាំ ត្រូវនាំគ្រួសារទាំងមូលៗដែល នៅជិតខាងគ្នា មកថ្វាយព្រះគ្រីស្ត មិនមែននាំតែមនុស្ស ម្នាក់ៗទេ ។

  គ្រួសារទាំងមូលៗ ជាគន្លឹះសំរាប់នាំសហគមន៍ទាំងមូលៗមកថ្វាយ ព្រះយេស៊ូគ្រីស្ត ។ បើយើងនាំមនុស្សម្នាក់ៗមកថ្វាយព្រះគ្រីស្ត ដាច់ចេញពីគ្រួសាររបស់គេ យើងនឹងធ្វើអោយពួកអ្នកដែលត្រូវ ការស្តាប់ដំណឹងល្អបែកបាក់គ្នា និង មានឧបសគ្គ ។ អ្នកត្រូវរៀប ចំផែនការផ្សាយដំណឹងល្អដល់គ្រួសារជាច្រើន ។

- ផ្សាយដំណឹងល្អ តាមរបៀបដែលសក្តិសមនឹងព្រះបុត្រា ព្រះជាម្ចាស់ ។

  ពេលខ្លះ ពួកគ្រីស្តជនធ្វើអោយមនុស្សមានប្រតិកម្មមិនល្អចំពោះ ការផ្សាយដំណឹងល្អ ដោយប្រើរបៀបលេងសើចឥតបានការ ។

BETA VERSION released prior to proofreading

- បុទ្ធានុភាពសំរាប់បំរើអ្នកដទៃ និង សម្រាលទុក្ខលំបាក របស់ពួកគេ
- ក្រុមគ្រួសារមានជីវិតប្រសើរជាងពីមុន
- ការចូលរួមចំណែកក្នុងសេចក្តីស្រឡាញ់របស់ប្រជា-រាស្ត្ររបស់ព្រះជាម្ចាស់
- ការអាចស្គាល់អត្ថន័យនៃជីវិត
- សេចក្តីសុខសាន្តក្នុងចិត្តគំនិត និង មនសិការជ្រះថ្លា
- ការដែលព្រះជាម្ចាស់ធ្វើអោយសេចក្តីសង្ឃឹមដ៏ខ្លាំងក្លា របស់ពួកគេបានសំរេច និង ផ្គត់ផ្គង់គ្រប់សេចក្តីត្រូវ ការរបស់ពួកគេ
- អំណរដែលបានពីការស្តាប់បង្គាប់ព្រះគ្រីស្ត និង ការផ្សាយដំណឹងល្អ ។

- ពន្យល់អ្នកជឿថ្មីថា ពួកគេមុខជាត្រូវគេបៀតបៀន ប៉ុន្តែ ព្រះជាម្ចាស់គង់ជាមួយពួកគេ ដើម្បីប្រទានកម្លាំងអោយ ពួកគេ ព្រមទាំងការពារពួកគេផងដែរ ។

- លើកទឹកចិត្តពួកអ្នកដែលស្តាប់ដំណឹងល្អ ពិភាក្សាគ្នាអំពី ការសំរេចចិត្តដើរតាមព្រះគ្រីស្ត ។

  ជំរុញអោយក្រុមគ្រួសារ និង មិត្តភក្តិទទួលជឿព្រះអង្គជាមួយគ្នា ។ ធ្វើដូចនេះ មនុស្សអាចថ្វាយខ្លួន ដោយមិនត្រូវគ្រួសារដែលមិន

បង្ហាញសេចក្តីស្រឡាញ់ចំពោះគ្រួសារ និង មិត្តភក្តិរបស់គេ ។ សូមទៅជាមួយអ្នកនោះ ដើម្បីបង្ហាញគាត់ពីរបៀបផ្សាយដំណឹងល្អ ប្រាប់គ្រួសារ និង មិត្តភក្តិរបស់គាត់ ។ បើសិនជាអ្នកជឿថ្មីលែង មានទំនាក់ទំនងជាមួយមិត្តភក្តិរបស់គេ ការផ្សាយដំណឹងល្អនឹង ត្រូវរាំងស្ទះហើយ ។

- ជួបប្រជុំជាមួយពួកអ្នករៀនអោយបានទៀងទាត់ ។

- ពេលទៅជួបជាមួយមនុស្ស ត្រូវប្រព្រឹត្តដោយសុភាព- រាបសារ និង គួរសម ។

  ស្លៀកពាក់អោយបានត្រឹមត្រូវ និង សមរម្យ ហើយកុំទៅសួរ សុខទុក្ខ ពេលបាយ ។

- រាប់អានគ្នាជាមិត្តភ័ក្តិ ។

- សូមពន្យល់អំពីផលប្រយោជន៍ ដែលអាចទទួលបានពីការ ប្រតិបត្តិតាមព្រះគ្រីស្ត គឺ :

  - ការសង្គ្រោះ និង ការលើកលែងទោស
  - ព្រះវិញ្ញាណដ៏វិសុទ្ធ និង ជីវិតអស់កល្ប
  - បុទ្ធានុភាពដើម្បីឈ្នះលើអំពើបាប និង សេចក្តីអាក្រក

BETA VERSION released prior to proofreading

របៀបដូចនេះ ជំរុញអោយមនុស្សគេចចេញពីដំណឹងល្អ និង ចំអក អំពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ និង របៀបរបស់ព្រះអង្គ ។

- ប្រើវិធីផ្សាយដំណឹងល្អ ដែលពួកអ្នកជឿថ្មីអាចធ្វើតាមអ្នក ដោយស្រួល ។

  នៅពេលអនាគត ពួកអ្នកដែលអ្នកនាំមកទទួលជឿព្រះគ្រីស្ត នឹង ចែកចាយដំណឹងល្អប្រាប់មនុស្សឯទៀត ។ បើអ្នកប្រើរបៀបដែល មានតំលៃថ្លៃ ឬ សាំញ៉ាំពិបាកអនុវត្ត នោះពួកអ្នកជឿរបស់ក្រុមជំនុំ ថ្មី នឹងមិនអាចធ្វើតាមគំរូអ្នកទេ ។ ពួកគេមិនចាំបាច់មានចំណេះ ដឹងកិរិតខ្ពស់ ឬ ជំនាញបច្ចេកទេសខ្ពស់ ដើម្បីអាចផ្សាយដំណឹង ល្អប្រាប់មនុស្សឯទៀតទេ ។

- នៅក្នុងសង្គម ដែលប្រទូស្តរាយនឹងដំណឹងល្អ សូមកុំប្រើ របៀបផ្សាយដំណឹងល្អ ដែលទាក់ទាញអារម្មណ៍របស់ រដ្ឋអំណាចទាំងឡាយ ។

- ជ្រើសរើសយករបៀបដែលនាំអោយអាចផ្សាយដំណឹងល្អ ត្រូវចិត្តគំនិតរបស់មនុស្ស ។

ត្រូវផ្លាស់ប្តូរបៀបទៅតាមទីកន្លែង ស្របតាមវប្បធម៌ និង កាលៈទេសៈមូលដ្ឋាន ។ នេះជាយោបល់ខ្លះ :

- ទៅសួរសុខទុក្ខ និង អញ្ជើញពួកគេអោយសិក្សាព្រះគម្ពីរនៅតាមផ្ទះ ។
- និយាយរឿងនៅក្នុងព្រះគម្ពីរប្រាប់អ្នកជិតខាង ។
- ប្រកាសព្រះបន្ទូលតាមផ្លូវ ។
- អធិស្ឋានសំរាប់អ្នកជំងឺ ឬ ធ្វើកម្មវិធីពិសេស ដើម្បីអធិស្ឋានអោយអ្នកជំងឺ ។
- រៀបចំកម្មវិធីផ្សាយដំណឹងល្អ សំរាប់សហគមន៍ទាំងមូល ។
- ធ្វើការអញ្ជើញ ឬ សរសេរអត្ថបទដាក់ក្នុងកាសែត ដោយមានប័ណ្ណឆ្លើយតបសំរាប់អោយគេសរសេរឆ្លើយ តប ហើយហែកផ្ញើមកយើងវិញ ។ បើសិនជាគេចង់ សិក្សាព្រះគម្ពីរ ឬ ចង់ឱ្យអ្នកជឿអធិស្ឋានសំរាប់គេ ។
- ធ្វើសេចក្តីអញ្ជើញ ឬ ធ្វើកម្មវិធីផ្សាយដំណឹងល្អតាមវិទ្យុ ។
- ធ្វើការស្ទង់មើលមតិរបស់មនុស្ស នៅក្នុងសហគមន៍ ។
- លក់សៀវភៅ ឬ អត្ថបទដែលស្តីអំពីដំណឹងល្អ ។
- រៀបចំធ្វើវគ្គសិក្សាស្តីអំពីការលើកកំពស់ទំនាក់ទំនងរវាងប្តីប្រពន្ធ ។
- ប្រើភ្លេង ចំរៀង កំណាព្យ និង រឿងល្ខោន ។
- ធ្វើការអភិវឌ្ឍក្នុងសហគមន៍ ។
- ធ្វើសកម្មភាពកីឡា ។ល។ ។

BETA VERSION released prior to proofreading

- ប្រើព្រះគម្ពីរ ដើម្បីបង្រៀនដំណឹងល្អព្រះយេស៊ូ ។

អាចប្រើសំភារៈបង្រៀនផ្សេងទៀតបាន តែបើសិនជាពួកអ្នកថ្វាយខ្លួនអាចមានប្រាក់ទិញសំភារៈទាំងនោះបានប៉ុណ្ណោះ ។ (សូមគិតពីតម្លៃសំភារៈសិក្សាសំរាប់អ្នកក្រ) ។

- លើកទឹកចិត្តពួកគេអោយប្រតិបត្តិតាមសេចក្តីបង្គាប់របស់ ព្រះអម្ចាស់ គឺអោយកែប្រែចិត្តគំនិត និង ជឿព្រះអង្គ ។

- សួរសំនួរអំពីដំណឹងល្អ ដើម្បីអោយអ្នកដែលទទួលជឿនោះមានឱកាសបញ្ជាក់ពីសេចក្តីពិតរបស់ដំណឹងល្អ និង ជំនឿរបស់ពួកគេ ។

- ជួយមេគ្រួសារអោយអាចបង្រៀនក្រុមគ្រួសារ និង មិត្តភក្តិរបស់ពួកគេ អំពីសេចក្តីដែលពួកគេបានរៀនរួចហើយ ។

- បន្តស្វែងរកជួបមិត្តភក្តិ និង សាច់ញាតិរបស់ក្រុមគ្រួសារដែលកំពុងរៀនដំណឹងល្អជាមួយអ្នក ។

មិត្តភក្តិ និង សាច់ញាតិទាំងនោះ នឹងបើកចិត្តទទួលដំណឹងល្អពីអ្នកដែលគេស្គាល់ខ្លាំងជាងពីអ្នកដែលគេមិនធ្លាប់ស្គាល់ ។ នៅពេលដែលមនុស្សម្នាក់ថ្វាយខ្លួន សូមឆាប់ជួយអ្នកនោះ អោយចេះ



- បង្រៀនតាមរបៀបមួយ ដែលអ្នកស្តាប់អាចបង្រៀនតាមបានដោយស្រួល ។

  នេះជាការសំខាន់ ពីព្រោះអ្នកស្តាប់ទាំងនោះដែលថ្វាយខ្លួន នឹងមានតួនាទីផ្សាយដំណឹងល្អ តាមរបៀបដែលអ្នកធ្វើគំរូឱ្យពួកគេ ។

BETA VERSION released prior to proofreading

  សៀវភៅសំរាប់សិក្សាព្រះគម្ពីរ ដែលនាំអោយមានលទ្ធផលល្អ គឺ សៀវភៅ «ដំណឹងល្អបំផុត » ។ សៀវភៅនោះ មានមេរៀនប្រាំបី ។ មេរៀននិមួយៗមានរូបគំនូរ ដែលទាក់ទាញអារម្មណ៍មនុស្សអោយយល់ពីប្រធានបទ ហើយមានវគ្គគម្ពីរ សំនួរស្រួលៗ និង កិច្ចការដែលអាចជួយមេគ្រួសារបង្រៀនរឿងដល់គ្រួសាររបស់គាត់ និង ដឹកនាំគ្រួសារគាត់អោយជឿលើព្រះអម្ចាស់ (ក្លូន សៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល លេខ ២) ។

- ជួយសហគមន៍ដែលមានសេចក្តីត្រូវការ ជាពិសេសពេលមានគ្រោះអាសន្ន ដែលត្រូវជួយជាបន្ទាន់ ។

  នៅពេលដែលមានសហគមន៍ណាមួយមានអាសន, គ្រោះថ្នាក់ជាបន្ទាន់ សូមដោះស្រាយទាំងសេចក្តីត្រូវការខាងសម្ភារៈរបស់បុគ្គល ទាំងសេចក្តីត្រូវការរបស់សហគមន៍ទាំងមូល ។ ធ្វើដូច នេះគឺបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្ស ។ ការធ្វើដូចនេះ សំខាន់ណាស់នៅក្នុងសង្គម ដែលប្រឆាំងនឹងដំណឹងល្អ ។ ប៉ុន្តែ ទោះជាយ៉ាងណា ក៏សូមកុំអោយការងារសង្គមកិច្ច បង្វែរអ្នកអោយឃ្លាតឆ្ងាយពីភារៈកិច្ចអ្នក ជាអ្នកផ្សាយដំណឹងល្អអោយសោះ ។ សូមប្រយ័ត្ន កុំរៀបចំធ្វើកម្មវិធីចែកចាយចំណីអាហារ និង សំលៀកបំពាក់ ដោយឥតគិតថ្លៃជាប់

ជាប្រចាំ ដែលនាំឱ្យមនុស្សមករកអ្នកដោយមូលហេតុខុសឆ្គង ។ ពេលដែលក្រុមជំនុំថ្មីបានបង្កើតហើយ ក្រុមជំនុំថ្មីត្រូវទទួលបន្ទុកជួយអ្នកខ្វះខាតនៅក្នុងសហគមន៍នោះ ។ សូមចងចាំថា ក្រុមបង្កើតក្រុមជំនុំគ្រាន់តែធ្វើការងារនៅក្នុងសហគមន៍នោះបណ្តោះអាសន្នប៉ុណ្ណោះ ។ ក្រុមមិនត្រូវធ្វើគំរោងដែលកំណត់ថា ក្រុមជំនុំថ្មីនឹងមិនអាចដំណើរការបាន ដោយខ្លួនឯងនោះឡើយ ។

តើអ្នកបានជួយបំរើមនុស្សខ្វះខាត ដោយរបៀបណា ?

BETA VERSION released prior to proofreading

គោលការណ៍ណែនាំសំរាប់បង្រៀនដំណឹងល្អ

- អធិស្ឋាន ដើម្បីរៀបចំចិត្តគំនិតអ្នកសិន ហើយសឹមទៅសួរសុខទុក្ខ ។
- នៅពេលដែលអ្នកអាចធ្វើបាន សូមបង្កើតក្រុមតាមផ្ទះ ។
- ធ្វើអោយសេចក្តីបង្រៀនមានការទាក់ទងនឹងអ្វីៗ ដែលពួកគេចេះដឹងស្រាប់ហើយ និង អ្វីៗដែលពួកគេជឿហើយ ។

  (ពត៌មានដែលអ្នកប្រមូលបាន នៅក្នុងគោលការណ៍ណែនាំទី ៣ របស់សៀវភៅនេះ អាចជួយអ្នកបាន) ។
- ជួយពួកគេអោយចាប់អារម្មណ៍ ដោយសួរសំណួរ និងនាំពួកគេពិភាក្សាពីប្រធានបទ ។

BETA VERSION released prior to proofreading

៥- ការថ្វាយខ្លួនរបស់ឆ្មាំគុក និង ក្រុមគ្រួសាររបស់គាត់ ដែលជឿលើព្រះយេស៊ូ : កិច្ចការ ១៦

៦-ព្រះយេស៊ូជាអាហារ ដែលផ្តល់ជីវិត : យ៉ូហាន ៦

៧-ព្រះយេស៊ូប្រោសមនុស្សខ្មោចថ្លង់ម្នាក់ : ម៉ាកុស ៥

៨-អ្នកបៀតបៀនពួកគ្រីស្តជនម្នាក់ទទួលជឿព្រះយេស៊ូ និងទទួលពិធីជ្រមុជទឹក : កិច្ចការ ៩

- និទានរឿងដែលដកស្រង់ពីព្រះគម្ពីរប្រាប់ពួកអ្នកដែលមិន ចេះអាន ។ ប្រើរូបភាពដែលទាក់ទងនឹងរឿង លើកលែងតែក្នុងកាលៈទេសៈដែលអ្នកស្តាប់គិតថារូបភាពមានអំណាចសក្តិសិទ្ធិ ឬក៏ ពួកគេរាប់ថា ការប្រើរូបភាពដើម្បីពន្យល់ពីសាសនាមិនសមរម្យទេ ។

អ្នកអាចរកបានសំភារៈផ្សេងទៀត ដែលមានប្រសិទ្ធិភាព សំរាប់វប្បធម៌ដែលអ្នកផ្សាយដំណឹងល្អ ។

សូមចងចាំថា មនុស្សច្រើនតែបើកចិត្តទទួលជឿព្រះជាម្ចាស់ខ្លាំងជាង នៅពេលដែលគេកំពុងមានវិបត្តិ ឬហេតុការណ៍សំខាន់ ដូចជា មានសមាជិកម្នាក់ក្នុងគ្រួសារស្លាប់ មានជំងឺ ប្តូរទីលំនៅ ប្តូរការងារ រៀប អាពាហ៍ពិពាហ៍ លែងលះគ្នា បាត់បង់មិត្តភ័ក្តិ ឆ្លងទន្លេ ។ល។ ។





BETA VERSION released prior to proofreading

១៧:២០-៣៧, ២១:៥-៣៦) ការកាត់ ទោសព្រះយេស៊ូ ការសុគត និង ការមានព្រះជន្មរស់ឡើង វិញ (ជំពូក ២២-២៤) ។

- អត្ថបទ «ដំណឹងល្អបំផុត » : កម្រងមេរៀនសំរាប់ផ្សាយ ដំណឹងល្អ ដែលត្រូវសំរាប់បង្រៀនមេគ្រួសារ និង ដែល ត្រូវសំរាប់មេគ្រួសារបង្រៀនមេរៀនទាំងនេះដល់ក្រុមគ្រួសារ និង មិត្តភក្តិរបស់គាត់បន្ត ។ (កូនសៀវភៅសំរាប់បង្ហាត់ បង្រៀនគ្រួគង្វាល លេខ ២ របស់កម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត » មានអត្ថបទ «ដំណឹងល្អបំផុត ») ។

  ១-លោកណូអេ និង ទឹកជំនន់ធំ : កំណើតពិភពលោក ៦-៨

  ២-ការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះ-អម្ចាស់ : លូកា ២៣-២៤

  ៣-កូនពៅដែលបាត់ ហើយរកឃើញវិញ : លូកា ១៥

  ៤- មន្ត្រីជាតិអេត្យូពីទទួលពិធីជ្រមុជទឹក : កិច្ចការ ៨

- តើពិធីជ្រមុជទឹកជាអ្វី ?

- តើក្រុមជំនុំជាអ្វី ? (ព្រះគ្រីស្តជាព្រះសិរសារបស់ក្រុមជំនុំ)

ឧទាហរណ៍អំពីអត្ថបទសិក្សាព្រះគម្ពីរ សំរាប់ផ្សាយដំណឹងល្អតាមផ្ទះ :

- វគ្គគម្ពីរនៅក្នុងសៀវភៅដំណឹងល្អយ៉ូហាន ជាពិសេស រឿងនិទានអំពីមនុស្ស ដែលបានទទួលជឿលើព្រះយេស៊ូ និង ការសុគត ព្រមទាំងការមានព្រះជន្មរស់ឡើងវិញ របស់ព្រះអង្គផងដែរ ។

- វគ្គគម្ពីរដកស្រង់ពីសៀវភៅដំណឹងល្អលូកា : ឧទាហរណ៍ កំណើតព្រះអម្ចាស់ (១:១-៣៨, ២:១-២០) ព្រះយេស៊ូ ទទួលការជ្រមុជទឹក (៣:១-២២) ព្រះយេស៊ូឈ្នះការល្បួង (៤:១-១៣) ការអស្ចារ្យដែលព្រះយេស៊ូបានធ្វើ (៥:១-១១, ៧:១-១៧, ៨:២៦-៥៦, ៩:១០-១៧) សេចក្តី បង្រៀនរបស់ព្រះយេស៊ូ (៦:១៧-៤៩, ៨:៤-១៥, ១០:១-៣៧, ១១:១-១៣, ១៤:២៥-៣៥, ១៥:១-៣២, ១៦:១៩-៣១,

BETA VERSION released prior to proofreading



រៀបរាយតំណែលការងារបស់អ្នក និង ធ្វើផែនការ :

តើអ្នកពេញចិត្តនឹងកិច្ចការផ្សាយដំណឹងល្អ និង លទ្ធផលនៃការផ្សាយដំណឹងល្អដែរឬទេ ? (បើមិនទាន់ សូមសរសេរផែនការដែលនាំអោយបានលទ្ធផលល្អជាង) ។

បើមនុស្សមិនបើកចិត្តទទួលដំណឹងល្អ ឬ មនុស្សប្រឆាំងនឹង ដំណឹងល្អ តើដោយសារហេតុអ្វី ? (បើអ្នកមិនដឹង សូមខំរក អោយឃើញមូលហេតុនោះ) ។

បើមនុស្សធ្វើអោយឃើញច្បាស់ថា គេមិនបើកចិត្តទទួលដំណឹងល្អ ទេ ទោះជាអ្នកប្រាកដក្នុងចិត្តថា បានផ្សាយដំណឹងល្អពីព្រះគ្រីស្ត ដោយអំណត់តាមរបៀបដែលទាក់ទងនឹងវប្បធម៌ក៏ដោយ សូម «រលាស់ធូលីដីចេញពីជើងរបស់អ្នករាល់គ្នា » ហើយស្វែងរក សហគមន៍ដែលបើកចិត្តទទួលដំណឹងល្អវិញ ។ (ម៉ាថាយ ១០:១៤)

BETA VERSION released prior to proofreading

- តើអំពើបាបជាអ្វី ? (ការមិនជឿលើព្រះជាម្ចាស់ ការគោរពព្រះក្លែងក្លាយ អំពើបាបជាក់លាក់ណាមួយ និង លក្ខខ័ណ្ឌនៃការធ្លាក់ចុះក្នុងអំពើបាបរបស់មនុស្សទាំងអស់ នៅចំពោះព្រះជាម្ចាស់) ។

- តើសេចក្តីស្លាប់ជាអ្វី ? (សេចក្តីស្លាប់ខាងរូបកាយ និង ខាងព្រលឹងវិញ្ញាណ) ។

- តើការជំនុំជំរះជាអ្វី ? (អត្ថន័យ និង ការចៀសមិនរួច) ។

- តើព្រះយេស៊ូជានរណា ? (និស្ស័យជាព្រះ កំណើត ការសុគតដើម្បីលោះបាបយើង ការមានព្រះជន្មរស់ឡើងវិញ និង ការយាងមកជាលើកទីពីររបស់ព្រះអង្គ) ។

- តើជីវិតអស់កល្បជាអ្វី ?

- តើការកើតជាថ្មីជាអ្វី ? តើអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្វី ?

- តើការកែប្រែចិត្តគំនិត និង ជំនឿជាអ្វី ?

ឥឡូវនេះ មានអ្នកជឿប្រាំនាក់ ដែលចង់ទទួលពិធីជ្រមុជទឹក ។ ប៉ុន្តែ ពីធីជ្រមុជទឹកយើងត្រូវធ្វើនៅក្នុងសកម្មភាពទី ៨ ឯណោះ ។ តើអោយខ្ញុំធ្វើដូចម្តេចទៅ ?



អាចធ្វើសកម្មភាពច្រើនមុខ ក្នុងពេលជាមួយគ្នាបាន ។ សូមធ្វើពិធីជ្រមុជទឹកអោយពួកអ្នកដែលថ្វាយខ្លួន ហើយបន្តបង្រៀនដំណឹងល្អប្រាប់អ្នកឯទៀតផង ។

ខ្លឹមសារសំខាន់ដែលត្រូវប្រកាសប្រាប់ពេលបង្រៀនដំណឹងល្អព្រះយេស៊ូ :

- ព្រះជាម្ចាស់ជានរណា ? (ចរិតលក្ខណៈ ភាពបរិសុទ្ធ សេចក្តីស្រឡាញ់ ផែនការសង្គ្រោះ ព្រះពិរោធ និង ព្រះរាជ្យរបស់ព្រះអង្គ) ។

BETA VERSION released prior to proofreading

ដើម្បីទាក់ទងអោយបានមនុស្សកាន់តែច្រើន សូមទៅ សួរសុខទុក្ខសាច់ញាតិ និង មិត្តភ័ក្តិរបស់ពួកអ្នកដែល ចាប់អារម្មណ៍អំពីដំណឹងល្អ ។ សូមនាំអ្នកដែលបើក ចិត្តជឿទាំងនោះទៅជាមួយអ្នក ។ ធ្វើដូចនេះ នឹងមានប្រសិទ្ធិភាពជាងទៅទាក់ទងនឹងមនុស្ស ដែលយើង មិនធ្លាប់ស្គាល់ ។



«ហេតុនេះ បងប្អូនជាទីស្រឡាញ់អើយ ចូរមានចិត្តរឹងប៉ឹងមាំមួនឡើង ។ ចូរខំប្រឹងធ្វើកិច្ចការរបស់ព្រះអម្ចាស់ឱ្យបានចំរើនឡើង ជានិច្ច ដោយដឹងថា កិច្ចការដែលបងប្អូនធ្វើ រួមជាមួយព្រះ- អម្ចាស់នោះ មិនមែនឥតប្រយោជន៍ឡើយ » ។ (១ កូរិនថូស ១៥:៥៨)

សង្ខេបអំពីគោលដៅ

ទាក់ទងជាមួយមនុស្ស ដែលចាប់អារម្មណ៍នឹងដំណឹងល្អ ជា ពិសេសមេគ្រួសារ ។

តារាងសំរាប់វាស់ការរីកចំរើនរបស់ការបង្កើតក្រុមជំនុំក្នុងវប្បធ៌មផ្សេង

សូមបង្ហាញអំពីការរីកចំរើននៃការបង្កើតក្រុមជំនុំរបស់អ្នកផ្ទាល់ នៅខាងក្រោមនេះ ដោយសរសេរថ្ងៃ ខែ នៅមុខកិច្ចការដែល អ្នកបានធ្វើចប់ហើយ ។ កិច្ចការនេះ នឹងលើកទឹកចិត្តអ្នក ដោយសារអ្នកអាចឃើញខ្លួនឯងឈានទៅមុខ ក្នុងពេលដែល អ្នកកំពុងបង្កើតក្រុមជំនុំ ដោយជំនឿ ។

ជំណាក់ការនៃការស្វែងយល់ :

☐ ខ្ញុំមានអ្នកជំនួយដែលមានវប្បធម៌ និង ភាសាដូចបណ្តាជន នៅកន្លែងនោះ ដែលអាចជួយបង្រៀនខ្ញុំអោយចេះនិយាយ ភាសារបស់បណ្តាជននៅកន្លែងនោះ ជួយខ្ញុំយល់ពីស្ថានភាព របស់ពួកគេ និង ជួយខ្ញុំពេលទៅសួរសុខទុក្ខ ។ល។ ។

_____

☐ ខ្ញុំបានស្វែងរកវិធីសំរាប់ទាក់ទងជាមួយបណ្តាជន ស្របទៅ តាមវប្បធម៌ និង ស្ថានភាពរបស់ពួកគេ ។

_____

BETA VERSION released prior to proofreading

ពួកអ្នកថ្វាយខ្លួនដែលព្យាយាមក្នុងជំនឿ នឹងកើន ចំនួនជាច្រើន បើសិនជាអ្នកដែលបង្រៀនដំណឹងល្អ ប្រកាស ដំណឹងល្អពីប្រាំទៅប្រាំពីរដងសិន មុននឹងសូមអោយមនុស្ស ប្តេជ្ញាចិត្តដើរតាមព្រះគ្រីស្ត ។

- រៀបចំពេលវេលាសំរាប់អោយអស់អ្នកដែលបានរៀនពី ដំណឹងល្អបានសំរាក និង កំសាន្តរួមជាមួយគ្នា ។

  ជួយពួកគេអោយស្គាល់គ្នាទៅវិញទៅមក ក្នុងឋានៈជាសមាជិក របស់ក្រុមជំនុំថ្មី នៅពេលអនាគត ។ ប៉ុន្តែ សូមកុំអាលធ្វើ ការប្រជុំថ្វាយបង្គំ គឺសូមចាំអោយមានអ្នកជឿមួយក្រុមបានទទួល ពិធីជ្រមុជទឹកហើយសិន ចាំធ្វើការប្រជុំថ្វាយបង្គំ ។ សូមយក ចិត្តទុកដាក់បង្រៀនដំណឹងល្អដល់ពួកគេសិន ។

- ធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ស្របតាមសេចក្តីបង្គាប់ របស់ព្រះយេស៊ូ ។

  ពន្យល់ពួកអ្នកជឿថ្មីថា ពិធីជ្រមុជទឹកធ្វើអោយយើងរួមស្លាប់ និង រស់ឡើងវិញ រួមជាមួយព្រះយេស៊ូ ។ លិខិតរបស់លោកប៉ូលផ្ញើ ជូនគ្រីស្តបរិស័ទនៅក្រុងរ៉ូម ជំពូក ៦ ពន្យល់ថា យើងស្លាប់ពី អំពើបាប ហើយរស់ឡើងជាមួយព្រះគ្រីស្ត ដើម្បីមានជីវិតថ្មី និង វិសុទ្ធ ។



- ណែនាំសមាជិកក្រុមបង្កើតក្រុមជំនុំ អោយបង្រៀនដំណឹងល្អ ដល់ក្រុមគ្រួសារពីប្រាំទៅប្រាំពីរដង ។ ការណែនាំនេះរួម មានការរៀបចំមេរៀនសំរាប់បង្រៀនដំណឹងល្អ និង របៀប បង្រៀនដំណឹងល្អដែរ ។

  រៀបចំសមាជិកក្រុមបង្កើតក្រុមជំនុំ អោយចេះប្រកាសដំណឹងល្អ តាមរបៀបមួយ ដែលពួកអ្នកស្តាប់អាចយល់បាន ដោយស្រួល និង អាចធ្វើតាមបាន ពេលដែលពួកគេចែកចាយប្រាប់អ្នកឯទៀត ជាបន្ត ។

BETA VERSION released prior to proofreading

☐ ខ្ញុំបានរកមើលមនុស្ស ដែលខ្ញុំអាចទៅទាក់ទងជាមួយគេ និង ដែលមានប្រយោជន៍ជាងគេចំពោះការផ្សព្វផ្សាយ ដំណឹងល្អ នៅកន្លែងនោះ ។ នៅពេលដែលអ្នកទៅ សួរសុខទុក្ខគេ ជាលើកដំបូង សូមគ្រាន់តែស្តាប់គេសិន ដើម្បីអោយដឹងពីវប្បធម៌ និង ជីវិតរបស់គេ ។ សូមសួរ សំនួរ ហើយនៅស្ងៀមចាំស្តាប់ ។

☐ មេគ្រួសារមួយបានទទួលខ្ញុំ និង អញ្ជើញខ្ញុំអោយទៅជួបគាត់ ទៀត ។

ដំណាក់ការចែកចាយទៅវិញទៅមក :

☐ ខ្ញុំបានចាប់ផ្តើមចែកចាយប្រាប់បន្តិចបន្តួចពីវប្បធម៌ និង ជីវិត របស់ខ្ញុំផ្ទាល់ដល់អ្នកដែលខ្ញុំទាក់ទងជាមួយ ហើយខ្ញុំបន្តស្តាប់ ពួកគេ នេះជាការប្តូរគំនិតគ្នាទៅវិញទៅមក ។

☐ ខ្ញុំបានចូលរួមធ្វើសកម្មភាពសង្គមជាមួយគ្រួសារនោះ ដូចជា បរិភោគអាហារ លេងល្បែង ដើរលេងកំសាន្ត ចូលរួមក្នុង ពិធីខួបកំណើត ។ល។ ។ វប្បធម៌របស់ពួកគេលែងប្លែក សំរាប់ខ្ញុំទៀតហើយ ។ ខ្ញុំអាចចូលរួមជាមួយពួកគេ ដោយ ស្រួល ហើយខ្ញុំចេះរាប់អានពួកគេ ដោយមិនគិតពីវប្បធម៌ របស់ពួកគេទេ ។

☐ ខ្ញុំបាននិទានរឿងព្រះគម្ពីរប្រាប់ពួកគេ ជាពិសេស មេគ្រួសារ ។

☐ មេគ្រួសារដែលខ្ញុំទាក់ទង បានយល់ព្រមស្តាប់រឿងព្រះគម្ពីរ ដែលពន្យល់អំពីដំណឹងល្អព្រះយេស៊ូ ។

BETA VERSION released prior to proofreading

ជាពិសេស បង្រៀនមេគ្រួសារ ដែលបានចាប់ផ្តើមបង្រៀនក្រុមគ្រួសាររបស់គាត់ហើយ ។

- រៀបចំក្រុមបង្កើតក្រុមជំនុំអោយចេញទៅធ្វើកិច្ចការបំរើពីរៗនាក់ (បើអាចធ្វើបាន) ។

ព្រះអម្ចាស់ចាត់សាវ័ករបស់ព្រះអង្គអោយចេញទៅពីរៗនាក់ ។ ពួកសិស្សកម្រធ្វើដំណើរតែឯងណាស់ (លូកា ១០:១) ។ សមាជិកក្រុមមុខជាក្លាហានជាង បើចេញទៅមានគ្នា ។ អ្នកបំរើដែលមានបទពិសោធន៍ច្រើនជាង ត្រូវបង្ហាត់បង្រៀន និង ជួយអ្នកដែលមិនទាន់មានសមត្ថភាព ។ បើអ្នកទៅលេងគេមានគ្នាពីរ នាក់ នោះការផ្សាយដំណឹងល្អនឹងកាន់តែមានប្រសិទ្ធិភាព ។



៣-ទូលសូមអោយព្រះជាម្ចាស់បំភ្លឺចិត្តគំនិតរបស់ពួកគេ
ដែលមារសាតាំងបានបាំងអោយងងឹត អោយភ្លឺឡើង វិញ
(២ កូរិនថូស ៤:៤) ។

៤- ទូលសូមអោយព្រះជាម្ចាស់នាំសាច់ញាតិ និង អ្នកជិត ខាង
ដែលប្រឆាំងនឹងដំណឹងល្អអោយថ្វាយខ្លួន នៅ ពេលខាងមុខ ។

- ចែកចាយប្រាប់ក្រុមរបស់អ្នកអំពីការងារ ដែលត្រូវធ្វើដើម្បី
នាំក្រុមគ្រួសារទាំងមូលអោយទទួយលជឿព្រះយេស៊ូ ។

  បើអ្នកធ្វើការងារ ដើម្បីនាំគ្រួសារទាំងមូលៗឱ្យថ្វាយខ្លួនទាំងអស់ គ្នា
  នោះអ្នកត្រូវប្រើពេលវេលាយូរជាង តែអ្នកនឹងបង្កើតបានក្រុម ជំនុំមួយ
  ដែលរឹងមាំ ។ សូមកុំខិតខំនាំមនុស្សតែម្នាក់ពីក្នុងក្រុម
  គ្រួសារ ឬ ក្រុមមិត្តភក្តិរបស់គេអោយថ្វាយខ្លួនឡើយ ។ បើធ្វើ
  ដូចនេះ នឹងនាំអោយពួកគេប្រឆាំងនឹងដំណឹងល្អ ។

- កត់ឈ្មោះ និង អាស័យដ្ឋានរបស់ពួកអ្នកដែលយល់ព្រម
ស្តាប់ដំណឹងល្អ ព្រមទាំងឈ្មោះរបស់សមាជិកនៃក្រុមបង្កើត ក្រុមជំនុំ
ដែលនឹងទៅសួរសុខទុក្ខ និង បង្រៀនពួកអ្នក ទាំងនោះ ។

BETA VERSION released prior to proofreading

ដំណាក់ការចែកចាយពិសេស :

☐ មេគ្រួសារខ្លះបានស្តាប់រឿងរបស់ព្រះគម្ពីរ ដែលមាននៅក្នុង សៀវភៅ
«ដំណឹងល្អបំផុត» ដែលមានមេរៀនប្រាំបីស្តីអំពី ព្រះយេស៊ូ
ឬ កំរងរឿងរបស់ព្រះគម្ពីរ ដែលត្រូវនឹងវប្បធម៌ មូលដ្ឋាន
ហើយនិយាយអំពីជីវិត សេចក្តីបង្រៀន ការ- អស្ចារ្យ ការសុគត
និង ការមានព្រះជន្មរស់ឡើងវិញរបស់ ព្រះអម្ចាស់យេស៊ូរបស់យើង ។



គោលការណ៍ណែនាំ ទី ៦
បង្រៀនដំណឹងល្អព្រះយេស៊ូ



គោលដៅ :

- ពន្យល់ដំណឹងល្អដល់ក្រុមគ្រួសារទាំងឡាយ ដែលស្ម័គ្រចិត្ត ចង់ស្តាប់ ។

☐ រៀបចំផែនការរួចហើយ ។
☐ បានអនុវត្តហើយ (ថ្ងៃ ខែ) _____

BETA VERSION released prior to proofreading

(សូមអោយក្រុមអធិស្ឋាន អធិស្ឋានសំរាប់ក្រុមគ្រួសារ ដែលស្តាប់ដំណឹងល្អ និង ជំរាបក្រុមអធិស្ឋានអំពីសំណូមពរអធិស្ឋាន ផ្សេងៗទៀត)

យោបល់អំពីការបង្រៀនដំណឹងល្អដល់ក្រុមគ្រួសារ :

«លោកប៉ូលបានចូលទៅសាលាប្រជុំ ហើយមានប្រសាសន៍ដោយចិត្តអង់អាចក្នុងអំឡុងពេលបីខែ ។ លោកបានសន្ទនាជាមួយពួកគេអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និង ខិតខំណែនាំពួកគេឱ្យជឿ » ។ (កិច្ចការ ១៩:៨)

- ដឹកនាំក្រុមបង្កើតក្រុមជំនុំរបស់អ្នក អោយអធិស្ឋានពិសេសអំពីការប្រកាសដំណឹងល្អរបស់ពួកគេដល់ក្រុមគ្រួសារទាំង ឡាយ :

  ១- ទូលសូមអោយព្រះជាម្ចាស់ប្រទានឫទ្ធានុភាពដល់អ្នក ដើម្បីអាចប្រកាសដំណឹងល្អអោយបានច្បាស់លាស់ ។

  ២- ទូលសូមអោយព្រះជាម្ចាស់ចងវិញ្ញាណអាក្រក់ អំណាចរបស់វត្ថុសក្តិសិទ្ធិ និង អំពើអាបធ្មប់គ្រប់ យ៉ាង នៅក្នុងផ្ទះរបស់មនុស្ស ដែលចាប់អារម្មណ៍ អំពីដំណឹងល្អ ។